ស្កេនដើម្បីអាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ២០២៣

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ

របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)






## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

របាយការណ៍ស្ដីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ("របាយការណ៍") ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ("គម្រោង") អនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលប្រជាពលរដ្ឋទាំងអស់អាចទទួលបានសិទ្ធិមនុស្សមូលដ្ឋាន ទទួលបាននីតិរដ្ឋដែលគ្មាននិទណ្ឌភាព ទទួលបានការគោរពដោយស្មើភាពគ្នាគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយចីរភាព។

ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌សកំពុងហើរចេញពីរង្វង់មូលមេឃពណ៌ផ្ទៃមេឃ ដែលមានន័យថាជាការទាមទារសេរីភាពនៅកម្ពុជា។

## គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក




គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានគោលបំណងចម្បងចំនួនពីរ៖ ទីមួយ បង្កើនការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការ និងទីពីរ ផ្សព្វផ្សាយគោលគំនិតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងចំណោមសាធារណជន។ គម្រោងធ្វើការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយលទ្ធផលត្រូវបានបោះពុម្ពផ្សាយ ដោយផ្អែកលើភស្តុតាង សំដៅជំរុញការបង្កើននូវការគោរពតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិនៅក្នុងតុលាការ និងវិស័យយុត្តិធម៌នៅកម្ពុជា។ គម្រោងបាននឹងកំពុងសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ ចាប់តាំងពីឆ្នាំ ២០១៣ មកម្ល៉េះ ហើយនៅសាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ចាប់តាំងពីខែមិថុនា/កក្កដា ឆ្នាំ២០២២។ របាយ

ការណ៍នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទីប្រាំបី ដែលគម្រោងបានផលិតឡើង និងជារបាយការណ៍ទីមួយដែលរួមបញ្ចូលទិន្នន័យពីការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ទាំងអស់។

គម្រោងនេះក៏បានផលិត**កម្រងមេរៀន**ផងដែរ ដែលមានសេចក្ដីពន្យល់ពេញលេញ វីដេអូ ខិត្តប័ណ្ណព័ត៌មាន និងសំណួរអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់។ កម្រងមេរៀននេះអាចស្វែងរកបាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org)។

## សំណួរ និងមតិចូលរួម

របាយការណ៍នេះ និងរបាយការណ៍មុនៗស្ដីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅកម្ពុជា" អាចស្វែងរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ www.cchrcambodia.org និង នៅលើគេហទំព័រសិទ្ធិមនុស្ស https://www.sithi.org/tmp/publication?type=report ។

ប្រសិនបើលោកអ្នកមានចម្ងល់ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖

ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទលេខ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

# មាតិកា


**មាតិកា** ........ 3
**តារាងតួលេខ** ........ 5
**បញ្ជីអក្សរកាត់** ........ 7
**ខ្លឹមសារសង្ខេប** ........ 9
**១. សេចក្តីផ្តើម** ........ 13
១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ 13
១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ ........ 13
១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា ........ 14
១.២. វិសាលភាព និងវិធីសាស្ត្រ ........ 21
**២. ទិដ្ឋភាពទូទៅ** ........ 26
**៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការទាំងអស់** ........ 32
៣.១. សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ........ 32
៣.២. សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ ........ 33
**៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការមួយចំនួន** ........ 35
៤.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 35
៤.២. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ........ 39
៤.៣. សិទ្ធិមានវត្តមាននៅពេលសវនាការ ........ 43
៤.៤. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ........ 45
**៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនទាន់ត្រូវបានគោរពពេញលេញ** ........ 48
៥.១. សិទ្ធិមានសេរីភាព ........ 48
៥.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ........ 51
៥.៣. សិទ្ធិមានមេធាវី ........ 55
៥.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 60
៥.៥. សិទ្ធិបង្ហាញភស្តុតាង ........ 65
៥.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........ 68
៥.៧. ការប្រតិបត្តិរបស់ចៅក្រម ........ 71
៥.៨. សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ........ 76

**៦. ២០១៤-២០២២៖ ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍ភ្នំពេញ** ........ 85
**៧. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 95
៧.១. អនុសាសន៍រួម ........ 96
៧.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ........ 96
៧.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ........ 97
៧.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 97
៧.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ........ 97
៧.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី ........ 98
៧.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 98
៧.៨. អនុសាសន៍ទាក់ទងនឹងការប្រតិបត្តិរបស់ចៅក្រម ........ 99
៧.៩. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង ........ 99
៧.១០. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ ........ 99
៧.១១. អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ........ 100
**៨. ឯកសារគន្ថនិទ្ទេស** ........ 102
៨.១. ច្បាប់កម្ពុជា ........ 102
៨.២. លិខិតុបករណ៍គោលនយោបាយកម្ពុជា ........ 102
៨.៣. ច្បាប់អន្តរជាតិ ........ 103
៨.៤. ករណីច្បាប់ ........ 105
៨.៥. ទ្រឹស្តី ........ 107
៨.៦. សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ........ 107
៨.៧. ឯកសារសង្កេតការណ៍សវនាការ និងប្រព័ន្ធផ្ទុកទិន្នន័យរបស់ ម.ស.ម.ក ........ 108
៨.៨. ការបោះពុម្ពផ្សាយរបស់ ម.ស.ម.ក ........ 108
៨.៩. ផ្សេងៗ ........ 109

# តារាងតួលេខ

តួលេខទី ១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត (ឆ្នាំ២០២២)................. 21
តួលេខទី ២៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតនៅឆ្នាំ២០២២................. 26
តួលេខទី ៣៖ សវនាការនៃបណ្តឹងឧទ្ធរណ៍ដែលបានសង្កេតតាមប្រភេទនៃបទចោទប្រកាន់........... 27
តួលេខទី ៤៖ ភាគីដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ........................................................................ 28
តួលេខទី ៥៖ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ.................................................... 34
តួលេខទី ៦៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ...................................................... 36
តួលេខទី ៧៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈតាមតុលាការនីមួយៗ ......................... 37
តួលេខទី ៨៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់.................................. 40
តួលេខទី ៩៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់.................................. 42
តួលេខទី ១០៖ សិទ្ធិមានវត្តមាននៅពេលសវនាការ ................................................................ 44
តួលេខទី ១១៖ រយៈពេលនៃចំណាត់ការលើបណ្តឹងឧទ្ធរណ៍ (គិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍របស់សាលាឧទ្ធរណ៍រហូតដល់ថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍)........................................................ 46
តួលេខទី ១២៖ សិទ្ធិមានសេរីភាព..........................................................................................50
តួលេខទី ១៣៖ រយៈពេលនៃការឃុំខ្លួនគិតពីថ្ងៃឃុំខ្លួនបណ្តោះអាសន្នមកដល់ថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍.............................................................................................................................50
តួលេខទី ១៤៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ............................................................................................................................ 53
តួលេខទី ១៥៖ សិទ្ធិមានមេធាវី............................................................................................ 56
តួលេខទី ១៦៖ ការពន្យល់អំពីសិទ្ធិ ....................................................................................... 59
តួលេខទី ១៧៖ សិទ្ធិនៅស្ងៀម .............................................................................................. 60
តួលេខទី ១៨៖ ការសន្មតទុកជាមុនថាគ្មានទោស ..................................................................... 63
តួលេខទី ១៩៖ ការសន្មតទុកជាមុនថាគ្មានទោស ..................................................................... 65
តួលេខទី ២០៖ ការអានសំអាងហេតុពេលប្រកាសសាលដីកាដោយចៅក្រម................................ 70
តួលេខទី ២១៖ រយៈពេលនៃសវនាការដែលបានសង្កេត............................................................ 73
តួលេខទី ២២៖ អាយុនៅពេលបទល្មើសកើតឡើង ................................................................... 79

តួលេខទី ២៣៖ ចំនួនភាគរយនៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានបន្តឃុំខ្លួននៅឆ្នាំ២០២២ ...... 80
តួលេខទី ២៤៖ ការការពារឯកជនភាពរបស់កុមារ ........ 82
តួលេខទី ២៥៖ ការវិវឌ្ឍនៃសិទ្ធិនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ (ឆ្នាំ២០១៤-២០២២).. 86
តួលេខទី ២៦៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀម (ឆ្នាំ២០១៤-២០២២)........ 88
តួលេខទី ២៧៖ ភាគរយនៃជនជាប់ចោទដែលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិត (ឆ្នាំ២០១៤-២០២២) ........ 89
តួលេខទី ២៨៖ ការវិវឌ្ឍនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ (ឆ្នាំ២០១៤-២០២២) ........ 90
តួលេខទី ២៩៖ ការវិវឌ្ឍនៃសិទ្ធិមានមេធាវី (ឆ្នាំ២០១៤-២០២២) ........ 91
តួលេខទី ៣០៖ ការវិវឌ្ឍនៃសិទ្ធិមានវត្តមាននៅពេលសវនាការ (ឆ្នាំ២០១៤-២០២២)........ 91
តួលេខទី ៣១៖ ការវិវឌ្ឍនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព (ឆ្នាំ២០១៤-២០២២) ........ 92
តួលេខទី ៣២៖ ការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ (ឆ្នាំ២០១៤-២០២២).... 93
តួលេខទី ៣៣៖ ការវិវឌ្ឍនៃការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នចំពោះកុមារទំនាស់នឹងច្បាប់ (ឆ្នាំ២០១៤-២០២២) ........ 94

# បញ្ជីអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា។ |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការនៅពេលសង្កេត។ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍។ |
| ក្រមសីលធម៌ | ឯកសារកំណត់អំពីកាតព្វកិច្ចនានានៃការមិនជ្រៀតជ្រែក គោលបំណងមិនលម្អៀង និងការសម្ងាត់ដែលចងជាកាតព្វកិច្ចដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ |
| សាលាឧទ្ធរណ៍/តុលាការ | សាលាឧទ្ធរណ៍( ទាំងបួន )នៃព្រះរាជាណាចក្រកម្ពុជា។ |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ។ |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍។ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ |
| មិនដឹង | ព័ត៌មានដែលមិនទទួលបាន ឬមិនបានតាមដានបន្ត។ |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនពាក់ព័ន្ធ។ |
| ក.ស.ម.វ.ប | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ។ |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ |

| | |
|---|---|
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអ៊ឺរ៉ុប។ |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ |
| គម្រោង | គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក។ |
| អំឡុងពេលធ្វើរបាយការណ៍ | ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២២។ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា។ |
| អ្នកសង្កេតការណ៍ | អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ |
| ស.ស.ស.ម | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ |
| អ.ស.ប | អង្គការសហប្រជាជាតិ។ |
| យូនីសេហ្វ | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ។ |
| អ្នករាយការណ៍ពិសេស | អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា។ |
| ច្បាប់អ៊ុនតាក់ | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលឆ្នាំ១៩៩២។ |

# ខ្លឹមសារសង្ខេប

នៅចន្លោះថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (“អំឡុងពេលធ្វើរបាយការណ៍”) គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក (“គម្រោង”) បានសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌចំនួន ៥២១ សំណុំរឿង នៅសាលាឧទ្ធរណ៍ចំនួនបួន នៅ**ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ**[1] ដើម្បីវាយតម្លៃលើការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់តុលាការ ដូចមានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញ និងវិភាគទិន្នន័យ ដែលប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍ និងក្នុងគោលបំណងរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា។

ការបរិយាយក្នុងខ្លឹមសារសង្ខេបនេះ មិនឆ្លុះបញ្ចាំងពីការអនុវត្តរបស់សាលាឧទ្ធរណ៍នីមួយៗជាក់លាក់នោះទេ លើកលែងតែការប្រៀបធៀបទិន្នន័យនឹងឆ្នាំកន្លងមករបស់សាលាឧទ្ធរណ៍ភ្នំពេញ យ៉ាងណាក៏ដោយការបង្ហាញទិន្នន័យលម្អិតរបស់សាលាឧទ្ធរណ៍នីមួយៗមានបញ្ជាក់ក្នុងផ្នែកផ្សេង។

របាយការណ៍នេះរកឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅចំពោះមុខតុលាការដូចជា សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។

ការសង្កេតសវនាការនេះ ក៏បានរកឃើញពីកង្វះការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួនដែលជាសិទ្ធិមូលដ្ឋាន។ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព និងផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ត្រូវបានចាត់ចំណាត់ថ្នាក់ថាមិនទាន់បានគោរពពេញលេញនៅឡើយ ដោយហេតុថាជនជាប់ចោទមួយចំនួនបានអះអាងថា ពួកគេបានទទួលរងអំពើហិង្សា ឬការធ្វើទារុណកម្មដើម្បីបង្ខិតបង្ខំឱ្យពួកគេឆ្លើយសារភាពអំពីបទល្មើសដែលបានចោទប្រកាន់ (ជនជាប់ចោទចំនួន ១៧ នាក់ ក្នុងចំណោម ៧២៤ នាក់) នៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌។

សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈ មិនទាន់ត្រូវបានគោរពពេញលេញ ដោយហេតុថា សវនាការចំនួន ១៤០ ក្នុងចំណោម ៥២១ សំណុំរឿង ដែល ម.ស.ម.ក បានសង្កេត ពុំមានការផ្សព្វផ្សាយកាលវិភាគសវនាការនៅលើប្រព័ន្ធអនឡាញ ឬនៅលើក្តារព័ត៌មាននៅខាងក្រៅបន្ទប់សវនាការនោះទេ។ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយហេតុថាចំនួន ៣០,៣% នៃសំណុំរឿងដែលបានសង្កេត ចៅក្រមមិនបានអានប្រាប់អំពី

[1] គម្រោងនេះបានចាប់ផ្តើមសង្កេតសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងនៅសាលាឧទ្ធរណ៍ព្រះសីហនុ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២។

បទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងពួកគេឡើយ ហើយចំនួន ១០% នៃសំណុំរឿងដែលបានសង្កេត ចៅក្រមមិនបានអានប្រាប់ទាល់តែសោះអំពីបទចោទប្រកាន់ប្រឆាំងនឹងពួកគេ។

សិទ្ធិមានមេធាវីមិនទាន់ត្រូវបានគោរពពេញលេញនោះទេ ទោះបីជាតុលាការបានអនុវត្តយ៉ាងត្រឹមត្រូវតាមច្បាប់ជាតិក៏ដោយ ព្រោះថាមានចំនួន ៣៣,៣% នៃជនជាប់ចោទពុំមានមេធាវីការពារនោះទេចំពោះសំណុំរឿងបទមជ្ឈិម និងបទលហុ។ លើសពីនេះ នៅក្នុងសំណុំរឿងចំនួន ៦៩ ក្នុងចំណោមសំណុំរឿងចំនួន ៥២១ ដែល ម.ស.ម.ក បានសង្កេត ចៅក្រមមិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីនោះទេ ហើយនៅក្នុងសំណុំរឿងចំនួន ៤៧ ចៅក្រមបានត្រឹមតែប្រាប់ជនជាប់ចោទ ដោយមិនបានពន្យល់អំពីសិទ្ធិជាមូលដ្ឋាននេះទេ។ ស្រដៀងគ្នានេះដែរ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសនៅតែមិនទាន់ត្រូវបានគោរពពេញលេញ ដោយហេតុថា ចៅក្រមមិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទចំនួន ៤៩,២% នៃជនជាប់ចោទទាំងអស់អំពីសិទ្ធិនៅស្ងៀមរបស់ពួកគេឡើយ។ លើសពីនេះ ជនជាប់ចោទចំនួន ៣៣,៩% បានបង្ហាញខ្លួនចំពោះតុលាការក្នុងឯកសណ្ឋានពន្ធនាគារដូចគ្នាទៅនឹងទណ្ឌិតដែរ ក្នុងនោះរួមទាំងកុមារចំនួនប្រាំមួយនាក់ផងដែរ។

សិទ្ធិមានសេរីភាព គឺតុលាការមិនទាន់បានគោរពពេញលេញនៅឡើយ ដោយជនជាប់ចោទចំនួន ៤១០ នាក់ ក្នុងចំណោម ៧២៤ នាក់ ត្រូវបានឃុំខ្លួន លើសពីនេះជនជាប់ចោទទាំងអស់នៅតែត្រូវបានបន្តការឃុំខ្លួនក្នុងពន្ធនាគារដោយមិនមានការសម្រេចឱ្យជនជាប់ចោទបាននៅក្រៅឃុំនោះឡើយ ក្នុងចន្លោះពេលនៃបណ្តឹងឧទ្ធរណ៍ដល់សាលាឧទ្ធរណ៍ និងការរង់ចាំដល់ថ្ងៃប្រកាសសាលដីកា។ ជាចុងក្រោយ សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ដែលមានសិទ្ធិទទួលបានការការពារពិសេសស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា នៅតែបន្តទទួលរងការប៉ះពាល់ដោយមិនមានវិធានការជាក់លាក់ណាមួយត្រូវបានដាក់ចេញ ដើម្បីការពារឯកជនភាពរបស់កុមារនៅក្នុងអំឡុងពេលសវនាការ ដែលនៅក្នុងសំណុំរឿងចំនួន ១០ ក្នុងចំណោមសំណុំរឿងចំនួន ២២ ដែលបានសង្កេត គឺមានវត្តមាន និងមានការប្រើវិធានឃុំខ្លួន (ជនជាប់ចោទជាអនីតិជនចំនួន ២៣ នាក់ក្នុងចំណោម ២៦ នាក់) រួមទាំងកុមារពីរនាក់អាយុ ១៤-១៥ ឆ្នាំផងដែរ។

របាយការណ៍នេះ ក៏ធ្វើការប្រៀបធៀបទិន្នន័យក្នុងឆ្នាំនេះជាមួយនឹងទិន្នន័យនៃអំឡុងពេលធ្វើរបាយការណ៍មុនៗ ដើម្បីកំណត់ពីនិន្នាការ និងធ្វើការវិភាគពីការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍ភ្នំពេញ។[2] របាយការណ៍នេះបានរកឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានតុលាការគោរពជាប្រចាំ ចាប់តាំងពីឆ្នាំ២០១៤ មក រួមទាំង សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ ប៉ុន្តែសិទ្ធិមួយចំនួនទៀតមិនទាន់ត្រូវបានគោរពពេញលេញនៅ

---

[2] គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ត្រូវបានផ្អាកជាបណ្តោះអាសន្ននៅចន្លោះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦។ ជាលទ្ធផល មិនមានទិន្នន័យណាមួយអាចស្វែងរកបានសម្រាប់អំឡុងពេលនេះទេ។

ឡើយ ចាប់តាំងពីឆ្នាំ២០១៤ ដូចជា សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។ ទោះបីជាភាគច្រើននៃរបកគំហើញមានសង្គតិភាពក៏ដោយ ប៉ុន្តែក៏មានចំណុចសំខាន់ចំនួនបីបានលេចឡើង៖

ទីមួយ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដែលត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញចាប់តាំងពីឆ្នាំ២០១៤ ឃើញថាមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ដោយហេតុថាតុលាការមិនបានបិទផ្សាយកម្មវិធីសវនាការនៅលើក្តារព័ត៌មាន និង/ឬ នៅលើប្រព័ន្ធអនឡាញស្ទើរតែជិតមួយភាគបីនៃសំណុំរឿងទាំងអស់ដែលបានសង្កេត។

ទីពីរ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងនៅតែបន្តមិនទាន់ត្រូវបានគោរពពេញលេញដដែល។ នៅអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទចំនួន ៤% នៃជនជាប់ចោទទាំងអស់នៅក្នុងចំណោមសំណុំរឿងដែលបានសង្កេត បានអះអាងថាពួកគេទទួលរងអំពើហិង្សា ឬទារុណកម្មដើម្បីទទួលបានចម្លើយសារភាព នៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្រ្តីនគរបាលយុត្តិធម៌ កើនឡើងពីចំនួន ២,៥% នៅឆ្នាំ២០២១។ ទោះបីជាអត្រានេះទាបជាងអំឡុងពេលធ្វើរបាយការណ៍មុនៗក៏ដោយ ចំនួន ៦,៧% នៅឆ្នាំ២០១៩/២០២០ ចំនួន ៤,៣% នៅឆ្នាំ២០១៨/២០១៩ និងចំនួន ៧% នៅឆ្នាំ២០១៧/២០១៨ និងនៅឆ្នាំ២០១៦/២០១៧ ការលើកឡើងអំពីហិង្សា ឬទារុណកម្មនៅតែជាបញ្ហាចោទខ្ពស់ដដែល និងចាំបាច់ត្រូវមានការស៊ើបអង្កេតភ្លាមៗ និងឱ្យបានហ្មត់ចត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

ទីបី សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់មិនទាន់បានអនុវត្តបានប្រសើរនៅឡើយ ចាប់តាំងពីឆ្នាំ២០១៤មក ដោយមិនមានការចាត់វិធានការណាមួយដើម្បីការពារឯកជនភាពរបស់កុមារក្នុងអំឡុងពេលសវនាការ និងការប្រើប្រាស់ប្រព័ន្ធនៃការឃុំខ្លួន។ កុមារស្ថិតក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះបំផុត និងត្រូវទទួលបានការការការពារជាពិសេសនៅពេលប្រឈមមុខជាមួយប្រព័ន្ធយុត្តិធម៌។ ដូច្នេះ មានសារៈសំខាន់ដែលតុលាការត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេឱ្យបានពេញលេញ។

ម.ស.ម.ក នៅមិនទាន់អាចធ្វើការវិភាគដូចគ្នាសម្រាប់សាលាឧទ្ធរណ៍ទាំងបីផ្សេងទៀតបានទេ ដោយហេតុថាសកម្មភាពសង្កេតសវនាការទើបតែចាប់ផ្តើមនៅឆ្នាំ២០២២ នេះប៉ុណ្ណោះ។ ចុងបញ្ចប់នៃរបាយការណ៍នេះមានអនុសាសន៍សំខាន់ៗស្នើដល់តុលាការ និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំណុចខ្វះខាត ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ និងធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅទូទាំងប្រទេសកម្ពុជា។

ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះនឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ និងការគោរព

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងគាំទ្រដល់អ្នកដែលធ្វើការដើម្បីធានាថា ប្រព័ន្ធតុលាការនៅកម្ពុជាមានភាពត្រឹមត្រូវ និងស្មើភាពសម្រាប់ទាំងអស់គ្នា។

# ១. សេចក្ដីផ្ដើម

## ១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

> **មាត្រា ១០ នៃ ស.ស.ស.ម**
>
> មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នា និងពេញលេញ ក្នុងការសុំឱ្យតុលាការឯករាជ្យ និងមិនលម្អៀង ត្រួតពិនិត្យរឿងក្ដីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចបានលើសិទ្ធិកាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសសរស្តម្ភស្នូលនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងជាធាតុផ្សំដ៏សំខាន់មួយនៃការគោរពនីតិរដ្ឋ។ សិទ្ធិនេះផ្តល់សិទ្ធិដល់ជនម្នាក់ៗ និងគ្រប់រូប ដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌឱ្យទទួលបានការប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នា ទោះបីជារដ្ឋកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ពួកគេក្តី។ នៅពេលអនុវត្តបានត្រឹមត្រូវ សិទ្ធិនេះការពារទាំងសិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ និងធានានូវការគ្រប់គ្រងវិស័យយុត្តិធម៌បានត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមាន សិទ្ធិសំខាន់ៗមួយចំនួន និងរួមបញ្ចូលទាំងដំណើរការផ្លូវច្បាប់ទាំងមូល រាប់ចាប់តាំងពីការចាប់ខ្លួនជនសង្ស័យនៅពេលដំបូងរហូតដល់ការបញ្ចប់បណ្តឹងតវ៉ាជាស្ថាពរ។[3]

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ

សិទ្ធិនេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងត្រូវបានការពារដោយច្បាប់អន្តរជាតិតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ("ស.ស.ស.ម")[4] និងកតិកាសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")[5] ក្នុងចំណោមលិខិតុបករណ៍ផ្សេងទៀត។[6] មាត្រា ១០ នៃ ស.ស.ស.ម និងមាត្រា ១៤ (១) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ ក.អ.ស.ព.ន ពន្យល់បន្ថែមអំពីជាតុផ្សំផ្សេងៗនៃការជំនុំជម្រះដោយយុត្តិធម៌ ដែលមានជាអាទិ៍ តែមិនបានកម្រិត ដូចជាសិទ្ធិ និងគោលការណ៍ដូចតទៅ (សំដៅដល់ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌")៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិក្នុង

[3] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "តើអ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/what-are-fair-trial-rights ។

[4] ស.ស.ស.ម https://www.un.org/en/about-us/universal-declaration-of-human-rights។

[5] ក.អ.ស.ព.ន https://www.ohchr.org/en/instruments-mechanisms/instruments/international-covenant-civil-and-political-rights។

[6] *សូមមើលផងដែរ* មាត្រា ៨ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩) មាត្រា ៧ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១) មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០) មាត្រា ៤៧-៥០ នៃធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប (ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០០)។

ការនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិមានមេធាវី ការការពារប្រឆាំងនឹងការដាក់បន្ទុកលើខ្លួនឯង និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ប្រទេសកម្ពុជាបានចូលជាសមាជិកនៃ ក.អ.ស.ព.ន នៅឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ចូលដោយផ្ទាល់នូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់កម្ពុជា។[7] បទប្បញ្ញត្តិនេះមានន័យថា បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន អាចត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅឆ្នាំ២០០៧។[8]

### ១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានការពារនៅក្នុងប្រទេសកម្ពុជា តាមរយៈបទប្បញ្ញត្តិទូទៅ និងជាក់លាក់ ដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តមួយចំនួន។

ក្របខ័ណ្ឌមូលដ្ឋានសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ដែលធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរដូចខាងក្រោម៖

- គ្មានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ។
- គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោស ចាប់ខ្លួន ឬឃុំខ្លួនឡើយ លើកលែងតែស្របតាមច្បាប់។
- ហាមឃាត់ការបង្ខិតបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយ ឬការធ្វើទុក្ខទោសផ្សេងៗដែលដាក់ទណ្ឌកម្មបន្ថែមលើជននៅក្នុងឃុំ ឬជនជាប់ឃុំ ហើយជនណាដែលប្រព្រឹត្ត ចូលរួម ឬសមគំនិតក្នុងការប្រព្រឹត្តអំពើបែបនោះ ត្រូវបានផ្តន្ទាទោសតាមច្បាប់។
- ចម្លើយសារភាពដែលទទួលបានតាមរយៈការបង្ខំលើរាងកាយ ឬផ្លូវចិត្តមិនត្រូវបានទទួលស្គាល់ជាភស្តុតាងនៃពិរុទ្ធភាពឡើយ។
- រាល់វិមតិសង្ស័យដែលកើតឡើងនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោសរហូតទាល់តែតុលាការសម្រេចជាស្ថាពរលើសំណុំរឿងនោះហើយ
- ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិការពារខ្លួនតាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការ។

[7] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ៖ “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិ មនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំង ឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងកុមារ https://www.sithi.org/laws/2008-02-19-constitution-of-the-kingdom-of-cambodia។ កំណែបច្ចុប្បន្នភាពនៃរដ្ឋធម្មនុញ្ញដែលបានធ្វើវិសោធនកម្មចុងក្រោយនៅខែសីហា ឆ្នាំ២០២២ https://www.coj.gov.kh/wp-content/uploads/2022/08/0822-007.pdf។

[8] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០៧) ទំព័រ ២ https://www.ccc.gov.kh/detail_info_en.php?_txtID=453 ។

លើសពីនេះ មាត្រា ៥១ មាត្រា ១២៨ មាត្រា ១៣០ និងមាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញ ក៏បានចែងផងដែរអំពីការបែងចែកអំណាច សម្រាប់ប្រព័ន្ធតុលាការឯករាជ្យ ដែលធានាដោយព្រះមហាក្សត្រ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ដែលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០៩ និងចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០ ចែងអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[9] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ដែលបានអនុម័តនៅឆ្នាំ២០០៧[10] ចែងលម្អិតអំពីការប្រព្រឹត្តចំពោះជនសង្ស័យ។ ក្រមនេះកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ចាប់ពីពេលចាប់ផ្តើមការស៊ើបអង្កេតដំបូងរហូតដល់ពេលឃាត់ខ្លួន និងក្នុងអំឡុងពេលនៃដំណើរការព្រហ្មទណ្ឌទាំងមូល រហូតដល់បណ្តឹងតវ៉ាត្រូវបានចប់ជាស្ថាពរ។

បន្ថែមលើនេះ ច្បាប់គ្រឹះទាំងបីដែលទាក់ទងនឹងប្រព័ន្ធតុលាការ ពោលគឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[11] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[12] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[13] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ មានគោលបំណងធានានូវឯករាជភាពនៃអំណាចតុលាការ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ យ៉ាងណាក្តី ច្បាប់ទាំងនេះត្រូវបានរងការរិះគន់ថា បានធ្វើឱ្យចុះខ្សោយនូវការបែងចែកអំណាច និងឯករាជភាពរបស់ប្រព័ន្ធតុលាការ។[14]

---

[9] 'ក្រមព្រហ្មទណ្ឌកម្ពុជា' https://www.sithi.org/laws/2014-01-31-criminal-code-2014។

[10] ក្រមនីតិវិធីព្រហ្មទណ្ឌ បានជំនួសផ្នែកនៃបទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធតុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តនៅកម្ពុជាក្នុងអំឡុងអន្តរកាល (ឆ្នាំ១៩៩២) ("ច្បាប់អ៊ុនតាក់")។ អាចស្វែងរកបានតាមអាសយដ្ឋាននេះ៖ https://sithi.org/tmp/publication/view/2007-09-03-criminal-procedure-code-of-the-kingdom-of-cambodia-2007។

[11] 'ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ' (ឆ្នាំ២០០៤) https://www.arbitrationcouncil.org/download/law-on-the-organization-of-courts/?wpdmdl=2883&refresh=6327d7f63be941663555574 ។

[12] 'ច្បាប់ស្តីពីលក្ខខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា' (ឆ្នាំ២០១៤) https://www.arbitrationcouncil.org/download/law-on-the-status-of-judges-and-prosecutors/?wpdmdl=2879&refresh=6327d84ac10921663555658។

[13] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម' (ឆ្នាំ២០១៤) https://www.arbitrationcouncil.org/download/law-on-the-organization-and-functioning-of-supreme-council-of-magistracy/?wpdmdl=2875&refresh=6327d875ee9ff1663555701។

[14] ម.ស.ម.ក គោលដៅយុត្តិធម៌ និង អាដហុក 'របាយការណ៍រួមដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់លើកទី៣ នៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា' (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) វាក្យខណ្ឌ ២ www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS32.aspx (J7) ("ការដាក់ទៅ UPR ស្តីពីការទទួលបានយុត្តិធម៌ (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨) ម.ស.ម.ក 'ការវិភាគផ្នែកច្បាប់ សេចក្តីព្រាងច្បាប់ចំនួនបីទាក់ទងនឹង ប្រព័ន្ធតុលាការ (ឆ្នាំ២០១៤) https://sithi.org/medias/files/projects/tmp/publication/final-upr-cambodia-joint-submission-on-access-to-justice-kh-20231206-171032.pdf ការិយាល័យឧត្តមស្នងការ ប្រចាំកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20o

ជាចុងក្រោយ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលត្រូវបានអនុម័តក្នុងខែកក្កដា ឆ្នាំ២០១៦ និងចូលជាធរមាននៅខែមករា ឆ្នាំ២០១៧[15] ចែងអំពីបទដ្ឋាន និងនីតិវិធីសម្រាប់ដោះស្រាយជាមួយកុមារដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[16] ច្បាប់នេះចាំបាច់ត្រូវអនុវត្តឱ្យបានតឹងរ៉ឹង ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ។

នៅខែមិថុនា ឆ្នាំ២០០៣ ទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ("យុទ្ធសាស្ត្រ")។[17] យុទ្ធសាស្ត្រនេះកំណត់នូវគោលការណ៍ណែនាំចំនួនបួន ដែលដកស្រង់ចេញពីរដ្ឋធម្មនុញ្ញ ដើម្បីជាមគ្គុទ្ទេសក៍សម្រាប់ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការៈ សិទ្ធិបុគ្គល គោលការណ៍ប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ យុទ្ធសាស្ត្រនេះ ក៏បានកំណត់គោលដៅយុទ្ធសាស្ត្រចំនួនប្រាំពីរផងដែរ ដែលបង្កើតជាមូលដ្ឋាននៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ("ផែនការយុទ្ធសាស្ត្រ")។[18] គោលដៅទីមួយនៃគោលដៅទាំងនេះគឺការធ្វើឱ្យប្រសើរឡើងនូវការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន។ រដ្ឋាភិបាលបានចេញផ្សាយផែនការយុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ២០១៩-២០២៣ នៅពាក់កណ្តាលឆ្នាំ២០១៩ ដោយរៀបរាប់ពីអាទិភាពសំខាន់ៗរបស់រដ្ឋាភិបាល ដែលរួមមានការលើកកម្ពស់សេវាយុត្តិធម៌តាមរយៈការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពការងាររបស់មន្ត្រីអនុវត្តច្បាប់ ការពង្រឹងទំនុកចិត្តរបស់សាធារណជនចំពោះវិស័យតុលាការ និងការ

---

n%20status%20of%20J%20and%20P,%20ENG%20May%202014%20final.pdf ការិយាល័យឧត្តមស្នងការ ប្រចាំកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20SCM%20Draft%20law,%20ENG%20May%202014%20final.pdf ការិយាល័យឧត្តមស្នងការ ប្រចាំកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" (ខែឧសភា ឆ្នាំ២០១៤) http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20org%20of%20courts,%20ENG%20May%202014%20final.pdf។

[15] 'ច្បាប់ស្តីពីយុត្តិធម៌អនីតិជន' (ឆ្នាំ២០១៦) https://sithi.org/laws/2016-06-29-law-on-juvenile-justice។

[16] យូនីសេហ្វ 'សំណួរ-ចម្លើយអំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅកម្ពុជា' (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦) http://unicefcambodia.blogspot.com/2016/09/q-on-newly-adopted-juvenile-justice-law.html ។

[17] ក្រុមប្រឹក្សាស្តារនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ("CRBD" និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC" "ការអនុវត្តគោល នយោបាយរដ្ឋាភិបាល (ឆ្នាំ២០០៤) វាក្យខណ្ឌ ១៦ http://old.cdc-crdb.gov.kh/cdc/7cg_meeting/position_paper_eng2004/7cg_02_1.htm។

[18] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ "ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ" (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥) 'ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨' របស់រាជរដ្ឋាភិបាលកម្ពុជា ទំព័រ ៩-១២ វាក្យខណ្ឌ ២.១១ ដល់ ២.២៣ www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---sro-bangkok/documents/genericdocument/wcms_364549.pdf (សំណៅបកប្រែ)។

ប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌។[19] ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៩-២០២៣ ក៏បានប្រកាសថា ក្រសួងយុត្តិធម៌នឹងបន្តអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការរបស់ខ្លួនផងដែរ។

តុលាការ និងក្រសួងពាក់ព័ន្ធក៏បានធ្វើសេចក្តីប្រកាសមួយចំនួនផងដែរ និងបានផ្តួចផ្តើមគំនិតនាពេលថ្មីៗនេះ ដែលអាចនាំឱ្យមានការកែលម្អគួរឱ្យកត់សម្គាល់លើកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ៖

- ការបង្កើតសាលាឧទ្ធរណ៍តំបន់ចំនួនបី នៅបាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយគ្រោងនឹងបណ្តុះបណ្តាល និងដាក់ពង្រាយចៅក្រមឱ្យបានគ្រប់គ្រាន់ទៅកាន់សាលាឧទ្ធរណ៍តំបន់។[20] សាលាឧទ្ធរណ៍តំបន់ថ្មីទាំងបីបានចាប់ផ្តើមបើកសវនាការជំនុំជម្រះនៅឆ្នាំ២០២០[21] ដែលជួយសម្រួលដល់ការកកស្ទះសំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញ។ នៅក្នុងខែមិថុនា ឆ្នាំ២០២២ ក្រសួងយុត្តិធម៌ក៏បានប្រកាសថា ខ្លួននឹងបង្កើតសាលាឧទ្ធរណ៍ចំនួន ៣ បន្ថែមទៀតនៅសៀមរាប ឧត្តរមានជ័យ និងស្ទឹងត្រែង នៅចុងឆ្នាំ២០២២ ដើម្បីជួយជម្រះការកកស្ទះសំណុំរឿងបណ្តឹងឧទ្ធរណ៍ និងនាំយកសេវាផ្លូវច្បាប់ឱ្យកាន់តែកៀកនឹងកន្លែងដែលប្រជាពលរដ្ឋរស់នៅ។[22] ប៉ុន្តែ សាលាឧទ្ធរណ៍ថ្មីទាំងបីនេះមិនទាន់ត្រូវបានបង្កើតនៅឡើយទេ នៅពេលនេះ។
- ការចេញផ្សាយសាលក្រមរឿងក្តីរដ្ឋប្បវេណីចំនួន ១០៤ ដោយក្រសួងយុត្តិធម៌ដើម្បីប្រើប្រាស់ជាគំរូរបស់តុលាការសម្រាប់មេធាវី និងសាធារណជន ដោយសន្យាថានឹងបន្តផ្សព្វផ្សាយសាលក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។[23] យុទ្ធនាការរយៈពេល ១៣ ខែ របស់ក្រសួងយុត្តិធម៌ ដើម្បីជម្រះការកកស្ទះសំណុំរឿងរបស់តុលាការនៅទូទាំងប្រទេសកម្ពុជា ដើម្បីសម្រាលភាពចង្អៀតណែននៅពន្ធនាគារ។ ក្រសួងយុត្តិធម៌បានបញ្ចប់យុទ្ធនាការនៅខែមិថុនា ឆ្នាំ២០២១ ដោយបញ្ជាក់ថាមាន សំណុំរឿងព្រហ្មទណ្ឌសរុបជាង ៣៧៩០០ ស្មើនឹង ៩៦% នៃសំណុំរឿងដែលកំពុងកកស្ទះសរុប ដែលបានដោះស្រាយរួចរាល់។[24]

---

[19] ក្រសួងផែនការនៃ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣- ទំព័រ ២០៥-២០៦ វាក្យខណ្ឌ ៤.២១(៧) http://cdc-crdb.gov.kh/en/strategy/documents/nsdp-2019-2023_en.pdf ។

[20] របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨) វាក្យខណ្ឌ ៨១។

[21] Sen Davis "សាលាឧទ្ធរណ៍ព្រះសីហនុដំណើរការពេញលេញ" (*ខ្មែរថាមស៍* ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០) www.khmertimeskh.com/50761092/preah-sihanouk-appeal-court-in-full-service/។

[22] ប៊ុត រស្មីគង្គា "បន្ទុកសំណុំរឿងបង្ខំឱ្យក្រសួងបង្កើតសាលាឧទ្ធរណ៍បន្ថែមទៀត" (*ខ្មែរថាមស៍* ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២២) https://www.khmertimeskh.com/501090610/case-load-forces-ministry-to-set-up-more-appeal-courts/?fbclid=IwAR0ABKu6vtI3fI8yaslvC2aeLrpOM7sUUanWcYaTTi1LzHodqRyIEjt4PCM។

[23] ការបោះពុម្ពផ្សាយនេះអាចរកបាននៅគេហទំព័រ https://www.moj.gov.kh/kh/actual-civil-judgments។

[24] វួន ដារ៉ា "ក្រសួងយុត្តិធម៌ បញ្ចប់កិច្ចខិតខំប្រឹងប្រែងសម្អាតភាពជាប់គាំងសំណុំរឿង" (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១), https://www.phnompenhpost.com/national/ministry-justice-wraps-case-backlog-clean-effort។

- ការចេញ*ប្រកាស*ថ្មីរបស់ក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការឃ្លាំមើល ការត្រួតពិនិត្យ និងការស្តារនីតិសម្បទាឡើងវិញនៃជនជាប់ឃុំដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ដែលកំណត់ពីលក្ខខណ្ឌនៃការដោះលែងជនជាប់ឃុំដោយមានលក្ខខណ្ឌ។[25]
- ការដាក់ពង្រាយមេធាវីស្ម័គ្រចិត្តនៅទូទាំងប្រទេស ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("គណៈមេធាវី") ក្រោមការសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីផ្តល់លទ្ធភាពនៃការទទួលបានជំនួយផ្នែកច្បាប់សម្រាប់ជនជាប់ចោទដែលជាជនក្រីក្រនៅទូទាំងប្រទេស [26] រួមទាំងកុមារទំនាស់នឹងច្បាប់[27] និងការអនុម័តគោលនយោបាយរបស់គណៈមេធាវី ដើម្បីលើកទឹកចិត្តមេធាវីឱ្យផ្តល់សេវាគាំទ្របន្ថែមដល់ជនក្រីក្រ។[28]
- ការបង្កើតក្រុមជំនួយផ្នែកច្បាប់របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីការពារជនក្រីក្រដែលសិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន[29] និងការបង្កើតបណ្តាញទូរស័ព្ទជំនួយផ្នែកច្បាប់ ដើម្បីលើកកម្ពស់ការទទួលបានយុត្តិធម៌។[30]
- នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ មានការរាយការណ៍ថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតបន្ទប់មេធាវី ដើម្បីផ្តល់លក្ខខណ្ឌកាន់តែប្រសើរសម្រាប់ការប្រឹក្សាផ្នែកច្បាប់នៅតាម

---

[25] ឡាយ សាមាន "កំណត់ច្បាប់ដោះលែងទណ្ឌិតមុនកំណត់ (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១) https://phnompenhpost.com/national/inmate-early-release-rules-set ប្រកាសលេខ ០៩០ កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើល ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមឡើងវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ (ក្រសួងយុត្តិធម៌ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១) https://policypulse.org/wp-content/uploads/2021/07/Prakas_090_0721_MOJ_KH.pdf (មានជាភាសាខ្មែរតែប៉ុណ្ណោះ)។

[26] ប៊ុត រស្មីគង្គា "ងាកមកដាក់ពង្រាយមេធាវីស្ម័គ្រចិត្តបន្ថែមទៀតនៅទូទាំងប្រទេស (*ខ្មែរថាមស៍* ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១) https://www.khmertimeskh.com/50816333/bakc-to-deploy-more-volunteer-lawyers-nationwide/។

[27] វួន ដារ៉ា "កម្មវិធីមេធាវីការពារក្តីសាធារណៈពង្រីកដែនវិសាលភាពនៃការផ្តល់ជំនួយផ្នែកច្បាប់" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២២) https://www.phnompenhpost.com/national/public-defenders-programme-expanding-legal-aid-provision។

[28] Sen David "គោលនយោបាយថ្មីរបស់គណៈមេធាវី ដើម្បីផ្តល់ជំនួយស្ម័គ្រចិត្តផ្នែកច្បាប់ (*ខ្មែរថាមស៍* ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩) https://www.khmertimeskh.com/50808340/new-bar-association-policy-to-provide-pro-bono-legal-aid/។

[29] នៀម ឆេង "គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាគ្រោងបង្កើតក្រុមជំនួយផ្នែកច្បាប់" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩) www.phnompenhpost.com/national/chrc-form-legal-assistance-team; តាំង វីដា (Taing Vida) "គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាកត់សម្គាល់ការ សម្រេចបាននូវសមិទ្ធផលយ៉ាងច្រើនក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ (ខ្មែរថាមស៍ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០) https://www.khmertimeskh.com/698246/chrc-marks-notable-achievements-in-providing-free-legal-aid/ ។

[30] សុត គឹមសឿន "ទូរសព្ទទាន់ហេតុការណ៍ផ្លូវច្បាប់របស់គណៈកម្មាធិការសិទ្ធិមនុស្សទទួលបានការសរសើរ" (*ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩) www.phnompenhpost.com/national/human-rights-committees-legal-hotline-receives-praise។

ពន្ធនាគារ និងមណ្ឌលកែប្រែទូទាំងប្រទេស។ បន្ទប់មេធាវីទាំងនេះជួយឱ្យមេធាវី និងកូនក្តីរបស់ខ្លួនអាចប្រឹក្សាជាសម្ងាត់ ស្របតាមការអនុវត្តល្អបែបអន្តរជាតិ។[31]

- នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ក្រសួងយុត្តិធម៌បានឱ្យដឹងថា ខ្លួនកំពុងរៀបចំច្បាប់ដើម្បីបង្កើតតុលាការពាណិជ្ជកម្ម និងការងារដាច់ដោយឡែកមួយ។[32] គេរំពឹងថាតុលាការពាណិជ្ជកម្មនឹងដំណើរការនៅត្រឹមឆ្នាំ២០២៤។[33] នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងយុត្តិធម៌ និងធនាគារអភិវឌ្ឍន៍អាស៊ី បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការគាំទ្រការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងដំណើរការតុលាការពាណិជ្ជកម្មកម្ពុជា។ ក្រោមកិច្ចព្រមព្រៀងនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងគាំទ្រក្រសួងយុត្តិធម៌ក្នុងការកសាងសមត្ថភាពធនធានមនុស្ស និងបញ្ហាបច្ចេកទេស ជាពិសេស ការរៀបចំច្បាប់។[34]
- នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានប្រកាសពីផែនការបង្កើតកម្មវិធីនៅតាមទូរស័ព្ទសម្រាប់ពលរដ្ឋរាយការណ៍ពីការរំលោភសិទ្ធិមនុស្ស និងដើម្បីឱ្យមានដំណោះស្រាយទាន់ពេល។ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបាននិយាយថា អ៊ែប (App) អាចជួយឱ្យទទួលបានបណ្តឹងកើនឡើង ទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស ប៉ុន្តែមានបញ្ហាប្រឈមក្នុងការស្វែងរកថវិកាដើម្បីអនុវត្តគម្រោងនេះ។[35]
- វិធានការមួយចំនួនត្រូវបានអនុវត្ត ដើម្បីដោះស្រាយកង្វះខាតចៅក្រម និងព្រះរាជអាជ្ញានាពេលបច្ចុប្បន្ននេះ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣ ព្រះមហាក្សត្របានចេញព្រះរាជក្រឹត្យអនុញ្ញាតឱ្យចៅក្រម និងព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ចូលនិវត្តនៅអាយុ ៦៥ ជំនួសឱ្យនៅអាយុ ៦០ ឆ្នាំ តាមសំណើរបស់ក្រសួងយុត្តិធម៌។[36] នៅថ្ងៃទី១០ ខែមេសា ២០២៣ បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជាក៏

---

[31] គីម សារ៉ុម "បន្ទប់សម្រាប់ពិគ្រោះយោបល់រវាងមេធាវី ជាមួយកូនក្តីនៅតាមពន្ធនាគារទូទាំងប្រទេសត្រូវបានប្រើប្រាស់" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២) https://www.postkhmer.com/national/2022-05-26-1514-236984.html ។

[32] វ៉ុន ដារ៉ា "ក្រសួងយុត្តិធម៌កំពុងចាប់ផ្តើមបង្កើតតុលាការពាណិជ្ជកម្មនៅត្រឹមចុងឆ្នាំ២០២២" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២២) https://www.phnompenhpost.com/national/justice-ministry-moving-launch-commercial-court-end-2022-senior-official។

[33] ឱម ប៊ុនធឿន "មន្ត្រីក្រសួងយុត្តិធម៌៖ តុលាការពាណិជ្ជកម្មអាចដំណើរការនៅឆ្នាំ២០២៤" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣) https://www.phnompenhpost.com/business/commercial-court-could-function-early-2024-justice-ministry-officials។

[34] ហ៊ុន សិរីវឌ្ឍ "តុលាការពាណិជ្ជកម្មនឹងមាននៅកម្ពុជា" (eacnews.asia ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣) https://eacnews.asia/home/details/20062 ។

[35] ហ៊ុន សិរីវឌ្ឍ "គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជានឹងបង្កើត App សម្រាប់ពលរដ្ឋរាយការណ៍" (eacnews.asia ថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០២២) https://eacnews.asia/home/details/17748 ។

[36] ឡុង គីមម៉ារីតា "មន្ត្រីសាលាឧទ្ធរណ៍ឥឡូវនេះអាចចូលនិវត្តន៍នៅអាយុ ៦៥ ឆ្នាំស្របតាមព្រះរាជក្រឹត្យ" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣) https://www.phnompenhpost.com/national/appeal-court-officers-can-now-retire-age-65-says-royal-decree។

បានបើកទទួលសិស្សចៅក្រម និងព្រះរាជអាជ្ញា ៥០ នាក់ ក្រឡាបញ្ជី ១០០ នាក់ អាជ្ញាសាលា ៥០ នាក់ និងសារការី ៥០ នាក់ផងដែរ។[37]

ជាងនេះទៀត រដ្ឋាភិបាលបានអនុវត្តវិធានការមួយចំនួន ដើម្បីបន្តធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ រួមទាំងតាមរយៈការបង្កើនថវិកាជាតិសម្រាប់ជំនួយផ្នែកច្បាប់ [38] អនុវត្តការកសាងសមត្ថភាព ការបង្កើនឯករាជភាព និងភាពមិនលម្អៀងរបស់តុលាការ និងការបែងចែកអំណាច ព្រមទាំងការបង្កើនការគោរពសិទ្ធិបុគ្គលដើម្បី "ទទួលបានជំនឿទុកចិត្តកាន់តែច្រើនឡើងពីសំណាក់សាធារណជន" [39] ការបណ្តុះបណ្តាលសិស្សចៅក្រមអំពីក្រមសីលធម៌ និងគោលការណ៍សុចរិតភាព មុនពេលចាប់ផ្តើមធ្វើការវិនិច្ឆ័យលើរឿងក្តី ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ។[40] រដ្ឋាភិបាលក៏បានស្វះស្វែងធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌កុមារ តាមរយៈការបង្កើតក្រុមការងារអន្តរក្រសួង ដែលរួមមាន ក្រសួងយុត្តិធម៌ និងសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានកំពុងស្វែងរកលទ្ធភាពក្នុងការលើកកម្ពស់ការដាក់ទោសជំនួសចំពោះបទល្មើសស្រាល ដែលប្រព្រឹត្តដោយអនីតិជនក្រោមការសហការជាមួយអង្គការយូនីសេហ្វ និងបានរៀបចំបង្កើតផែនការ វិធានការ និងបទប្បញ្ញត្តិនានា ដើម្បីធានាបាននូវការអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនូវច្បាប់ស្តីពីអនីតិជន។[41]

ទាំងនេះគឺជាគំនិតផ្តួចផ្តើមគួរឱ្យសាទរ ដោយហេតុថាបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការអនុវត្តអនុសាសន៍ទាក់ទងនឹងការទទួលបានយុត្តិធម៌ ដែលរដ្ឋាភិបាលបានទទួលស្គាល់នៅក្នុងរបាយការណ៍ត្រួតពិនិត្យជាសកលតាមពេលកំណត់របស់កម្ពុជាលើកទីបីរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅខែមករា ឆ្នាំ ២០១៩ ដោយប្តេជ្ញាអនុវត្តនូវអនុសាសន៍ទាំងនោះ។[42]

---

[37] ឡុង គីមម៉ារីតា "ក្រសួងយុត្តិធម៌កំពុងស្វែងរកចៅក្រម និងមន្ត្រីថ្មី" (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣), https://www.phnompenhpost.com/national/justice-ministry-seeking-new-judges-officials ។

[38] ការិយាល័យឧត្តមស្នងការ (OHCHR) "តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១) វាក្យខណ្ឌ ៣០ https://cambodia.ohchr.org/sites/default/files/Ohchr-report/A_HRC_48_49.pdf។

[39] របាយការណ៍រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការត្រួតពិនិត្យជាសកលតាមកាលកំណត់ជុំទី ៣ (ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨) វាក្យខណ្ឌ ៧៤ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស' (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៩) A/HRC/៤២/៣១ វាក្យខណ្ឌ ៣០ https://cambodia.ohchr.org/sites/default/files/Ohchr-report/Role%20and%20achievements%20of%20the%200ffice.pdf ("របាយការណ៍ប្រចាំឆ្នាំរបស់ OHCHR (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩)"។

[40] រាជរដ្ឋាភិបាលកម្ពុជា "ការឆ្លើយតបរបស់កម្ពុជាចំពោះបញ្ជីបញ្ហាទាក់ទងនឹងរបាយការណ៍តាមពេលកំណត់លើកទីបីរបស់ខ្លួន" (ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២១), CCPR/C/KHM/RQ/៣, វាក្យខណ្ឌ ៥០ https://tbinternet.ohchr.org/_layouts/១៥/treatybodyexternal/Download.aspx?symbolno=CCPR%2fC%2fKHM%2fRQ%២f៣&Lang=en ("ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាទៅនឹងបញ្ជីបញ្ហាសម្រាប់ការពិនិត្យ យូភីអ លើកទី៣")។

[41] ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាទៅនឹងបញ្ជីបញ្ហាសម្រាប់ការពិនិត្យ យូភីអ លើកទី ៣ វាក្យខណ្ឌ ៨៥។

[42] ម.ស.ម.ក "ការទទួលបានយុត្តិធម៌នៅកម្ពុជា៖ ការពិនិត្យ យូភីអ លើកទី ៣
"https://sithi.org/medias/files/projects/tmp/publication/final-upr-cambodia-joint-submission-on-access-to-justice-kh-

## ១.២. ទិសាលភាព និងវិធីសាស្រ្ត

*តួលេខទី ១៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត (ឆ្នាំ២០២២)*

| ឈ្មោះសាលាឧទ្ធរណ៍ | សំណុំរឿងសរុប | អំឡុងពេលធ្វើរបាយការណ៍ |
|---|---|---|
| *សាលាឧទ្ធរណ៍ភ្នំពេញ* | | |
| ចំនួនសំណុំរឿង | **២៥៧** | ខែមករា-ធ្នូ ឆ្នាំ ២០២២ |
| ចំនួនបទឧក្រិដ្ឋ | ១២៩ | |
| ចំនួនបទមជ្ឈិម | ១២៤ | |
| ចំនួនបទលហុ | ៤ | |
| ចំនួនជនជាប់ចោទ | ៣៥២ | |
| ចំនួនកុមារទំនាស់នឹងច្បាប់ | **៦** | |
| ចំនួនជនជាប់ចោទជាស្ត្រី | ៥០ | |
| *សាលាឧទ្ធរណ៍បាត់ដំបង* | | |
| ចំនួនសំណុំរឿង | ១៤៣ | ខែមិថុនា-ធ្នូ ឆ្នាំ ២០២២ |
| ចំនួនបទឧក្រិដ្ឋ | ៥១ | |
| ចំនួនបទមជ្ឈិម | ៩០ | |
| ចំនួនបទលហុ | ២ | |
| ចំនួនជនជាប់ចោទ | ១៩៩ | |
| ចំនួនកុមារទំនាស់នឹងច្បាប់ | ១៥ | |
| ចំនួនជនជាប់ចោទជាស្ត្រី | ២៨ | |
| *សាលាឧទ្ធរណ៍ត្បូងឃ្មុំ* | | |
| ចំនួនសំណុំរឿង | ៦២ | ខែកក្កដា-ធ្នូ ឆ្នាំ ២០២២ |
| ចំនួនបទឧក្រិដ្ឋ | ១៨ | |
| ចំនួនបទមជ្ឈិម | ៤២ | |
| ចំនួនបទលហុ | ២ | |
| ចំនួនជនជាប់ចោទ | ៨៦ | |
| ចំនួនកុមារទំនាស់នឹងច្បាប់ | ០ | |

20231206-171032.pdf ម.ស.ម.ក ការអនុវត្តការពិនិត្យជាសកលតាមពេលកំណត់៖ ពីរឆ្នាំខាងមុខ" (ខែមករា ឆ្នាំ២០២១)

https://sithi.org/medias/files/projects/upr/infographic/Implementation%20of%20the%20Universal%20periodic%20review%20Eng.pdf សូមមើលផងដែរ "សំណើដាក់ជូនស្តីពីសិទ្ធិទទួលបានសំណើយុត្តិធម៌ក្រោម យូភីអ (ថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៨) របស់ ម.ស.ម.ក គោលដៅយុត្តិធម៌ និងអាជហុក។"

| | | |
|---|---|---|
| ចំនួនជនជាប់ចោទជាស្ត្រី | ១៣ | |
| *សាលាឧទ្ធរណ៍ព្រះសីហនុ* | | |
| ចំនួនសំណុំរឿង | ៥៩ | ខែកក្កដា-ធ្នូ ឆ្នាំ ២០២២ |
| ចំនួនបទឧក្រិដ្ឋ | ១៩ | |
| ចំនួនបទមជ្ឈិម | ៣៨ | |
| ចំនួនបទលហុ | ២ | |
| ចំនួនជនជាប់ចោទ | ៨៧ | |
| ចំនួនកុមារទំនាស់នឹងច្បាប់ | ៥ | |
| ចំនួនជនជាប់ចោទជាស្ត្រី | ១១ | |

អំឡុងពេលធ្វើរបាយការណ៍ទាំងមូល អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ជាធម្មតាបានចូលរួមក្នុងការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌនៅតុលាការទាំងបួនជារៀងរាល់ថ្ងៃ។ អ្នកសង្កេតការណ៍សវនាការបានប្រើតារាងសង្កេតការណ៍សវនាការ ដែលបានរៀបចំឡើងជាពិសេស (“តារាងសង្កេតការណ៍សវនាការ”) ដែលមានសំណួរជាង ៨០ ដែលផ្តោតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់មួយចំនួន រួមមានដូចខាងក្រោម៖[43]

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ និង
- សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។

ក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការណ៍សវនាការ និងសកម្មភាពសង្កេតសវនាការរបស់ខ្លួនដល់តំណាងតុលាការ ព្រមទាំងក្រសួងយុត្តិធម៌។

---

[43] ម.ស.ម.ក ‘តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍’ https://sithi.org/km/tmp/publication/view/2021-01-01-appeal-hearing-monitoring-checklist ។

ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធមួយទំព័រនៃតារាងសង្កេតការណ៍សវនាការ សម្រាប់ការប្រើប្រាស់នៅក្នុងសវនាការពាក់ព័ន្ធនឹងកុមារ។ ម.ស.ម.ក បានចងក្រងគោលការណ៍ណែនាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនេះ ("គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការ")[44] ដើម្បីផ្តល់នូវការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរទាំងនោះ ព្រមទាំងជានាឱ្យមានការបកស្រាយដូចគ្នាទាំងអស់ចំពោះសំណួរនីមួយៗ។ អ្នកសង្កេតការណ៍សវនាការក៏ត្រូវបានផ្តល់នូវឯកសារក្រុមខ័ណ្ឌច្បាប់ ដែលរៀបរាប់អំពីច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធនានា សម្រាប់សំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការ។

ម.ស.ម.ក បានយកចិត្តទុកដាក់យ៉ាងជាក់លាក់ចំពោះសិទ្ធិប្តឹងឧទ្ធរណ៍[45] ដែលសិទ្ធិនេះទទួលបានការត្រួតពិនិត្យសំណុំរឿងឡើងវិញ។ ម្យ៉ាងវិញទៀត ការពិនិត្យលើបណ្តឹងឧទ្ធរណ៍ត្រូវតែពាក់ព័ន្ធទាំងទិដ្ឋភាពផ្នែកច្បាប់ និងភស្តុតាងនៃការផ្តន្ទាទោស និងការកាត់ទោសបុគ្គលនោះ[46] ពោលគឺត្រូវផ្តល់នូវ "ការវាយតម្លៃពេញលេញលើ ភស្តុតាង និងកិច្ចដំណើរការជំនុំជម្រះ"។[47]

ជារួមមក ម.ស.ម.ក អនុវត្តតាមគោលការណ៍អន្តរជាតិក្នុងការសង្កេតសវនាការ[48] និងក្រមសីលធម៌ ("ក្រមសីលធម៌") សម្រាប់អ្នកសង្កេតការណ៍សវនាការរបស់ខ្លួន។[49] ក្រមសីលធម៌នេះគូសបញ្ជាក់អំពីកាតព្វកិច្ចនៃការមិនជ្រៀតជ្រែក ផ្អែកលើមូលដ្ឋាននៃការពិត និងរក្សាការសម្ងាត់ ដែលអ្នកសង្កេតការណ៍សវនាការត្រូវគោរពតាម។

---

[44] ម.ស.ម.ក 'គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍' https://sithi.org/tmp/publication/view/2014-01-29-guidance-notes-for-cchr-appeal-court-monitoring-checklist។

[45] ក.អ.ស.ព.ន មាត្រា ១៤ (៥) ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥។

[46] គណៈកម្មាធិការសិទ្ធិមនុស្ស 'សេចក្តីពន្យល់ទូទៅលេខ ៣២–មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌ (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧) CCPR/C/GC/៣២ វាក្យខណ្ឌ ៤៨ https://www.refworld.org/docid/578b2b2f2.html, ("គណៈកម្មាធិការសិទ្ធិមនុស្ស "សេចក្តីពន្យល់ទូទៅលេខ ៣២")។

[47] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥ V. P. Domukovsky et al. និង ប្រទេសហ្សកហ្ស៊ី (ថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៨) GAOR /៥៣/៤០ (លេខ II) ទំព័រ ១១១ វាក្យខណ្ឌ ១៨.១១ https://juris.ohchr.org/Search/Details/833។

[48] អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌' ការបោះពុម្ពលើកទីពីរ (ឆ្នាំ២០១៤) https://www.amnesty.org/en/documents/pol ៣០/០០២/២០១៤/en/ ('អង្គការលើកលែងទោសអន្តរជាតិ, សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ (ឆ្នាំ២០១៤)') គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ មគ្គុទ្ទេសក៍ជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់' (ឆ្នាំ២០០០) https://internationalcourts.net/system/files/LawyersCommitteeForHumanRights_WhatIsAFairTrial_2000.pdf អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) / ការិយាល័យស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស "ការសង្កេតសវនាការជំនុំជម្រះ៖ សៀវភៅណែនាំយោងសម្រាប់អ្នកប្រតិបត្តិ' (ឆ្នាំ២០០៨) https://www.osce.org/odihr/94216 គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ "ការសង្កេតការណ៍ការជំនុំជម្រះ (ឆ្នាំ២០០២) https://courtmonitoring.org/wp-content/uploads/trial_observation_manual_international-conmission-of-jurists.pdf។

[49] ម.ស.ម.ក 'ក្រមសីលធម៌នៃអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក' https://sithi.org/km/tmp/publication/view/2010-01-01-cchr-trial-monitoring-code-of-conduct ។

ការសង្កេតសវនាការរបស់ ម.ស.ម.ក នៅតុលាការមិនបានកំណត់លើសវនាការជាក់លាក់ណាមួយឡើយ។ សវនាការដែលត្រូវសង្កេត ផ្អែកតាមកាលវិភាគរបស់តុលាការ ដើម្បីធានាថាដំណើរការប្រមូលទិន្នន័យគឺមិនលម្អៀង និងត្រឹមត្រូវ។ នៅពេលដែលអ្នកសង្កេតការណ៍សវនាការបានសង្កេតសវនាការ រាល់ព័ត៌មានត្រូវបានកត់ត្រាដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍សវនាការ។ ទិន្នន័យដែលប្រមូលបានកម្រិតត្រឹមតែព័ត៌មានដែលមានក្នុងសវនាការប៉ុណ្ណោះ ដោយមិនមានការសម្ភាស ឬសាកសួរបន្ថែមណាមួយត្រូវបានធ្វើឡើងនោះទេ លើកលែងតែក្នុងករណីដែលអ្នកសង្កេតការណ៍សវនាការស្វែងរកព័ត៌មានទាក់ទងនឹងសាលដីកា ដែលមិនបានប្រកាសនៅថ្ងៃសវនាការ ដោយលើកពេលប្រកាសទៅថ្ងៃក្រោយជំនួសវិញ។ បន្ទាប់ពីសវនាការនីមួយៗ ទិន្នន័យដែលប្រមូលបានត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធផ្ទុកទិន្នន័យ")។[50]

ម.ស.ម.ក បានវិភាគទិន្នន័យសវនាការ ដែលបានកត់ត្រានៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ និងបានកំណត់ចំណុចវិជ្ជមាននៃការអនុវត្ត ក៏ដូចជាចំណុចត្រូវធ្វើឱ្យប្រសើរឡើងដែលកើតមាននៅអំឡុងពេលនៃសវនាការនីមួយៗ។ នៅពេលដែលបន្តអនុវត្តសកម្មភាពសង្កេតសវនាការ ប្រព័ន្ធផ្ទុកទិន្នន័យនឹងត្រូវបានយកមកប្រើប្រាស់ដើម្បីធ្វើការវិភាគប្រៀបធៀប និងកំណត់អំពីនិន្នាការនៃការអនុវត្តរបស់តុលាការ ការកែលម្អនូវចំណុចមិនទាន់ប្រសើរ និងផ្តល់ជាអនុសាសន៍។ សម្រាប់គោលបំណងនៃការវិភាគនេះ ម.ស.ម.ក ចាត់ទុកថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរព ប្រសិនបើការគោរពនោះមានកម្រិតជាភាគរយបានយ៉ាងតិចចំនួន ៨០% នៃសវនាការដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ ទោះជាយ៉ាងនេះក្តី នៅពេលមានការបំពានទៅលើសិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាន និងសិទ្ធិដាច់ខាត (សូមមើលទំព័រ ៤៩) ម.ស.ម.ក មិនកំណត់នូវចំណាត់ថ្នាក់នៃការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយផ្អែកលើភាគរយនោះឡើយ។

ម.ស.ម.ក បានធានាថា សាលាឧទ្ធរណ៍ទាំងអស់មានឱកាសក្នុងការផ្តល់ធាតុចូលរបស់ខ្លួនលើរបកគំហើញពីការសង្កេតសវនាការរបស់ ម.ស.ម.ក មុនពេលរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ។ នៅចុងឆ្នាំ ២០២២ ម.ស.ម.ក បានចាប់ផ្តើមរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយតុលាការគោលដៅ ដើម្បីបង្ហាញអំពីលទ្ធផលដែលបានរកឃើញពីការសង្កេតសវនាការ និងស្វែងរកការបញ្ជាក់ឱ្យបានច្បាស់លាស់ពីតុលាការទាំងនោះ។ នៅអំឡុងពេលកិច្ចប្រជុំទាំងនេះ តុលាការបានស្វាគមន៍ចំពោះការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងរបស់ ម.ស.ម.ក ក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ កិច្ចប្រជុំទាំងនេះបានធ្វើឡើងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ និងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ នៅសាលាឧទ្ធរណ៍ព្រះសីហនុ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០២២ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ នៅសាលាឧទ្ធរណ៍បាត់ដំបង និងនៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២៣ និងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

---

[50] ម.ស.ម.ក 'ប្រព័ន្ធផ្ទុកទិន្នន័យសង្កេតសវនាការរបស់ ម.ស.ម.ក' https://sithi.org/km/tmp/appeal ។

លើសពីនេះ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍នេះត្រូវបញ្ជូនទៅកាន់ប្រធានសាលាឧទ្ធរណ៍ និង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទាំងអស់ ដើម្បីពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍។ ម.ស.ម.ក បាន ទទួលធាតុចូលពីសាលាឧទ្ធរណ៍បាត់ដំបងក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣, សាលាឧទ្ធរណ៍ត្បូងឃ្មុំនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ និង សាលាឧទ្ធរណ៍ភ្នំពេញថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៣។ ដោយឡែកសាលាឧទ្ធរណ៍ព្រះសីហនុផ្តល់ធាតុនេះតាមរយៈលិខិតលេខ ១៩១៩ រប-ឧ/២៣ ចុះថ្ងៃ ទី២០ ខែកញ្ញា ឆ្នាំ២០២៣ ហើយធាតុចូលទាំងឡាយដែលបានផ្តល់ពីភាគីពាក់ព័ន្ធត្រូវបានបញ្ចូលទៅក្នុង របាយការណ៍នេះ ដើម្បីយល់កាន់តែច្បាស់នូវបញ្ហាប្រឈមនានារបស់អ្នកប្រតិបត្តិក្នុងវិស័យយុត្តិធម៌។ ម.ស.ម.ក បានជូនសេចក្តីព្រាងនេះដល់ក្រសួងយុត្តិធម៌ផងដែរ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ។

# ២. ទិដ្ឋភាពទូទៅ

ផ្នែកនៃរបាយការណ៍នេះ កំណត់នូវទិន្នន័យដើម ដែលបានកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការ ចំនួន ៥២១ សំណុំរឿង ដែលបានសង្កេតនៅតុលាការ ចន្លោះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ទិន្នន័យនេះ នឹងត្រូវធ្វើការវាយតម្លៃនៅក្នុងរបាយការណ៍ទាំងមូល។

*តួលេខទី ២៖ ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតនៅឆ្នាំ២០២២*



*តួលេខទី ៣៖ សវនាការនៃបណ្ដឹងឧទ្ធរណ៍ដែលបានសង្កេតតាមប្រភេទនៃបទចោទប្រកាន់*[51]

| *ប្រភេទនៃបទចោទប្រកាន់* |
|---|
| ***បទឧក្រិដ្ឋ៖*** មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌចែងថា បទឧក្រិដ្ឋជាបទល្មើសទាំងឡាយ ដែលមានទោសដាប់ពន្ធនាគារអតិបរមាលើសពីប្រាំឆ្នាំឡើងទៅ។ |
| **បទមជ្ឈិម៖** មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌចែងថា បទមជ្ឈិមជាបទល្មើសទាំងឡាយ ដែលទោសដាប់ពន្ធនាគារអតិបរមា លើសពីប្រាំមួយថ្ងៃឡើងទៅ និងតិចជាង ឬស្មើនឹងប្រាំឆ្នាំ។ |
| ***បទលហុ៖*** មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌចែងថា បទលហុជាបទល្មើសទាំងឡាយដែលមានទោសដាប់ពន្ធនាគារអតិបរមា ចំនួន ៦ ថ្ងៃ ឬតិចជាងនេះ ឬផ្តន្ទាទោសដោយពិន័យជាប្រាក់ប៉ុណ្ណោះ។ |













[51] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុបដែលបានសង្កេតនៅឆ្នាំ២០២២ (ចំនួន ៥២១ សំណុំរឿង)។

*តួលេខទី ៤៖ ភាគីដាក់ពាក្យបណ្តឹងឧទ្ធរណ៍*[52]




សេចក្តីសម្រេចដែលចេញដោយសាលាដំបូង អាចត្រូវបានប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន (មេធាវីការពារក្តី) និងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ទាំងពីរទាក់ទងនឹងបញ្ហារដ្ឋប្បវេណី)។[53] តួលេខទី៤ បង្ហាញថា ភាគច្រើននៃបណ្តឹងឧទ្ធរណ៍ (៨៣%) ត្រូវបានប្តឹងដោយភាគីជនជាប់ចោទ។

តារាងខាងក្រោមគូសបញ្ជាក់អំពីសិទ្ធិដែលបានគោរព និងសិទ្ធិមិនទាន់ត្រូវបានពេញលេញនៅក្នុងសវនាការដែល ម.ស.ម.ក បានសង្កេតសវនាការ៖

| សាលាឧទ្ធរណ៍ | សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរព | សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនទាន់ត្រូវបានគោរពពេញលេញ |
|---|---|---|
| **សាលាឧទ្ធរណ៍ភ្នំពេញ** | • សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ | • សិទ្ធិមានសេរីភាព<br>• សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល<br>• សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង<br>• សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ |

[52] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុបដែលបានសង្កេតនៅឆ្នាំ២០២២ (ចំនួន ៥២១ សំណុំរឿង)។
[53] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

| | | |
|---|---|---|
| | • សិទ្ធិមានវត្តមាននៅពេលសវនាការ | • សិទ្ធិមានមេធាវី<br>• សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ<br>• ការប្រតិបត្តិរបស់ចៅក្រម<br>• សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ |
| **សាលាឧទ្ធរណ៍បាត់ដំបង** | • សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ<br>• សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិមានវត្តមាននៅពេលសវនាការ<br>• សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល | • សិទ្ធិមានសេរីភាព<br>• សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង<br>• សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់<br>• សិទ្ធិមានមេធាវី<br>• សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ<br>• ការប្រតិបត្តិរបស់ចៅក្រម<br>• សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ |

| | | |
|---|---|---|
| សាលាឧទ្ធរណ៍ត្បូងឃ្មុំ | • សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់<br>• សិទ្ធិមានវត្តមាននៅពេលសវនាការ<br>• សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល | • សិទ្ធិមានសេរីភាព<br>• សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង<br>• សិទ្ធិមានមេធាវី<br>• ការប្រតិបត្តិរបស់ចៅក្រម<br>• សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស<br>• សិទ្ធិបង្ហាញភស្តុតាង |
| សាលាឧទ្ធរណ៍ព្រះសីហនុ | • សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី<br>• សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ<br>• សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់<br>• សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល | • សិទ្ធិមានសេរីភាព<br>• សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង<br>• សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ<br>• សិទ្ធិមានមេធាវី<br>• សិទ្ធិមានវត្តមាននៅពេលសវនាការ<br>• សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ<br>• ការប្រតិបត្តិរបស់ចៅក្រម<br>• សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស<br>• សិទ្ធិបង្ហាញភស្តុតាង<br>• សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ |

ផ្នែកខាងក្រោមនេះ ធ្វើការវិភាគលើការអនុវត្តរបស់តុលាការនូវធាតុផ្សំពាក់ព័ន្ធផ្សេងៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅអំឡុងពេលធ្វើរបាយការណ៍នេះ។ គោលបំណងនៃការវិភាគនេះ របាយការណ៍នឹងបង្ហាញពីទិដ្ឋភាពទាំងឡាយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលតុលាការបានគោរព និងបន្ទាប់មកបកស្រាយបំភ្លឺលើការអនុវត្ត ដែលមិនទាន់ត្រូវបានគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការទាំងអស់

### ៣.១. សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ខ) | មាត្រា ៤៨, ៩៨,១៤៥, ២៥៩ & ៣១៩ | មាត្រា ២៩ |

ជនណាដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ គួរត្រូវបានផ្ដល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី។ រយៈពេលដែល "គ្រប់គ្រាន់" អាស្រ័យលើកាលៈទេសៈជាក់ស្ដែងនៃសំណុំរឿងនីមួយៗ[54]" ទោះជាយ៉ាងនេះក្ដី គោលការណ៍ណែនាំបានកំណត់ថា ជនជាប់ចោទត្រូវតែមានលទ្ធភាពរៀបចំឱ្យបានត្រឹមត្រូវ ដើម្បីតតាំងនឹងភស្តុតាងរបស់អយ្យការ ធ្វើការស៊ើបអង្កេត និងបង្ហាញសាក្សីការពារក្ដី។ នេះជាតួនាទីរបស់មេធាវីការពារក្ដីក្នុងការស្នើសុំពន្យារពេលការជំនុំជម្រះ ប្រសិនបើខ្លួនយល់ឃើញថា ពេលវេលាសម្រាប់ការរៀបចំមេធាវីការពារក្ដីមិនគ្រប់គ្រាន់។[55]

មធ្យោបាយចាំបាច់សម្រាប់រៀបចំការពារក្ដី រួមមានការទទួលបានឯកសារសំណុំរឿង និងភស្តុតាងដើម្បីឱ្យជនជាប់ចោទដឹងច្បាស់អំពីបទចោទប្រកាន់លើពួកគេ និងដើម្បីអាចឱ្យពួកគេផ្ដល់ការណែនាំគ្រប់ជ្រុងជ្រោយដល់មេធាវីរបស់ខ្លួន។[56] ជាពិសេស រាប់បញ្ចូលទាំងការទទួលបានភស្តុតាងទាំងឡាយ ដែលព្រះរាជអាជ្ញាគ្រោងនឹងបង្ហាញនៅក្នុងតុលាការ និងភស្តុតាងដោះបន្ទុក។ នៅដំណាក់កាលនៃបណ្ដឹងឧទ្ធរណ៍នេះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេក្នុងការប្ដឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបានសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង ដែលមានសំអាងហេតុត្រឹមត្រូវ និងកំណត់ហេតុនៃការជំនុំជម្រះ ដើម្បីរៀបចំសំណុំរឿងរបស់ខ្លួន។[57] លើសពីនេះ ជនជាប់ចោទត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីទំនាក់ទំនងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយផ្ទាល់។ បញ្ញត្តិនេះធានាការគោរពគោលការណ៍

---

[54] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[55] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[56] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៣។

[57] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩។ សូមមើល គណៈកម្មាធិការសិទ្ធិមនុស្ស បណ្ដឹងលេខ ១៧៩៧/ ២០០៨ រវាង Mennen និងប្រទេសហូឡង់ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០) CCPR/C/៩៩/0/១៧៩៧/២០០៨, វាក្យខណ្ឌ ៨.២.-៨.៤, http://hrlibrary.umn.edu/undocs/1797-2008.html ។

ស្មើភាពគ្នា និងតម្រូវឱ្យជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ។ លើសពីនេះ មធ្យោបាយដែលអាចអនុញ្ញាតឱ្យមានទំនាក់ទំនងដោយសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ។[58]

ទោះបីជាការសង្កេតសវនាការលើបណ្ដឹងឧទ្ធរណ៍មិនបានផ្ដល់ឱ្យ ម.ស.ម.ក នូវរាល់ព័ត៌មានចាំបាច់ដើម្បីវាយតម្លៃថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្ដី និងទំនាក់ទំនងជាមួយមេធាវី តាមរយៈព័ត៌មានដែល ម.ស.ម.ក មាន ប៉ុន្តែមានភាពវិជ្ជមានដែលអាចកត់សម្គាល់បានដោយភាគច្រើននៃសំណុំរឿងដែលបានសង្កេត បង្ហាញថា សិទ្ធិទាំងនេះត្រូវបានគោរពដោយតុលាការទាំងបួន។ ម.ស. ម.ក បានរកឃើញថាមានជនជាប់ចោទតែបីនាក់គត់ (០,៤% នៃជនជាប់ចោទសរុប) ដែលមេធាវីរបស់គេត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្ដឹងឧទ្ធរណ៍ - ជនជាប់ចោទពីរនាក់នៅសាលាឧទ្ធរណ៍ភ្នំពេញ និងជនជាប់ចោទម្នាក់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ជនជាប់ចោទភាគច្រើនទទួលបានមេធាវីនៅមុនដំណើរការនីតិវិធី។ លើសពីនេះ គ្មានសំណុំរឿងណាមួយដែលមេធាវីរបស់ជនជាប់ចោទលើកឡើងពីបញ្ហាកង្វះខាតក្នុងការរៀបចំការពារក្ដីឱ្យបានគ្រប់គ្រាន់នោះទេ។

| |
|---|
| មានការលើកឡើងថា មានជនជាប់ចោទតែបីនាក់ប៉ុណ្ណោះ ដែលមេធាវីរបស់ខ្លួនត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្ដឹងឧទ្ធរណ៍។ នេះមានន័យថា សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ ទំនងត្រូវបានគោរពក្នុងចំណោមចំនួន ៩៩,៦% នៃជនជាប់ចោទ។ |

| |
|---|
| បញ្ហាពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្ដី មិនត្រូវបានលើកឡើងឡើយក្នុងចំណោមជនជាប់ចោទទាំង ៧៧៤ នាក់។ នេះមានន័យថា សិទ្ធិនេះទំនងជាត្រូវបានគោរពក្នុងចំណោមចំនួន ១០០% នៃជនជាប់ចោទ។ |

## ៣.២. សិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣១៧ | មាត្រា ៧ |

[58] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៤។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលកម្រងមេរៀនរបស់ ម. ស.ម.ក "សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្ដី និងសិទ្ធិនិយាយជាមួយមេធាវី" (ខែកញ្ញា ឆ្នាំ ២០២២) https://sithi.org/km/fair-trial-rights/the-right-to-adequate-time-and-facilities-to-prepare-a-defense-and-the-right-to-speak-with-a-lawyer ។

### *តួលេខទី ៥៖ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ*[59]




សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ មានន័យថា សេចក្តីសម្រេចដែលបានបំពេញតាមនីតិវិធីច្បាប់ត្រូវតែធ្វើឡើងជាសាធារណៈ។ សិទ្ធិនេះ មានសារៈសំខាន់ក្នុងការធានានូវតម្លាភាព និងគណនេយ្យភាព។[60] យោងតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.ន ទោះបីជានៅពេលដែលសាធារណជនមិនត្រូវបានឱ្យចូលរួមក្នុងសវនាការក៏ដោយ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុ ត្រូវតែបង្ហាញជាសាធារណៈ។[61] មានករណីលើកលែងមួយចំនួនប៉ុណ្ណោះចំពោះវិធានច្បាប់នេះ ដូចជានៅពេលដែលផលប្រយោជន៍របស់កុមារ មិនតម្រូវឱ្យប្រកាសសេចក្តីសម្រេចជាសាធារណៈឡើយ។[62]

នៅអំឡុងពេលធ្វើរបាយការណ៍នេះ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈត្រូវបានគោរពដោយតុលាការចំនួនបីក្នុងចំណោមតុលាការទាំងបួននៅគ្រប់សំណុំរឿងទាំងអស់ សម្រាប់ព័ត៌មានដែលទទួលបាន (ចំនួន ១៣៥ សំណុំរឿង)។

ម.ស.ម.ក អាចបានស្តាប់សាលដីកាចំនួនមួយប៉ុណ្ណោះនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ទោះបីជាសាលដីកានេះបានប្រកាសជាសាធារណៈក៏ដោយ ម.ស.ម.ក មិនអាចវាយតម្លៃបានថា តុលាការបានគោរពតាមសិទ្ធិនេះជាប់លាប់ដែរ ឬទេនៅឆ្នាំ២០២២ ដោយហេតុថាកង្វះទិន្នន័យអំពីសំណុំរឿងនៅសល់ផ្សេងទៀតចំនួន ៦១ ដែលបានសង្កេត។

---

[59] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុប ៥២១ សំណុំរឿង ដែលបានសង្កេតនៅឆ្នាំ២០២២។ "មិនដឹង" សំដៅលើសំណុំរឿងដែលមិនទទួលបានព័ត៌មាន ឬសំណុំរឿងដែលមិនបានតាមដាន ដោយសារតែអ្នកសង្កេតការណ៍សវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

[60] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-a-public-judgment-and-the-right-to-a-reasoned-judgment ។

[61] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[62] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

# ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដោយតុលាការមួយចំនួន

## ៤.១. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធី | ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ |
| មាត្រា ១៤(១) | មាត្រា ៣៩២ | មាត្រា ៧ |

*ការធានានៅក្នុងករណីសវនាការជាអសាធារណៈ*

ទោះបីជាសាធារណជនទាំងអស់ ឬផ្នែកខ្លះនៃសាធារណជនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការដោយសារកាលៈទេសៈពិសេសក៏ដោយ ក៏នៅតែមានការធានាដល់សាធារណភាពផងដែរ។ ក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ ភស្តុតាង និងសំអាងហេតុច្បាប់ត្រូវតែធ្វើជាសាធារណៈ។[63] មានតែក្នុងករណីមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍៖ ប្រសិនបើមានភាពចាំបាច់ដើម្បីជាប្រយោជន៍របស់កុមារ) ទើបអាចមានការលើកលែងចំពោះការធានានូវសាធារណភាពនេះ។

ជនគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងការជំនុំជម្រះជាសាធារណៈ[64] លើកលែងតែក្នុងកាលៈទេសៈពិសេសមួយចំនួន។ ក្នុងចំណោមហេតុផលដែលអាចជំរុញឱ្យតុលាការបង្គាប់ឱ្យមានដំណើរការសវនាការជាអសាធារណៈទាំងស្រុង ឬដោយផ្នែក ជាហានិភ័យដែលថាសវនាការជាសាធារណៈអាចបណ្តាលឱ្យមាន "ការប៉ះពាល់យ៉ាងខ្លាំង" ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬសីលធម៌ ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី (ជាពិសេស ក្នុងសំណុំរឿងរំលោភផ្លូវភេទមួយចំនួន) ឬវត្តមានរបស់កុមារទំនាស់នឹងច្បាប់។[65]

---

[63] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[64] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ" (ខែកញ្ញា ឆ្នាំ២០២២)។ https://sithi.org/km/fair-trial-rights/the-right-to-a-public-hearing ។

[65] គណៈកម្មាធិការសិទ្ធិកុមារអង្គការសហប្រជាជាតិ ("គណៈកម្មាធិការសិទ្ធិកុមារ) សេចក្តីពន្យល់ទូទៅលេខ ២៤ ស្តីពីសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ (ជំនួសសេចក្តីពន្យល់ទូទៅលេខ ១០ (ឆ្នាំ២០០៧)) (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩) CRC/C/GC/២៤ វាក្យខណ្ឌ ៦៧ http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2FPPRiCAqhKb7yhsqIkirKQZLK2M58RF%2F5F0vEnG3QGKUxFivhToQfjGxYjV05tUAIgpOwHQJsFPdJXCiixFSrDRwow8HeKLLh8cgOw1SN6vJ%2Bf0RPR9UMtGkA4 ("គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤")។

មានតែនៅក្នុងកាលៈទេសៈពិសេសដែលច្បាប់កំណត់ប៉ុណ្ណោះ ទើបសាធារណជនទាំងអស់ ឬមួយផ្នែកមិនអាចត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការបាន។ [66] ក្នុងកាលៈទេសៈផ្សេងទៀត សវនាការត្រូវតែធ្វើជាសាធារណៈ រួមទាំងសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយផងដែរ ហើយមិនអាចផាត់ចេញនូវក្រុមមនុស្សជាក់លាក់ណាមួយឡើយ។ [67] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងពេលវេលា និងទីកន្លែងសម្រាប់សវនាការផ្ទាល់មាត់ទៅដល់សាធារណជន និងផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងកម្រិតសមរម្យ។[68]

***តួលេខទី ៦៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ***[69]







ការបិទកាលវិភាគសវនាការ ដែលបង្ហាញអំពីកាលបរិច្ឆេទ ទីតាំង និងពេលវេលាចាប់ផ្តើមសវនាការនៅខាងក្រៅបន្ទប់សវនាការ ឬផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត គឺជាមធ្យោបាយមួយក្នុងការផ្សព្វផ្សាយអំពីសវនាការជាសាធារណៈ តាមរយៈការជូនដំណឹងដល់សាធារណជនអាចចូលទៅកាន់បន្ទប់សវនាការនោះបាន។ នៅក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍ មិនមានការបង្ហាញថាសាធារណជន ឬប្រព័ន្ធផ្សព្វផ្សាយត្រូវបានរាំងមិនឱ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការនោះទេ។ កាលវិភាគសវនាការ ត្រូវបានបិទផ្សាយ ៧៣,១% នៃការជំនុំជម្រះដែលបានសង្កេត (ចំនួន ៣៨១ ក្នុងចំណោម

[66] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩

[67] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩

[68] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨, គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ២១៥/១៩៨៦, Van Meurs ទល់នឹង ប្រទេសហូឡង់ (ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០) CCPR/C/៣៩/D/២១៥/១៩៨៦, វាក្យខណ្ឌ ៦.២, http://juris.ohchr.org/Search/Details/311 ។

[69] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុបចំនួន ៥២១ ដែលបានសង្កេត។

៥២១ សំណុំរឿង) គឺមានការបិទផ្សាយនៅលើក្តារព័ត៌មានជាសាធារណៈនៅខាងក្រៅបន្ទប់សវនាការ និង/ឬនៅលើប្រព័ន្ធអ៊ីនធឺណិត។ ទោះជាយ៉ាងនេះក្តី ក៏មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយផងដែរ។

*តួលេខទី ៧៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈតាមតុលាការនីមួយៗ*[70]




នៅឆ្នាំ២០១៧ និងឆ្នាំ២០១៨ សាលាឧទ្ធរណ៍**ភ្នំពេញ**[71] បានទទួលស្គាល់ថា មានចំណុចកង្វះខាតមួយចំនួនពាក់ព័ន្ធនឹងការជូនដំណឹងអំពីសវនាការទាក់ទងនឹងកាលវិភាគរបស់តុលាការ ព្រមទាំងបានប្រាប់ដល់ ម.ស.ម.ក ថានឹងចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីសវនាការ និងងាយស្រួលក្នុងការចូលរួមសវនាការ។ នៅឆ្នាំ២០១៩ តុលាការបានបញ្ជាក់ថា ការបិទកាលវិភាគសវនាការជាសាធារណៈ គឺជាបញ្ហារដ្ឋបាល និងមិនបានតម្រូវដោយច្បាប់នោះទេ។ ទោះបីជាយ៉ាងនេះក្តី តុលាការបានផ្តល់អាទិភាពលើបញ្ហានេះ និងបានបង្កើត គេហទំព័រ មួយដើម្បីបង្ហោះព័ត៌មានអំពីសំណុំរឿងនាពេលខាងមុខ ក៏ដូចជា កាលវិភាគសវនាការ ផងដែរ។ ព័ត៌មានដែលអាចស្វែងរកបាននាពេលនេះ រួមមានដូចជា កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ លេខសំណុំរឿង បទចោទប្រកាន់ និងឈ្មោះរបស់ចៅក្រម។ ទោះបីជាមានកិច្ច

---

[70] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿងសរុប ៥២១ ដែលបានសង្កេត។

[71] នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញដែលមានក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៦/ ២០១៧ និង ឆ្នាំ២០១៧/២០១៨។

ខិតខំប្រឹងប្រែងទាំងនេះក្ដី ក៏តុលាការមិនបានបិទផ្សាយអំពីកាលវិភាគសវនាការមួយចំនួនដែរ ដែលស្មើនឹងមួយភាគបី (៣២,៣%) ក្នុងចំណោមសំណុំរឿងដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍។ កង្វះការជូនដំណឹងអំពីកាលវិភាគសវនាការនេះ គឺជាការបារម្ភមួយចាប់តាំងពីឆ្នាំ២០១៣ មកម្ល៉េះ ហើយចាំបាច់គួរមានវិធានការបន្ថែមទៀតដើម្បីដោះស្រាយបញ្ហាខ្វះខាតនេះ ដើម្បីធានាបានថាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈត្រូវបានគោរពពេញលេញ។

សាលាឧទ្ធរណ៍**បាត់ដំបង** បានផ្សព្វផ្សាយជាសាធារណៈអំពីកាលវិភាគសវនាការចំនួន ៩៣,៧% នៃសវនាការដែល ម.ស.ម.ក បានសង្កេត (ចំនួន ១៣៤ ក្នុងចំណោម ១៤៣ សំណុំរឿង)។ ការជូនដំណឹងអំពីកម្មវិធីសវនាការចំនួន ៨៤,៣% (១១៣ ក្នុងចំណោម ១៣៤ សំណុំរឿង) បានបិទផ្សាយនៅលើក្ដារខៀនព័ត៌មានជាសាធារណៈ និង ៤៥,៥% (៦១ ក្នុងចំណោម ១៣៤ សំណុំរឿង) បានផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត។ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់នោះ គឺតុលាការអនុវត្តល្អក្នុងការផ្សព្វផ្សាយកាលវិភាគសវនាការទាំងនៅលើប្រព័ន្ធអ៊ីនធឺណិត និងនៅលើក្ដារព័ត៌មាន មានតែ ២៩,៨% ដែលចំនួននេះតិចជាងមួយភាគបីនៃសំណុំរឿងដែលបានបិទផ្សាយ។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការបានទទួលស្គាល់ថា កាលវិភាគសវនាការមិនបានបិទផ្សាយនៅលើក្ដារខៀនព័ត៌មានរបស់តុលាការនោះជាទៀងទាត់ទេ តែយ៉ាងណាតុលាការនឹងពង្រឹងលើការងារនេះ។[72] ជាលទ្ធផល ការផ្សព្វផ្សាយកាលវិភាគសវនាការកើនឡើងគួរកត់សម្គាល់។

សាលាឧទ្ធរណ៍**ត្បូងឃ្មុំ** បានអនុវត្តល្អប្រសើរជាងគេនៅក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដោយបានបិទផ្សាយការជូនដំណឹងអំពីកាលវិភាគសវនាការចំនួន ៩៦,៨% នៃសំណុំរឿងដែលបានសង្កេត (ចំនួន ៦០ ក្នុងចំណោម ៦២ សំណុំរឿង)។ ចំនួន ៨៥% បានបិទផ្សាយទាំងនៅលើប្រព័ន្ធអ៊ីនធឺណិតនិងនៅលើក្ដារខៀនព័ត៌មាន ហើយចំនួន ១៥% ទៀតគឺផ្សព្វផ្សាយតែនៅលើប្រព័ន្ធអ៊ីនធឺណិតប៉ុណ្ណោះ។

សាលាឧទ្ធរណ៍**ព្រះសីហនុ**មិនបានបិទផ្សាយអំពីកាលវិភាគសវនាការ នៅក្នុងសំណុំរឿងចំនួន ៧៨% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត (ចំនួន ៤៦ ក្នុងចំណោម ៥៩ សំណុំរឿង)។ សាលាឧទ្ធរណ៍នេះមិនបានផ្សព្វផ្សាយអំពីកាលវិភាគសវនាការនៅលើប្រព័ន្ធអ៊ីនធឺណិតទេ ដោយមានតែការបិទផ្សាយលើក្ដារខៀនព័ត៌មាននៅក្រៅបន្ទប់សវនាការក្នុងសំណុំរឿងចំនួន ១៣ (២២%) ប៉ុណ្ណោះ។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមប្រធានតុលាការបានទទួលស្គាល់អំពីការអនុវត្តមិនទាន់ពេញលេញនេះ ហើយថានឹងធ្វើឱ្យប្រសើរឡើងនូវកង្វះខាតនេះ។ ឯកឧត្តមក៏បានណែនាំឱ្យសហការីចាប់ផ្ដើមផ្សព្វផ្សាយអំពីកម្មវិធីសវនាការនៅលើទំព័រហ្វេសប៊ុក

[72] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

(Facebook) របស់តុលាការផងដែរ។[73] ទោះជាយ៉ាងនេះក្តី វិធានការនេះនៅមិនទាន់បានអនុវត្តនៅឡើយទេ នៅពេលធ្វើសេចក្តីព្រាងរបាយការណ៍នេះ។ ខែកញ្ញា ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា ការជំនុំជម្រះជាសាធារណៈសំដៅដល់ការជំនុំជម្រះដែលធ្វើនៅក្នុងសាលសវនាការ និងបើកចំហទទួលសាធារណជនគ្រប់រូបចូលរួមមើល ស្តាប់ សង្កេត មិនមែនសំដៅដល់ការបិទផ្សាយកាលវិភាគសវនាការលើប្រព័ន្ធអនឡាញ ឬក្តារព័ត៌មានទេ។ ការបិទផ្សាយកាលវិភាគគ្រាន់តែជាបែបបទរដ្ឋបាលដែលជួយសម្រួលដល់បុគ្គលគ្រប់រូបដែលមានបំណងចង់ចូលមើល និងស្តាប់ការជំនុំជម្រះប៉ុណ្ណោះ។[74]

## ៤.២. សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ស.ស.ស.ម | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (៣) (ក) និង(ច) | មាត្រា ៣២២, ៣២៥, ៣៣០, ៣៣១ និង ៣៩៦ | មាត្រា ៦ និង៥១ |

ជនជាប់ចោទបទព្រហ្មទណ្ឌ ត្រូវទទួលបានការជូនដំណឹង "ភ្លាមៗ" អំពីប្រភេទនៃបទល្មើស ដែលបានចោទប្រកាន់មកលើពួកគេ។ ចៅក្រមមានកាតព្វកិច្ចផ្តល់ការពន្យល់ឱ្យបានគ្រប់គ្រាន់ និងធានាថាជនជាប់ចោទបានដឹងអំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើពួកគេ ធ្វើដូច្នេះទើបពួកគេអាចរៀបចំការការពារក្តីបានត្រឹមត្រូវ។[75] ព័ត៌មានទាក់ទងនឹងការចោទប្រកាន់ត្រូវតែផ្តល់ជូនភ្លាមៗនៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានកំណត់ជាសាធារណៈថាជាជនជាប់ចោទ។ ការជូនដំណឹងនេះអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ (លុះត្រាតែមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរនៅពេលក្រោយ) ឬជាលាយលក្ខណ៍អក្សរ ដែលព័ត៌មានបង្ហាញទាំងអង្គច្បាប់ និងអង្គហេតុទូទៅសម្រាប់ជាមូលដ្ឋាននៃការចោទប្រកាន់។[76]

---

[73] នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[74] លិខិតលេខ ១៩១៩ រប-ឧ/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[75] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-informed-of-the-nature-and-causes-of-the-charges ។

[76] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦០៩/១៩៩៥, Nathaniel Williams និងចាម៉ៃកា (ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧) CCPR/C/៦១/D/៦០៩/១៩៩៥ ដែលក្នុងនោះគណៈកម្មា

គួរកត់សម្គាល់ថា អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យនៅពេលចាប់ផ្តើមសវនាការរបស់សាលាឧទ្ធរណ៍ ខណៈពេលដែលជនជាប់ចោទបានដឹងច្បាស់រួចហើយអំពីបទចោទប្រកាន់មកលើពួកគេ។ ទោះបីជាយ៉ាងនេះក្តី ប្រការនេះមានសារៈសំខាន់សម្រាប់ចៅក្រមដើម្បីរំឭកជនជាប់ចោទអំពីព័ត៌មាននេះ និងដើម្បីធានាថា ជនជាប់ចោទយល់ដឹងអំពីព័ត៌មាននេះ ជាពិសេសក្នុងករណីដែលការចោទប្រកាន់អាចមានការប្តូរ ឬកែប្រែនៅ ចន្លោះពេលឃាត់ខ្លួន/ការចោទប្រកាន់ដំបូង និងការជំនុំជម្រះជាក់ស្តែង។ បន្ថែមលើនេះ មាត្រា ៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា វិធានដែលអនុវត្តចំពោះមុខតុលាការជាន់ដំបូងត្រូវយកមកអនុវត្តចំពោះមុខសាលាឧទ្ធរណ៍។

*តួលេខទី ៨៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់*[77]




ក្នុងសំណុំរឿងចំនួន ៥៩,៧% (ចំនួន ៣១១ ក្នុងចំណោម ៥២១ សំណុំរឿង) នៃសំណុំរឿងទាំងអស់ដែល ម.ស.ម.ក បានសង្កេត គឺថាចៅក្រមបានអានប្រាប់ដល់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់លើពួកគេ។ ទោះបីជាយ៉ាងនេះក្តី សំណុំរឿងស្ទើរតែមួយភាគបី (៣០,៣%) ដែលចៅក្រមមិនបានអានប្រាប់ដល់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ពួកគេ ហើយក្នុងសំណុំរឿងចំនួន ៥២ (១០%) ជនជាប់ចោទមិនត្រូវបានអានប្រាប់អំពីបទចោទប្រកាន់មកលើខ្លួនទាល់តែសោះ។ ជាថ្មីម្តងទៀត តួលេខនេះក៏មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយផងដែរ។ ប៉ុន្តែ អ្វីដែលគួរកត់សម្គាល់នោះគឺថាជនជាប់ចោទទាំងអស់សុទ្ធតែមានអ្នកបកប្រែនៅពេលត្រូវការចាំបាច់។

សាលាឧទ្ធរណ៍**ភ្នំពេញ** គ្រាន់តែបានអានប្រាប់ដល់ជនជាប់ចោទអំពីការចោទប្រកាន់ពាក់ព័ន្ធទាំងអស់លើពួកគេ ក្នុងចំណោមសំណុំរឿងចំនួន ៤៧,៩% ដែល ម.ស.ម.ក បានសង្កេត (ចំនួន ១២៣ ក្នុងចំណោម

---

ធិការបានបញ្ជាក់បន្ថែមថា ព័ត៌មានលម្អិតអំពីបទចោទប្រកាន់ត្រូវតែផ្តល់ជូន។ នៅពេលចាប់ផ្តើមការស៊ើបអង្កេតបឋម ឬនៅពេលកំណត់សវនាការមួយចំនួនផ្សេងទៀត ដែលនាំទៅដល់ការសង្ស័យជាផ្លូវការយ៉ាងច្បាស់ចំពោះជនជាប់ចោទ"។

[77] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៥២១ ដែលបានសង្កេតនៅឆ្នាំ២០២២។

២៥៧ សំណុំរឿង) ពោលគឺធ្លាក់ចុះពី ៨៩,៤% នៅឆ្នាំ២០២១។ ជនជាប់ចោទភាគច្រើន (៥១%) ត្រូវបានអានប្រាប់តែបទចោទប្រកាន់មួយចំនួនលើពួកគេប៉ុណ្ណោះ។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ចៅក្រមមិនបានអានប្រាប់ជនជាប់ចោទភាគច្រើនទាក់ទងនឹងច្បាប់ពាក់ព័ន្ធ ហើយមានប្រាប់តែក្នុងសំណុំរឿងចំនួន ១០០ នៃសំណុំរឿងដែលបានសង្កេត (៣៨,៩%)។ លើសពីនេះ ចៅក្រមមិនបានអានប្រាប់អំពីទីកន្លែង និងកាលបរិច្ឆេទនៃបទល្មើសនៅក្នុងសំណុំរឿងចំនួន ១៥,៦% ហើយ ១០,៥% នៃសំណុំរឿងដែលបានសង្កេតកាលពីឆ្នាំកន្លងមក។ គួរបញ្ជាក់ថា ព័ត៌មានសំខាន់ទាំងនេះ គឺត្រូវផ្តល់ឱ្យបានលម្អិតដល់ជនជាប់ចោទនៅអំឡុងពេលសវនាការ។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញមានប្រសាសន៍ថា តុលាការនឹងធ្វើឱ្យប្រសើរឡើងពាក់ព័ន្ធនឹងការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទដើម្បីយល់អំពីសំណុំរឿងរបស់គេ។[78]

ស្រដៀងគ្នានេះដែរ សាលាឧទ្ធរណ៍**បាត់ដំបង** មិនបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ៣២,២% នៃសំណុំរឿងដែលបានសង្កេត (៤៦ ក្នុងចំណោម ១៤៣) ហើយបានអានប្រាប់តែបទចោទប្រកាន់មួយចំនួននៅក្នុងសំណុំរឿងចំនួន ២៣ (១៦,១%)។ ដូច្នេះ ជនជាប់ចោទលើសពាក់កណ្តាល (៥១,៧%) ត្រូវបានអានប្រាប់អំពីបទចោទប្រកាន់ទាំងអស់ដល់ពួកគេ។ ចៅក្រមមិនបានអានប្រាប់អំពីច្បាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ១០៥ ដែលបានសង្កេត (៧៣,៤%) ហើយសំណុំរឿងប្រហែលជាមួយភាគបីចៅក្រមមិនបានអានប្រាប់អំពីទីកន្លែង និងកាលបរិច្ឆេទនៃបទល្មើស និងភាគីពាក់ព័ន្ធនោះទេ (សូមមើលតារាងខាងក្រោម)។

សាលាឧទ្ធរណ៍**ត្បូងឃ្មុំ** និងសាលាឧទ្ធរណ៍**ព្រះសីហនុ** បានអនុវត្តល្អប្រសើរជាងគេនៅក្នុងការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដោយចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់នៅក្នុងសំណុំរឿង ៩៦,៨% នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំនិង ៩១,៥% នៅសាលាឧទ្ធរណ៍ព្រះសីហនុ ដែល ម.ស.ម.ក បានសង្កេត ហើយសំណុំរឿងភាគច្រើនចៅក្រមបានអានប្រាប់ជាប្រចាំអំពីទីកន្លែង និងកាលបរិច្ឆេទនៃបទល្មើស និងភាគីពាក់ព័ន្ធនៅក្នុងសំណុំរឿងដែលបានសង្កេត ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះ ចៅក្រមនៅសាលាឧទ្ធរណ៍ខេត្តព្រះសីហនុមិនបានអានប្រាប់អំពីច្បាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ១០,២% ខណៈដែលសាលាឧទ្ធរណ៍ត្បូងឃ្មុំមានតែ ៤,៨% ប៉ុណ្ណោះ។ ហេតុដូច្នេះ គួរមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាការគោរពពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។ ខែកញ្ញា ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថា នីតិវិធីប្រាប់បទចោទប្រកាន់គឺធ្វើនៅចំពោះមុខចៅក្រមស៊ើបសួរ បន្ទាប់ពីព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ដើម្បីបើកការស៊ើបសួរ មិនធ្វើចំពោះមុខសាលាឧទ្ធរណ៍ទេ។ សាលា

[78] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

ឧទ្ធរណ៍មានសមត្ថកិច្ចសម្រេចពីបណ្ដឹងឧទ្ធរណ៍ ដែលធ្វើប្រឆាំងនឹងសេចក្ដីសម្រេចរបស់តុលាការជាន់ដំបូង ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។ នៅចំពោះមុខសាលាឧទ្ធរណ៍ នៅពេលសួរដេញដោល បន្ទាប់ពីចៅក្រម ប្រកាសបើក និងអានរបាយការណ៍ ក៏ដូចជាប្រាប់សិទ្ធិជនជាប់ចោទ និងបុគ្គលដែលពាក់ព័ន្ធរួច សំណួរទី១ ដែលចៅក្រមជាប្រធានក្រុមប្រឹក្សាជំនុំជម្រះតែងតែសួរទៅលើជនជាប់ចោទគឺ «តើជនជាប់ចោទមិនសុខចិត្ត នឹងសេចក្ដីសម្រេចរបស់សាលាដំបូងនឹងចំណុចណា? ហេតុអ្វី?»។ ជាទូទៅ ចម្លើយដែលត្រឡប់មកវិញមាន តែ ០១ ក្នុងចំណោម ០២។ ទី១ ខ្ញុំមិនសុខចិត្ត ពីព្រោះខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងទី២ ទោស ដែលសម្រេចធ្ងន់ពេក។ ដូចនេះ នៅចំពោះមុខសាលាឧទ្ធរណ៍ពុំមាននីតិវិធីណាដែលចែងជាកាតព្វកិច្ចថា ត្រូវ អានបទចោទប្រកាន់ និងមូលហេតុនៃការចោទប្រកាន់ប្រាប់ទៅជនជាប់ចោទនោះទេ ប៉ុន្តែបើសិនជនជាប់ចោទ និយាយថា ខ្លួនមិនដឹង នោះចៅក្រមតែងតែប្រាប់ និងពន្យល់ ចៅក្រមមិនអាចសួរជនជាប់ចោទដែលមិនដឹង និងមិនយល់នោះបានទេ។[79]

*តួលេខទី ៩៖ សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់*[80]

| កម្រងសំណួរ | សាលាឧទ្ធរណ៍ភ្នំពេញ | | សាលាឧទ្ធរណ៍បាត់ដំបង | | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | | សាលាឧទ្ធរណ៍ព្រះសីហនុ | |
|---|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន | មាន | គ្មាន |
| តើមានការចាត់តាំងអ្នកបកប្រែដែរឬទេ ប្រសិនបើមានការចាំបាច់? | ១៤<br>១០០% | ០<br>០% | ១<br>១០០% | ០<br>០% | ១<br>១០០% | ០<br>០ % | ១២<br>១០០% | ០<br>០% |
| តើចៅក្រមបានអានប្រាប់ពីភាគីពាក់ព័ន្ធដែរឬទេ? | ២៤៥<br>៩៥,៣% | ១២<br>៤,៧% | ៩៩<br>៦៩,២% | ៤៤<br>៣០,៨% | ៦១<br>៩៨,៤% | ១<br>១,៦% | ៥៩<br>១០០% | ០<br>០% |
| តើចៅក្រមបានអានប្រាប់ពីទីកន្លែងដែលបទល្មើសកើតឡើងដែរឬទេ? | ២១៧<br>៨៤,៤% | ៤០<br>១៥,៦% | ៩៣<br>៦៥% | ៥០<br>៣៥% | ៦១<br>៩៨,៤% | ១<br>១,៦% | ៥៧<br>៩៦,៦% | ២<br>៣,៤% |
| តើចៅក្រមបានអានប្រាប់អំពីកាលបរិច្ឆេទដែលបទល្មើសកើតឡើងដែរឬទេ? | ២៣០<br>៨៩,៥% | ២៧<br>១០,៥% | ៩១<br>៦៣,៦% | ៥២<br>៣៦,៤% | ៦១<br>៩៨,៤% | ១<br>១,៦% | ៥៧<br>៩៦,៦% | ២<br>៣,៤% |
| តើចៅក្រមបានអានប្រាប់ពីច្បាប់ពាក់ព័ន្ធដែរឬទេ? | ១០០<br>៣៨,៩ % | ១៥៧<br>៦១,១ % | ៣៨<br>២៦,៦ % | ១០៥<br>៧៣,៤% | ៥៩<br>៩៥,២% | ៣<br>៤,៨% | ៥៣<br>៨,៨% | ៦<br>១០,២% |

[79] លិខិតលេខ ១៩១៩ រប-ឧ/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ របស់ ម.ស.ម.ក។

[80] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៥២១ ដែលបានសង្កេតនៅឆ្នាំ២០២២។

## ៤.៣. សិទ្ធិមានវត្តមាននៅពេលសវនាការ[81]

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន | ច្បាប់ស្តីពីពន្ធនាគារ[82] |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ១៤៣, ៣០០, ៣០១, និង៣៨៩ | មាត្រា ៦, ៥០ និង ៥១ | មាត្រា ៦២ |

ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ[83] ដោយសារតែការធ្វើបែបនេះផ្តល់ឱកាសឱ្យពួកគេបានស្តាប់ និងឆ្លើយតបទៅនឹងភស្តុតាងដែលដាក់បន្ទុកលើពួកគេ និងអាចការពារខ្លួនបាន។ ចំពោះកុមារទំនាស់នឹងច្បាប់វិញ សវនាការត្រូវមានវត្តមាន "មេធាវី ឬជំនួយការផ្នែកច្បាប់សមស្របផ្សេងទៀត"[84] និងវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ឬអ្នកមើលថែផ្សេងទៀត លុះត្រាតែមានការរកឃើញថាប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់កុមារ ឬតាមការស្នើសុំមិនចូលរួមសវនាការរបស់កុមារ។[85] សិទ្ធិមានវត្តមាននៅពេលសវនាការអាចអនុវត្តបានចំពោះដំណើរការបណ្តឹងតវ៉ា ប្រសិនបើពាក់ព័ន្ធនឹងបញ្ហានៃអង្គហេតុ និងអង្គច្បាប់[86] ដែលជាករណីកើតឡើងនៅកម្ពុជា។ ការជំនុំជម្រះដោយកំបាំងមុខ ពោលគឺអវត្តមានជនជាប់ចោទ គឺអាចអនុញ្ញាតបានតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ នៅក្នុងកាលៈទេសៈពិសេស និងនៅពេលដែលជាប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។[87] យុត្តិកម្មច្បាស់លាស់ត្រូវតែផ្តល់ឱ្យពួកគេ។[88] ជនជាប់ចោទក៏អាចលះបង់សិទ្ធិមានវត្តមានក្នុងសវនាការបានផងដែរ។[89]

---

[81] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិទាំងនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសិទ្ធិមានមេធាវី" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-present-at-trial-and-the-right-to-defend-oneself-in-person-or-through-legal-representation ។

[82] "ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា" http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Prison%20law%202011%20-%20ENG%20(unofficial%20translation).pdf ។

[83] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

[84] គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅ លេខ ២៤ វាក្យខណ្ឌ ៦៣។

[85] គណៈកម្មាធិការអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅ លេខ ២៤ វាក្យខណ្ឌ ៥៦។

[86] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣៨៧/១៩៨៩, Karttunen ទល់នឹង ប្រទេសហ្វាំងឡង់ (ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩២) CCPR/C/៤៦/D/៣៨៧/១៩៨៩ វាក្យខណ្ឌ ៧.៣ http://juris.ohchr.org/Search/Details/402។

[87] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

[88] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ០១៦/១៩៧៧, Mbenge ទល់នឹង ប្រទេសហ្សាអៀ (ថ្ងៃទី២៥ ខែមីនា ឆ្នាំ ១៩៨៣) CCPR/C/១៨/D/១៦/១៩៧៧ វាក្យខណ្ឌ ១៤.១, http://juris.ohchr.org/Search/Details/573។

[89] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦។

*តួលេខទី ១០៖ សិទ្ធិមានវត្តមាននៅពេលសវនាការ* [90]




នៅអំឡុងពេលធ្វើរបាយការណ៍នេះ ជនជាប់ចោទចំនួន ៦០៤ នាក់ (៨៣,៤%) ក្នុងចំណោមជនជាប់ចោទ ៧២៤ នាក់មានវត្តមាននៅពេលសវនាការ។ ទោះបីជាតួលេខនេះមានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយក្តី ម.ស.ម.ក បានរកឃើញថា តុលាការចំនួនបីក្នុងចំណោមតុលាការទាំងបួនបានគោរពនូវសិទ្ធិមានវត្តមាននៅពេលសវនាការ។

ភាគរយនៃជនជាប់ចោទដែលមានវត្តមាននៅពេលសវនាការរបស់ខ្លួននៅសាលាឧទ្ធរណ៍**ភ្នំពេញ** មានចំនួន ៨១,៨% ដែលថយចុះពី ៨៣,១% នៅឆ្នាំ២០២១ ហើយចំនួន ៩០,២% នៅឆ្នាំ២០១៩/២០២០។ តួលេខនេះបង្ហាញអំពីការថយចុះ ខណៈដែលមានចំនួន ៨២,៥% នៅឆ្នាំ២០១៧/២០១៨។ នៅអំឡុងពេលធ្វើរបាយការណ៍ពីមុន អវត្តមានរបស់ជនជាប់ចោទជារឿយៗ គឺដោយសារតែបញ្ហាភស្តុភារ ព្រមទាំងបញ្ហាទំនាក់ទំនងរវាងតុលាការ និងមន្ទីរឃុំឃាំង។ នៅក្នុងករណីជាច្រើន គឺមិនមានការដឹកជញ្ជូនជនជាប់ចោទមកនោះទេ ដោយសារតែតុលាការបានបញ្ជូនព័ត៌មានទៅខុសមណ្ឌលកែប្រែ ឬដោយសារតែមណ្ឌលកែប្រែមិនបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់តុលាការអំពីការផ្ទេរជនជាប់ឃុំទៅមណ្ឌលកែប្រែផ្សេងទៀត។ បញ្ហានេះចាំបាច់ត្រូវដោះស្រាយដោយការកែលម្អការធ្វើកំណត់ត្រា និងទំនាក់ទំនងរវាងតុលាការ និងមន្ទីរឃុំឃាំង។ តុលាការក៏បានពន្យល់ផងដែរថា តុលាការក៏អាចបើកសវនាការលើសំណុំរឿងដោយគ្មានវត្តមានរបស់ជនជាប់ចោទបាន ប្រសិនបើមេធាវីរបស់ពួកគេមានវត្តមាន, ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ, ប្រសិនបើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយអយ្យការ ឬប្រសិនបើសំណុំរឿងកកស្ទះនៅតុលាការអស់រយៈពេលជាយូរ ហើយភាគីស្នើសុំឱ្យចៅក្រមជំនុំជម្រះលើសំណុំរឿងនោះដោយគ្មានវត្តមានរបស់ជនជាប់ចោទ។[91]

[90] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៧២៤ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

[91] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក។

តួលេខស្រដៀងគ្នាត្រូវបានកត់ត្រានៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** ដែលមានជនជាប់ចោទ ៨១,៤% បានចូលរួមនៅក្នុងសវនាការដែល ម.ស.ម.ក បានសង្កេតសវនាការរបស់ខ្លួនក្នុងអំឡុងពេលធ្វើរបាយការណ៍។ នៅខែកញ្ញា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានបង្ហាញថា សិទ្ធិមានវត្តមានរបស់ជនជាប់ចោទមានសារៈសំខាន់ណាស់ ជាការអនុវត្តជាក់ស្តែងកន្លងមក តុលាការនៅតែបន្តកោះហៅជនជាប់ចោទពីបទឧក្រិដ្ឋឱ្យចូលរួមក្នុងសវនាការ ទោះបីជាជនជាប់ចោទនោះ បានបោះបង់សិទ្ធិមិនចូលរួមសវនាការជាមួយនឹងហេតុផលមួយចំនួនក៏ដោយ។[92]

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា ភាគរយនៃជនជាប់ចោទ ដែលមានវត្តមាននៅក្នុងដំណើរការជំនុំជម្រះក្តីនៅសាលាឧទ្ធរណ៍**បាត់ដំបង** មាន ៩១% ដែលជាតួលេខខ្ពស់ជាងគេបំផុតក្នុងចំណោមតុលាការទាំងបួន។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការ បានមានប្រសាសន៍ថា តុលាការចាត់វិធានការលើបញ្ហានេះយ៉ាងម៉ឺងម៉ាត់ ដោយសារតែវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ គឺជាធាតុដ៏ចម្បងមួយនៃលទ្ធភាពទទួលបានយុត្តិធម៌។ ឯកឧត្តមបានមានប្រសាសន៍បន្ថែមថា តុលាការតម្រូវឱ្យជនជាប់ចោទគ្រប់រូបមានវត្តមាន រួមទាំងជនជាប់ចោទដែលបានស្នើសុំមិនបង្ហាញខ្លួនផងដែរ។[93] ដោយឡែក នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** ដែលជាតួលេខនេះមានត្រឹម ៧៤,៧% ដែលទាបជាងគេបើធៀបនឹងតុលាការផ្សេង។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមប្រធានសាលាឧទ្ធរណ៍បានមានប្រសាសន៍ថា ទោះបីជាជនជាប់ចោទត្រូវបានអញ្ជើញឱ្យបង្ហាញខ្លួននៅក្នុងសវនាការក៏ដោយ ក៏មន្ត្រីពន្ធនាគារ មិនអាចនាំជនជាប់ចោទទាំងអស់មកបានទេ ដោយសារតែការរីតត្បិតនៃជំងឺកូវីដ-១៩។[94]

## ៤.៤. សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

| ច្បាប់អន្តរជាតិ | ច្បាប់ជាតិ |
|---|---|
| ក.អ.ស.ព.ន | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា១៤ (៣) (គ) | មាត្រា ៥៧ |

[92] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[93] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[94] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

មាត្រា ១៤(៣)(គ) នៃ ក.អ.ស.ព.ន ធានាថា ជនគ្រប់រូបដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវទទួលបានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ការពន្លឿននីតិវិធីគឺជាធាតុសារវន្តមួយនៃការជំនុំជម្រះដោយយុត្តិធម៌។ [95] ជាការបារម្ភដោយសារច្បាប់ជាតិមិនមានបទប្បញ្ញត្តិណាមួយចែងថាសាលាឧទ្ធរណ៍ត្រូវត្រូវចាត់ការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនក្នុងវេលាជាក់លាក់ឡើយសម្រាប់ជនជាប់ចោទជានីតិជន។ តែមាត្រា៩៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយកុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំ តុលាការត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ ខែយ៉ាងយូរ លើកលែងតែមានមូលហេតុសន្យានុម័តមិនអាចជម្នះបាន។ ម.ស.ម.ក នឹងចាត់ទុកថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេលត្រូវបានគោរព ប្រសិនតុលាការបានជំនុំជម្រះលើសំណុំរឿងរបស់គេក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍។ នៅអំឡុងពេលធ្វើរបាយការណ៍ មាន ៨២,៤% នៃសំណុំរឿងដែលបានសង្កេត មានព័ត៌មានទាក់ទិននឹងកាលបរិច្ឆេទនៃបណ្តឹងឧទ្ធរណ៍មកដល់សាលាឧទ្ធរណ៍ (៣០៤ សំណុំរឿងក្នុងចំណោម ៣៦៩) ហើយមានភាពខុសគ្នារវាងសាលាឧទ្ធរណ៍ភ្នំពេញនឹងសាលាឧទ្ធរណ៍ផ្សេងៗទៀត។

សវនាការដែលបានធ្វើឡើងក្នុងអំឡុងពេលតិចជាង ៦ ខែបន្ទាប់ពីទទួលបណ្តឹងឧទ្ធរណ៍មាន ៩៦,៤% នៅសាលាឧទ្ធរណ៍បាត់ដំបង (១៣៤ សំណុំរឿងក្នុងចំណោម ១៣៩), ៨៥,៥% នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ (៥៣ សំណុំរឿងក្នុងចំណោម ៦២), និង៩២,៣% នៅសាលាឧទ្ធរណ៍ព្រះសីហនុ (៤៨ សំណុំរឿងក្នុងចំណោម ៥២)។ គួរឱ្យសាទរចំពោះសាលាឧទ្ធរណ៍ទាំង ៣ ដែលមានចំណាត់ការលើសំណុំរឿងក្នុងរយៈពេល ១ ឆ្នាំ បន្ទាប់ពីទទួលបណ្តឹងឧទ្ធរណ៍ លើកលែងតែសំណុំរឿងចំនួន ១ ដែលលើសពី ១ ឆ្នាំ។ តាមការប្រៀបធៀបសំណុំរឿងនៅសាលាឧទ្ធរណ៍ភ្នំពេញដែលត្រូវបានលើកយកមកជំនុំជម្រះមាន ៧៧,៦% (៩០ សំណុំរឿងក្នុងចំណោម ១១៦) ធ្វើឡើងក្នុងរយៈពេល ១ ឆ្នាំ, ៥៩,៥% (៦៩ សំណុំរឿងក្នុងចំណោម ១១៦) សវនាការត្រូវបានធ្វើឡើងក្នុងរយៈពេលតិចជាង ៦ ខែ បន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍។ ចំពោះចំណុចនេះ គួរមានវិធានការបន្ថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើង និងអាចដោះស្រាយនូវការកកស្ទះសំណុំរឿង ដូច្នោះសិទ្ធិនេះមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយទេនៅសាលាឧទ្ធរណ៍ភ្នំពេញ។

*តួលេខទី ១១៖ រយៈពេលនៃចំណាត់ការលើបណ្តឹងឧទ្ធរណ៍ (គិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍របស់សាលាឧទ្ធរណ៍រហូតដល់ថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍)[96]*

| រយៈពេល | សាលាឧទ្ធរណ៍ភ្នំពេញ | សាលាឧទ្ធរណ៍បាត់ដំបង | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | សាលាឧទ្ធរណ៍ព្រះសីហនុ | សរុបសំណុំរឿង |
|---|---|---|---|---|---|

[95] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ២៧។

[96] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៥២១ ដែលបានសង្កេតនៅឆ្នាំ២០២២។

| | | | | | |
|---|---|---|---|---|---|
| តិចជាង ៦ ខែ | ៦៩ | ១៣៤ | ៥៣ | ៤៨ | ៣០៤ |
| ចន្លោះ ៦ ខែ ដល់ ១ ឆ្នាំ | ២១ | ៤ | ៩ | ៤ | ៣៨ |
| លើស ១ ឆ្នាំ ដល់ ២ ឆ្នាំ | ១៧ | ១ | ០ | ០ | ១៨ |
| លើស ២ ឆ្នាំដល់ ៣ ឆ្នាំ | ៥ | ០ | ០ | ០ | ៥ |
| លើសពី ៣ ឆ្នាំ | ៤ | ០ | ០ | ០ | ៤ |
| មិនមានទិន្នន័យ | ១៤១ | ៤ | ០ | ៧ | ១៥២ |
| **សរុបសំណុំរឿង** | **២៥៧** | **១៤៣** | **៦២** | **៥៩** | **៥២១** |

# ៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនទាន់ត្រូវបានគោរពពេញលេញ

## ៥.១. សិទ្ធិមានសេរីភាព

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | |
|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ |
| មាត្រា ៣ | មាត្រា ៩ (១) | មាត្រា ៣២<br>មាត្រា ៣៨ | មាត្រា ២០៣, ២០៤, ២០៥, ២០៨, ២០៩, ២១១ |

មាត្រា ៩(១) នៃ ក.អ.ស.ព.ន ធានានូវសេរីភាពរបស់ជនគ្រប់រូបពីការបង្ខាំងរូបរាងកាយ[97] មានន័យថាមិនត្រូវបានដកហូតសេរីភាពជារូបវន្តក្នុងការដើរហើរតាមបំណងប្រាថ្នានោះឡើយ។ [98] ប៉ុន្តែសិទ្ធិមានសេរីភាពនេះមិនមានលក្ខណៈដាច់ខាតឡើយ។

ដូច្នេះ បុគ្គលម្នាក់ៗអាចត្រូវបានដកហូតសេរីភាពដោយផ្អែកទៅលើមូលដ្ឋាននៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដូចជាការឃាត់ខ្លួននៅដំណាក់កាលនគរបាលយុត្តិធម៌ ការឃុំខ្លួនបណ្ដោះអាសន្ន ការដាក់ពន្ធនាគារបន្ទាប់ពីការកាត់ទោសជាដើម។ [99] ដោយសារតែសិទ្ធិមានសេរីភាពមានសារៈសំខាន់ដើម្បីការពារការសន្និតទុកជាមុនថាគ្មានទោស ដូច្នេះការដកហូតសេរីភាពណាមួយដែលធ្វើឡើងក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែត្រឹមត្រូវតាមច្បាប់ ពោលគឺត្រូវអនុវត្តទៅតាមនីតិវិធីដែលច្បាប់កំណត់ និងដោយការគោរពនីតិរដ្ឋ[100] និងមិនត្រូវធ្វើតាមអំពើចិត្តឡើយ ពោលគឺមិនត្រូវអនុវត្តដោយមិនត្រឹមត្រូវតាមច្បាប់ អយុត្តិធម៌ មិនមានសំអាងហេតុត្រឹមត្រូវ មិនមានភាពចាំបាច់ ឬមិនសមាមាត្រ។ ឧទាហរណ៍ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវប្រើប្រាស់ជាវិធានការដោះស្រាយជាជម្រើសចុងក្រោយតែប៉ុណ្ណោះ និងធ្វើឡើងនៅពេលមានការចាំបាច់ និងក្នុងកាលៈទេសៈពិសេសដែលច្បាប់កំណត់ប៉ុណ្ណោះ។

នៅអំឡុងពេលធ្វើរបាយការណ៍នេះ ជនជាប់ចោទចំនួន ៤១០ នាក់ក្នុងចំណោម ៧២៤ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតត្រូវបានឃុំខ្លួន លើសពីនេះជនជាប់ចោទទាំងអស់នៅតែត្រូវបានបន្តការឃុំខ្លួនក្នុងពន្ធនាគារដោយមិនមានការសម្រេចឱ្យជនជាប់ចោទបាននៅក្រៅឃុំនោះឡើយ ក្នុងចន្លោះពេល

---

97 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ ៣៥ វាក្យខណ្ឌ ៣។

98 សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិទាំងនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមរម្យ (ឬត្រូវដោះលែង និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល (ខែកញ្ញា ឆ្នាំ២០២២), https://sithi.org/km/fair-trial-rights/the-right-to-liberty-the-right-to-be-tried-within-reasonable-time-or-to-release-and-the-right-to-be-tried-without-undue-delay ។

99 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣៥ វាក្យខណ្ឌ ៥។

100 គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅ ៣៥ វាក្យខណ្ឌ ១០។

នៃបណ្តឹងឧទ្ធរណ៍ដល់សាលាឧទ្ធរណ៍ និងការរង់ចាំដល់ថ្ងៃប្រកាសសាលដីកា។ ជនជាប់ចោទចំនួនជាងពាក់កណ្តាល (៥៦,៦%) ស្ថិតនៅក្នុងការឃុំខ្លួន ខណៈដែលសិទ្ធិមានសេរីភាពនៅតែជាសិទ្ធិដ៏សំខាន់ ហើយការបន្តឃុំខ្លួនគួរជាវិធានការពិសេស ដែលប្រើប្រាស់ជាជម្រើសចុងក្រោយប៉ុណ្ណោះ។ ការសង្កេតសវនាការបានបង្ហាញឱ្យឃើញថា ជនជាប់ចោទលើសពីពីរភាគបី (៦៨,៣%) នៅក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍បាត់ដំបងត្រូវបានស្ថិតក្នុងការឃុំខ្លួន បើធៀបទៅនឹងជនជាប់ចោទនៅក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ភ្នំពេញ** (៥២%) សាលាឧទ្ធរណ៍**ត្បូងឃ្មុំ** (៥២,៣%) និងសាលាឧទ្ធរណ៍**ព្រះសីហនុ** (៥២,៩%)។

ជាការសំខាន់ណាស់ ការឃុំខ្លួនត្រូវអនុវត្តតែនៅក្នុងករណីលើកលែងប៉ុណ្ណោះ ហើយសិទ្ធិមានសេរីភាពរបស់ជនជាប់ចោទដែលនៅជាជនគ្មានទោសរហូតទាល់តែពិរុទ្ធភាពត្រូវបានបង្ហាញ ត្រូវតែគោរព។ គួរមានវិធានការដើម្បីធានាថា ជនជាប់ចោទដែលមានវត្តមានក្នុងពេលសវនាការ ឬពេលសេចក្តីសម្រេច តុលាការគួរពិចារណាវិធានការបន្ធូរបន្ថយជាងនេះ ដូចជាការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងករណីចាំបាច់ដែលអាចធ្វើបាន។ នៅខែសីហា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថាចំពោះសំណុំរឿងដែលមានជនជាប់ចោទនៅក្នុងពន្ធនាគារ ចៅក្រមតែងតែយកសំណុំរឿងនោះជាអាទិភាពនៃការបើកសវនាការមុនគេដូចបានបង្ហាញតាមទិន្នន័យខាងលើ ដែលនេះបង្ហាញពីការយកចិត្តទុករបស់តុលាការក្នុងចំណាត់ការឆាប់រហ័សផងដែរ។[101] ខែកញ្ញា ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យអមសាលាឧទ្ធរណ៍ព្រះសីហនុបានឆ្លើយតបថា ការឃុំខ្លួនបណ្តោះអាសន្នជានីតិវិធីនៅចំពោះមុខចៅក្រមស៊ើបសួរនៅដំណាក់កាលសាលាដំបូង ប៉ុន្តែលទ្ធផលនៃរបាយការណ៍នេះគឺចេញមកពីការសង្កេតសវនាការនៅចំពោះមុខសាលាឧទ្ធរណ៍ ហេតុនេះការលើកថា សិទ្ធិមានសេរីភាពមិនត្រូវបានគោរពពេញលេញដោយសារជនជាប់ចោទភាគច្រើនត្រូវបានឃុំខ្លួន ហាក់ដូចជាពុំសមហេតុផលទេ។ ជាគោលការណ៍ តុលាការគោរពគោលការណ៍នៃសិទ្ធិមានសេរីភាពរបស់បុគ្គល ដូចនេះ ការឃុំខ្លួនជនណាម្នាក់គឺជាជម្រើសចុងក្រោយរបស់ចៅក្រម។ ដើម្បីដឹងថា ការសម្រេចការឃុំខ្លួនជាជម្រើសចុងក្រោយ ឬមិនមែនទេ គឺចៅក្រមពិនិត្យមើលពីហេតុ និងផលដែលមានក្នុងសំអាងហេតុនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន មិនមែនមើលតែតួលេខបុគ្គលដែលជាប់ឃុំនោះទេ។ ដោយឡែក ចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល បើការឃុំខ្លួនបណ្តោះអាសន្ន គឺជាការពន្យារពេលជំនុំជម្រះនោះនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺល្មើសសិទ្ធិមនុស្សហើយ។[102]

---

[101] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[102] លិខិតលេខ ១៩១៩ រប-ឧ/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក។

## *តួលេខទី ១២៖ សិទ្ធិមានសេរីភាព*[103]







នៅក្នុងអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទចំនួន ៨៦ នាក់ ក្នុងចំណោម ១៩០ (៤៥,៣%) ដែលត្រូវបានដឹងពីកាលបរិច្ឆេទនៃការចាប់ និងឃុំខ្លួន បានស្ថិតក្នុងពន្ធនាគារចន្លោះពី ១ ដល់ ២ ឆ្នាំ គិតមកដល់ថ្ងៃជំនុំជម្រះលើសំណុំរឿងរបស់គេ។ ជាង ១ ភាគ ៣ នៃពួកគេ (៦៥ នាក់ក្នុងចំណោម ១៩០) បានជាប់ពន្ធនាគារតិចជាង១ឆ្នាំ ខណៈដែលមាន ១ នាក់ក្នុងចំណោម ៩ នាក់ គឺជាប់ពន្ធនាគារលើសពី ២ឆ្នាំ គិតមកដល់ថ្ងៃសវនាការលើសំណុំរឿងរបស់គេ។

## *តួលេខទី១៣៖ រយៈពេលនៃការឃុំខ្លួនគិតពីថ្ងៃឃុំខ្លួនបណ្តោះអាសន្នមកដល់ថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍*[104]

| ថិរវេលាឃុំខ្លួន | សាលាឧទ្ធរណ៍ ភ្នំពេញ | សាលាឧទ្ធរណ៍ បាត់ដំបង | សាលាឧទ្ធរណ៍ ត្បូងឃ្មុំ | សាលាឧទ្ធរណ៍ ព្រះសីហនុ | សរុប |
|---|---|---|---|---|---|
| តិចជាង ១ ឆ្នាំ | ១៥ | ២៤ | ១៨ | ៨ | ៦៥ |
| ១ ឆ្នាំ ដល់ ២ ឆ្នាំ | ៤១ | ១៩ | ២១ | ៥ | ៨៦ |
| លើស ២ ឆ្នាំ ដល់ ៣ ឆ្នាំ | ១៦ | ៣ | ៣ | ២ | ២៤ |
| លើស ៣ ឆ្នាំ ដល់ ៤ ឆ្នាំ | ៣ | ១ | ០ | ០ | ៤ |
| លើស ៤ ឆ្នាំ ដល់ ៥ ឆ្នាំ | ៥ | ០ | ០ | ០ | ៥ |

[103] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៥២១ ដែលបានសង្កេតនៅឆ្នាំ២០២២។ "មិនដឹង" សំដៅលើសំណុំរឿងដែលមិនទទួលបានព័ត៌មាន។

[104] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទ (៤១០)ដែលបានជាប់ឃុំក្នុងសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ ២០២២។

| លើស ៥ ឆ្នាំ | ៦ | ០ | ០ | ០ | ៦ |
|---|---|---|---|---|---|
| សរុប | ៨៦ | ៤៧ | ៤២ | ១៥ | ១៩០ |
| មិនដឹងថិរវេលាឃុំខ្លួន | ៩៧ | ៨៨ | ៤ | ៣១ | ២២០ |
| សរុបទាំងអស់ (ចំនួនជនជាប់ចោទ) | ១៨៣ | ១៣៥ | ៤៦ | ៤៦ | ៤១០ |

## ៥.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

| ច្បាប់អន្តរជាតិ | | | ច្បាប់កម្ពុជា | | |
|---|---|---|---|---|---|
| ស.ស.ស.ម | ក.អ.ស.ព.ន | អនុសញ្ញាប្រឆាំងទារុណកម្ម | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន |
| មាត្រា ៥ | មាត្រា ១៤ (៣) (ឆ) និងមាត្រា ៧ | មាត្រា ១៥ | មាត្រា ៣៨ | មាត្រា ១៤៥ និង៣២១ | មាត្រា៥ និង៦ |

មាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន.ធានានូវសិទ្ធិបុគ្គលក្នុងការមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។[105] ទីមួយ ប្រការនេះមានន័យថា មិនត្រូវប្រើការបង្ខិតបង្ខំ ផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោល ដើម្បីបង្ខំជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទឱ្យផ្ដល់ភស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។[106] ទីពីរ ប្រការនេះមានន័យថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទមិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬដោយផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងឡើយ និងមានសិទ្ធិមិនផ្ដល់ភស្តុតាងដែលអាចប្រើប្រាស់ប្រឆាំងនឹងខ្លួនឯង។[107] ប្រសិនបើជនណាម្នាក់បដិសេធក្នុងការផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាព ក្នុងស្ថានភាពនោះចៅក្រមទាញយកសេចក្ដីសន្និដ្ឋានអវិជ្ជមានណាមួយដោយ

[105] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-not-to-be-compelled-to-confess-guilt-or-to-testify-against-oneself ។

[106] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្ដឹងលេខ ៩១២/២០០០, Deolall ទល់នឹង ប្រទេសហ្គីយ៉ាន (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤), CCPR/C/៨២/D/៩១២/ ២០០០ វាក្យខណ្ឌ ៥.១, 9http://juris.ohchr.org/Search/Details/1148។ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្ដឹងលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, Khuseynova និង Butaeva ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន (ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៨) CCPR/ C/៩៤/D/១២៦៣–១២៦៤/២០០៤, វាក្យខណ្ឌ ៨.៣, http://juris.ohchr.org/Search/Details/1457; អ.វ.ត.ក. កាំង ហ្គេកអ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១), អង្គជំនុំជម្រះ (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) វាក្យខណ្ឌ ៣៦០។

[107] ក.អ.ស.ព.ន មាត្រា ១៤(៣)(ច) សូមមើលផងដែរ អ.ស.ក មាត្រា ៤០(២)(ខ)(iv)។

ផ្អែកលើការនៅស្ងៀមនេះ គឺត្រូវបានហាមឃាត់។[108] នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ លក្ខណៈទូទៅជាងនេះ៖ ពួកគេមិនត្រូវបានបង្ខិតបង្ខំឱ្យ "ផ្តល់សក្ខីកម្ម" ឡើយ។[109] សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដូចជាការហាមឃាត់ដាច់ខាតចំពោះការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ដូចមានចែងនៅមាត្រា ៥ នៃ ស.ស.ស.ម. មាត្រា ៧ នៃ ក.អ.ស.ព.ន និងនៅក្នុងអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ("អនុសញ្ញាប្រឆាំងនឹងទារុណកម្ម") ជាពិសេសមាត្រា ១៥។ ការសារភាព ឬចម្លើយណាមួយដែលធ្វើឡើងដោយការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើបាបផ្សេងទៀត មិនត្រូវបានចាត់ទុកជាភស្តុតាងឡើយ លើកលែងតែប្រើជាភស្តុតាងដែលបង្ហាញថាមានការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម ឬការប្រព្រឹត្តផ្សេងទៀត។[110]

[108] ECHR, Condron និងចក្រភពអង់គ្លេស (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០) ពាក្យស្នើសុំលេខ ៣៥៧១៨/៩៧ វាក្យខណ្ឌ ៥៦, http://hudoc.echr.coe.int/eng?i=001-58798; ECtHR, Beckles v. ចក្រភពអង់គ្លេស (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២) ពាក្យស្នើសុំលេខ ៤៤៦៥២/៩៨, វាក្យខណ្ឌ ៥៨, http://hudoc.echr.coe.int/eng?i=001-60672។

[109] អ.ស.ក. មាត្រា ៤០(២)(ខ)(iv)។

[110] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១។

*តួលេខទី ១៤៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង* [111]




នៅអំឡុងពេលធ្វើរបាយការណ៍នេះ មានជនជាប់ចោទចំនួនប្រាំមួយនាក់ក្នុងចំណោម ៧២៤ នាក់ ប៉ុណ្ណោះដែលបានអះអាងថា ពួកគេត្រូវបានស្ដាប់ចម្លើយដោយគ្មានវត្តមានមេធាវីរបស់ខ្លួន (នៅដំណាក់កាលនគរបាលយុត្តិធម៌) (០,៨% នៃជនជាប់ចោទសរុប)៖ ជនជាប់ចោទពីរនាក់នៅសាលាឧទ្ធរណ៍ភ្នំពេញ ជនជាប់ចោទម្នាក់នៅសាលាឧទ្ធរណ៍បាត់ដំបង និងជនជាប់ចោទបីនាក់នៅសាលាឧទ្ធរណ៍ព្រះសីហនុ។ គួរឱ្យកត់សម្គាល់ផងដែរថា មិនមានករណីនេះត្រូវបានលើកឡើងនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំឡើយ។

ទោះជាយ៉ាងនេះក្ដី ជនជាប់ចោទចំនួនដប់មួយនាក់ (១,៥% នៃជនជាប់ចោទសរុប) បានអះអាងថា ពួកគេត្រូវបានគេគំរាមកំហែងឱ្យផ្ដល់ចម្លើយសារភាព (នៅដំណាក់កាលនគរបាលយុត្តិធម៌)៖ ជនជាប់ចោទចំនួនប្រាំពីរនាក់នៅសាលាឧទ្ធរណ៍**ភ្នំពេញ** ជនជាប់ចោទពីរនាក់នៅសាលាឧទ្ធរណ៍**បាត់ដំបង** ជនជាប់ចោទម្នាក់នៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** និងម្នាក់ទៀតនៅសាលាឧទ្ធរណ៍**ព្រះសីហនុ**។ អ្វីដែលគួរកត់សម្គាល់នោះគឺថា ជនជាប់ចោទចំនួន ១៧ នាក់ (២,៣% នៃជនជាប់ចោទសរុប) បានលើកឡើងថាមានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មមកលើពួកគេ ដើម្បីទទួលបានចម្លើយសារភាពពីបទល្មើសដែលបានចោទប្រកាន់នៅក្នុងអំឡុងពេលស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌។ ករណីភាគច្រើននៅសាលាឧទ្ធរណ៍**ភ្នំពេញ** (ជនជាប់ចោទចំនួន ១៣ នាក់) បន្ទាប់មកនៅសាលាឧទ្ធរណ៍**បាត់ដំបង** (ជនជាប់ចោទពីរនាក់) សាលាឧទ្ធរណ៍**ត្បូងឃ្មុំ** (ជនជាប់ចោទម្នាក់) និងសាលាឧទ្ធរណ៍**ព្រះសីហនុ** (ជនជាប់ចោទម្នាក់)។

***វាក្យស័ព្ទច្បាប់ស្ដីពីសិទ្ធិមនុស្សអន្តរជាតិ៖***

***សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាន៖*** *សិទ្ធិដែលរដ្ឋាភិបាលមិនអាចព្យួរការអនុវត្តបានក្នុងកាលៈទេសៈនៃ "ការដាក់ប្រទេសក្នុងគ្រាអាសន្ន" ក្រោមមាត្រា ៤ នៃ ក.អ.ស.ព.ន។*

[111] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៧២៤ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ទាំងជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទមិនមានវត្តមាន ដូច្នេះហើយគ្មាននរណាម្នាក់លើកពីបញ្ហានោះទេ។

***សិទ្ធិដាច់ខាត៖ សិទ្ធិដែលមិនត្រូវបានអនុញ្ញាតឱ្យមានការរឹតត្បិតណាមួយ។***
***បទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិ (គោលការណ៍ ជូស ខូហ្សិន)៖*** "បទដ្ឋានដែលត្រូវបានសហគមន៍អន្តរជាតិនៃបណ្តារដ្ឋទាំងអស់ទទួលយក និងទទួលស្គាល់ថាជាបទដ្ឋាន ដែលមិនអាចធ្វើបដិប្បញ្ញត្តិ"។[112]

បញ្ហាដែលជនជាប់ចោទមួយចំនួននៅតែលើកឡើងបែបនេះ ដោយសារប្រការនេះបង្ហាញឱ្យឃើញថា នៅតែមានការប្រើប្រាស់អំពើហិង្សា ឬការធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាព (នៅដំណាក់កាលនគរបាលយុត្តិធម៌)។ ការលើកឡើងអំពីការបង្ខិតបង្ខំ ឬការធ្វើទារុណកម្ម នៅអំឡុងពេលសួរចម្លើយ (ទាំងផ្លូវចិត្ត ឬផ្លូវកាយ) គឺជាបញ្ហាគួរយកចិត្តទុកដាក់មួយ។ ការហាមឃាត់ការធ្វើទារុណកម្មពិតជាមានលក្ខខណ្ឌពិសេសនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សិទ្ធិនេះមិនត្រឹមតែជាសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាននោះទេ ប៉ុន្តែក៏ជាសិទ្ធិដាច់ខាតផងដែរ។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការហាមឃាត់ការធ្វើទារុណកម្មគឺជាបទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិ "គោលការណ៍ ជូស ខូហ្សិន"។[113] ដូច្នេះ ម.ស.ម.ក បានកំណត់ថា សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង គឺមិនទាន់គោរពបានពេញលេញនោះទេ។

ទោះបីបញ្ហានេះជាបញ្ហាដែលគួរដោះស្រាយ នៅដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរនៃដំណើរការនីតិវិធីក៏ដោយ ចៅក្រមសាលាឧទ្ធរណ៍គួរមានការប្រុងប្រយ័ត្នផងដែរ និងធានាថារាល់ការលើកឡើងអំពីការបង្ខិតបង្ខំដែលមិនទាន់ត្រូវបានដោះស្រាយនៅដំណាក់កាលមុនការជំនុំជម្រះ ត្រូវបានស៊ើបអង្កេតឱ្យបានហ្មត់ចត់មុនពេលអនុញ្ញាតឱ្យបន្តដំណើរការជំនុំជម្រះ។ ចៅក្រមក៏ត្រូវសម្រេចថា ភស្តុតាងជាចម្លើយសារភាពដែលទទួលបានដោយបែបនេះ មិនអាចទទួលយកបានឡើយ ប្រសិនបើមានមូលដ្ឋានហេតុផលត្រឹមត្រូវ ដែលអាចជឿបានថា ភស្តុតាងទាំងនោះត្រូវបានទទួលដោយការបង្ខិតបង្ខំ។ នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថា តែងតែមានការលើកឡើងរបស់ជនជាប់ចោទថាខ្លួនទទួលរងនូវការគំរាមគំហែង ឬទារុណកម្មនៅដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែការលើកឡើងនោះគ្មានមូលដ្ឋានណាមួយបង្ហាញដល់ចៅក្រមជឿថាជាការពិតនោះទេ ដូច្នោះចៅក្រមមានសិទ្ធិក្នុងការសម្រេចថាជឿ ឬមិនជឿដោយឥស្សរចិត្ត។[114] នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

---

112 គណៈកម្មការច្បាប់អន្តរជាតិ របាយការណ៍ការងាររបស់គណៈកម្មការច្បាប់អន្តរជាតិ នៅក្នុងសម័យប្រជុំទី ៧៥ របស់ខ្លួន" កំណត់ហេតុផ្លូវការនៃមហាសន្និបាត សម័យប្រជុំទី ៧៤ សេចក្តីបន្ថែមលេខ ១០ (A/៧៤/១០) (២០១៩) វាក្យខណ្ឌ ៥៦, https://legal.un.org/ilc/reports/2019/។

113 Manfred Nowak, កតិកាសញ្ញាអង្គការសហប្រជាជាតិ *ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – សេចក្តីពន្យល់របស់ CCPR (បោះពុម្ពផ្សាយលើកទី ២, N.P. Engel ឆ្នាំ២០០៥) ទំព័រ ១៥៧។*

114 នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

ភ្នំពេញ បានឆ្លើយថា ការលើកឡើងរបស់ជនជាប់ចោទថាខ្លួនទទួលរងនូវហិង្សា ឬទារុណកម្មនៅដំណាក់កាលនគរបាលយុត្តិធម៌ គឺមិនមានប្រយោជន៍អ្វីទេនៅពេលសវនាការនៅសាលាឧទ្ធរណ៍ ដោយសារតែការលុបលាងមោឃភាពនៃនីតិវិធីមិនអាចអនុវត្តបានទេ ក្រោយពីដីកាដំណោះស្រាយបានចូលជាស្ថាពរ បើយោងតាមមាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តំណាងសាលាឧទ្ធរណ៍នេះក៏បានបន្ថែមថា ចៅក្រមតែងពិនិត្យសំណុំរឿងដោយយកចិត្តទុកដាក់ នៅពេលជនជាប់ចោទបានលើកឡើងថាមានការប្រើហិង្សា ឬទារុណកម្ម ដើម្បីទទួលយកចម្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ តែគ្មានភស្តុតាងជាមូលដ្ឋានសម្រាប់ចៅក្រមធ្វើការពិចារណាលើបញ្ហានេះឡើយ។[115]

## ៥.៣. សិទ្ធិមានមេធាវី[116]

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | |
|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ឃ) | មាត្រា ៣៨ | មាត្រា ១៤៣, ៣០០, ៣០១,និង៣៨៩ | មាត្រា ៦, ៥០ និង៥១ |

ការរងការចោទប្រកាន់ពីបទល្មើសអាចជាបទពិសោធន៍ដ៏គួរឱ្យភ័យខ្លាចមួយ ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់។ ដូច្នេះ ជាការសំខាន់ណាស់ដែលបុគ្គលត្រូវមានឱកាសទទួលបានមេធាវី។ សិទ្ធិមានមេធាវី អាចធានាឱ្យជនជាប់ចោទទទួលបានការពិគ្រោះយោបល់ជាមួយមេធាវី ដែលមានសមត្ថភាពក្នុងការពន្យល់ពីការចោទប្រកាន់មកលើពួកគេ ពន្យល់អំពីសិទ្ធិ ផ្តល់ការណែនាំតាមរយៈដំណើរការជំនុំជម្រះ និងតំណាងឱ្យផលប្រយោជន៍របស់ជនជាប់ចោទនៅក្នុងតុលាការ។ ប្រសិនបើជនជាប់ចោទមិនមានលទ្ធភាពស្វែងរកមេធាវីដោយខ្លួនឯងបានទេ អាជ្ញាធរពាក់ព័ន្ធគប្បីផ្តល់មេធាវីដោយឥតគិតថ្លៃ ប្រសិនបើមានការតម្រូវដោយសារផលប្រយោជន៍យុត្តិធម៌ (ឧទាហរណ៍ ស្ថានទម្ងន់នៃបទល្មើស លទ្ធភាពជាក់ស្តែងដែលមានឱកាសឈ្នះបណ្តឹងឧទ្ធរណ៍)។[117] នៅក្នុងប្រទេសកម្ពុជា ជាការចាំបាច់សម្រាប់ជនជាប់ចោទដែលត្រូវតែមានមេធាវីការពារ ប្រសិនបើជនជាប់ចោទពីបទឧក្រិដ្ឋ ឬប្រសិនបើពួកគេជាអនីតិជន។ វាមិនមែនជាកាតព្វកិច្ចត្រូវតែមានមេធាវីការពារនោះទេ ប្រសិនបើជនជាប់ចោទពីបទមជ្ឈិម (លុះត្រាតែពួកគេជាអនីតិជន ឬកុមារទំនាស់

---

[115] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើបេកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[116] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិទាំងនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសិទ្ធិមានមេធាវី" (ខែកញ្ញា ឆ្នាំ២០២២)https://sithi.org/km/fair-trial-rights/the-right-to-be-present-at-trial-and-the-right-to-defend-oneself-in-person-or-through-legal-representation ។

[117] ក.អ.ស.ព.ន មាត្រា ១៤(៣)(ឃ); គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៨។

នឹងច្បាប់) យ៉ាងណាក៏ដោយ បុគ្គលនោះនៅតែមានជម្រើស ប្រសិនបើពួកគេចង់បានមេធាវី ប៉ុន្តែចំណុចនេះមិនមែនជាបន្ទុករបស់តុលាការនោះទេ។

នៅអំឡុងពេលធ្វើរបាយការណ៍ ជនជាប់ចោទចំនួន ៤៨៣ នាក់ (៦៦,៧%) ក្នុងចំណោមជនជាប់ចោទ ៧២៤ នាក់មានមេធាវីការពារ។ យោងតាមលក្ខណៈមូលដ្ឋាននៃសិទ្ធិនេះ ការពិតដែលថាជនជាប់ចោទ ៣៣,៣% មិនមានមេធាវីការពារសម្រាប់បទមជ្ឈិម និងបទលហុ គឺជាហេតុដែលនាំឱ្យមានការព្រួយបារម្ភ។ ទោះបីជាមានភាពខុសគ្នាខ្លះៗរវាងតុលាការមួយទៅតុលាការមួយក៏ដោយ ក៏មិនមានតុលាការណាមួយដែលគោរពបានពេញលេញស្របតាមសិទ្ធិមានមេធាវីនោះទេ។

*តួលេខទី ១៥៖ សិទ្ធិមានមេធាវី*[118]










---

[118] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៧២៤ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

លើសពីនេះ ជនជាប់ចោទ ១៩០ នាក់មានមេធាវីការពារ ដែលមេធាវីការពារក្ដីឱ្យជនជាប់ចោទលើសពីម្នាក់។ ស្ថានភាពដែលមេធាវីការពារឱ្យជនជាប់ចោទជាច្រើននាក់ ទោះបីជាពេលខ្លះអាចសន្សំសំចៃការចំណាយក៏ដោយ តែក៏អាចប៉ះពាល់ចំពោះសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ ឧទាហរណ៍នៅពេលដែលមេធាវីការពារជនជាប់ចោទច្រើននាក់ ឬមានភាពខុសគ្នា ឬផ្ទុយគ្នាពីស្ថានភាពរបស់ជនជាប់ចោទមួយទៅជនជាប់ចោទមួយទៀត។ ប្រសិនបើ មេធាវីដែលការពារជនជាប់ចោទលើសពីម្នាក់នោះ ការផ្ដល់មេធាវីការពារនឹងជះឥទ្ធិពលអវិជ្ជមានដល់គ្នា ដូច្នេះប៉ះពាល់ដល់ការពារក្ដីប្រកបដោយប្រសិទ្ធភាព និងប៉ះពាល់ការការពារឱ្យបានគ្រប់ជ្រុងជ្រោយអស់ពីសមត្ថភាពរបស់មេធាវី។ ដូច្នេះ ជនជាប់ចោទម្នាក់ៗគប្បីមានមេធាវីដាច់ដោយឡែក។[119] គួរកត់សម្គាល់ថា នៅអំឡុងពេលធ្វើរបាយការណ៍ មេធាវីការពារក្ដីឱ្យជនជាប់ចោទបួននាក់ ដែលជាសហចារី និងមានទំនាស់ផលប្រយោជន៍ នៅក្នុងចំណោមជនជាប់ចោទចំនួនបួននាក់នោះ។

ភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារមានចំនួន ៧៥,៦% នៅសាលាឧទ្ធរណ៍**ភ្នំពេញ** ដែលប្រសើរបន្តិចបើធៀបទៅនឹងឆ្នាំ២០២១ (៧៥,៤%) និងបញ្ជាក់អំពីវឌ្ឍនភាពដែលបានសង្កេតចាប់តាំងពីឆ្នាំ ២០១៩/២០២០ (៧១,៨%)។ ជនជាប់ចោទចំនួន ៩២ នាក់ក្នុងចំណោម ៣៥២ នាក់ (២៦,១%) ទទួលបានមេធាវីការពារក្ដីលើសពីម្នាក់ ហើយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានឃើញទំនាស់ផលប្រយោជន៍ចំនួនពីរនាក់។ តំណាងតុលាការបានលើកឡើងកាលពីមុនថា ចៅក្រមជូនដំណឹងដល់ជនជាប់ចោទដែលមិនមានមេធាវីការពារក្នុងសំណុំរឿងបទមជ្ឈិមអំពីជំនួយផ្នែកច្បាប់ ប៉ុន្តែបានកត់សម្គាល់ថា ជនជាប់ចោទមួយចំនួនបានយល់ព្រមបន្តដំណើរការជំនុំជម្រះដោយមិនមានមេធាវី។ មន្ត្រីតុលាការក៏បានព្យាយាមជួយដល់ជនជាប់ចោទឱ្យមានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់នៅក្នុងសំណុំរឿងបទមជ្ឈិមផងដែរ។ ទោះជាយ៉ាងនេះក្ដី មន្ត្រីទាំងនោះបានលើកឡើងថា ការស្នើសុំមេធាវី គឺមានការលំបាកសម្រាប់ជនក្រីក្រ ដោយសារតែមានការតម្រូវឱ្យផ្ដល់លិខិតបញ្ជាក់ពីស្ថានភាពសេដ្ឋកិច្ចកម្រិតទាបរបស់ពួកគេជូនដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយសារតែគណៈមេធាវីជួបប្រទះបញ្ហាប្រឈមផ្នែកថវិកា ដូច្នេះជារឿយៗគណៈមេធាវីមានការឆ្លើយតបយឺតយ៉ាវទៅនឹងការស្នើសុំមេធាវីនេះ។[120]

បើតាមការប្រៀបធៀបជាមួយតុលាការចំនួនបីផ្សេងទៀត ការអនុវត្តមិនសូវបានប្រសើរនោះទេ ដោយមានជនជាប់ចោទ ៦១,៨% ប៉ុណ្ណោះដែលមានមេធាវីការពារនៅក្នុងការជំនុំជម្រះដែលបានសង្កេតនៅក្នុងសាលាឧទ្ធរណ៍**បាត់ដំបង**។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្ដមអនុប្រធានតុលាការបានលើកឡើងថា សំណើសុំមេធាវី ត្រូវតែដាក់ជូនគណៈមេធាវីតាមរយៈក្រសួងយុត្តិធម៌។ ទោះបីជាឯកឧត្ដមបានទទួលស្គាល់ថាដំណើរការនេះត្រូវការចំណាយពេលវេលាយូរក៏ដោយ ឯកឧត្ដមបានលើកឡើងថា គ្រប់តម្រូវការមេធាវីទាំងអស់គឺត្រូវបាន

[119] សូមមើល "គោលការណ៍ណែនាំស្ដីពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក" ទំព័រ ៤៧។

[120] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្ដមប្រធាន និងឯកឧត្ដមអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្ដមអគ្គព្រះរាជអាជ្ញា និងឯកឧត្ដមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ និងឯកឧត្ដមអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៨/២០១៩ ។

បំពេញជូន។[121] នៅខែមីនា ឆ្នាំ២០២៣ ឯកឧត្តមបានលើកឡើងថា សំណុំរឿងបទឧក្រិដ្ឋទាំងអស់ត្រូវបានជំនុំជម្រះដោយមានមេធាវី លើកលែងតែសំណុំរឿងទាំងនោះត្រូវបានតុលាការចាត់ថ្នាក់ឡើងវិញជាបទមជ្ឈិម។[122] មេធាវីរបស់ជនជាប់ចោទចំនួន ៥៧ នាក់ក្នុងចំណោមជនជាប់ចោទ ១៩៩ នាក់ (២៨,៦%) ទទួលបានមេធាវីការពារលើសពីម្នាក់ ហើយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានរកឃើញមានទំនាស់ផលប្រយោជន៍ចំនួនពីរនាក់។

សាលាឧទ្ធរណ៍**ព្រះសីហនុ** អនុវត្តបានល្អប្រសើរជាងគេបន្តិច ដោយមានជនជាប់ចោទ ៦៤,៤% ទទួលបានមេធាវីការពារនៅអំឡុងពេលធ្វើបាយការណ៍។ នៅខែមីនា ឆ្នាំ២០២៣ តំណាងតុលាការនេះ បានលើកឡើងថា ចៅក្រមបានអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថាសម្រាប់បទមជ្ឈិម ការទទួលបានមេធាវីការពារមិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាយ៉ាងនេះក្តី តុលាការនៅតែសួរជនជាប់ចោទនៅក្នុងសំណុំរឿងបទមជ្ឈិម ថាតើពួកគេចង់បានមេធាវីការពារដែរឬទេ។ ប្រសិនបើពួកគេចង់បានមេធាវីការពារនោះ សវនាការនឹងត្រូវលើកពេលរហូតដល់រកបានមេធាវី។ បន្ទាប់មក ជនជាប់ចោទត្រូវចំណាយលើថ្លៃសេវាមេធាវីដោយខ្លួនឯង។[123] ទោះបីជាមេធាវីរបស់ជនជាប់ចោទចំនួន ២៥ នាក់ក្នុងចំណោមជនជាប់ចោទចំនួន ៨៧ នាក់ (២៨,៧%) បានការពារពីម្នាក់ក៏ដោយ ក៏អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក មិនបានឃើញថាមានទំនាស់ផលប្រយោជន៍ណាមួយនៅក្នុងអំឡុងពេលធ្វើបាយការណ៍នោះទេ។

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ មានជនជាប់ចោទតែ ៤៤,២% ប៉ុណ្ណោះដែលមានមេធាវីកាពារនៅក្នុងសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**។ ទោះបីជាជនជាប់ចោទចំនួន ១៦ នាក់ក្នុងចំណោមជនជាប់ចោទ ៨៦ នាក់ (១៨,៦%) ដែលទទួលបានមេធាវីការពារលើសពីម្នាក់ក៏ដោយ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក មិនបានរកឃើញថាមានទំនាស់ផលប្រយោជន៍ណាមួយនោះទេ។ នៅខែកញ្ញា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានលើកឡើងថា តុលាការបានអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌពេញលេញពាក់ព័ន្ធនឹងសិទ្ធិមានមេធាវីរបស់ជនជាប់ចោទ សម្រាប់បទឧក្រិដ្ឋ និងជនជាប់ចោទជាអនីតិជនត្រូវតែមានមេធាវីដាច់ខាត ដោយឡែកចំពោះបទមជ្ឈិម និងលហុវិញក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនតម្រូវត្រូវតែមាន

[121] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើបេកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[122] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើបេកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[123] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើបេកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

មេធាវីដាច់ខាតនោះទេ  ក្នុងករណីជនជាប់ចោទមិនពឹងពាក់មេធាវីដើម្បីការពារខ្លួន  ហើយយល់ព្រមឱ្យយល់តុលាការដំណើរការសវនាការលើសំណុំរឿងរបស់គេ នុះតុលាការត្រូវអនុវត្តតាមនីតិវិធីច្បាប់[124]

*តួលេខទី ១៦៖ ការពន្យល់អំពីសិទ្ធិ*[125]




នៅក្នុងសំណុំរឿង ៤៨,៦% នៃសំណុំរឿងដែលក្នុងនោះជនជាប់ចោទបានចូលខ្លួននៅក្នុងសវនាការមិនមានមេធាវីការពារ (ចំនួន ៦៩ ក្នុងចំណោម ១៤២ សំណុំរឿង) ចៅក្រមមិនបានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវី ឬសិទ្ធិក្នុងការការពារខ្លួនឯងឡើយ។ ទោះជាយ៉ាងនេះក្ដី មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយទៀតផងដែរ។ ចំនួន ៣៦,៧% នៅសាលាឧទ្ធរណ៍**ភ្នំពេញ** (ចំនួន ១៨ ក្នុងចំណោម ៤៩ សំណុំរឿង) ៥៦.២៥% នៅសាលាឧទ្ធរណ៍**បាត់ដំបង** (ចំនួន ២៧ ក្នុងចំណោម ៤៨ សំណុំរឿង) និង ២៥,៩% នៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** (ចំនួន ៧ ក្នុងចំណោម ២៧ សំណុំរឿង)។ អ្វីដែលគួរកត់សម្គាល់នោះគឺថាចំនួន ៩៤,៤% នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** (ចំនួន ១៧ ក្នុងចំណោម ១៨ សំណុំរឿង)។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមប្រធានតុលាការបានយល់ស្របថាមានការកង្វះខាតក្នុងការពន្យល់អំពីសិទ្ធិដល់ជនជាប់ចោទ និងបានលើកឡើងថា ឯកឧត្តមនឹងរៀបចំកិច្ចប្រជុំបច្ចេកទេសដើម្បីដោះស្រាយបញ្ហានេះ។[126]

---

124 នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ របស់ ម.ស.ម.ក។

125 ចំនួនសំណុំរឿងសរុបដែលជនជាប់ចោទមានវត្តមាន (៤៦១ សំណុំរឿង) សាលាឧទ្ធរណ៍ភ្នំពេញ (២២១ សំណុំរឿង) សាលាឧទ្ធរណ៍បាត់ដំបង (១៣៣ សំណុំរឿង) សាលាឧទ្ធរណ៍ត្បូងឃ្មុំ (៥៣ សំណុំរឿង) និងសាលាឧទ្ធរណ៍ព្រះសីហនុ (៥៤ សំណុំរឿង)។

126 នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

## ៥.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | |
|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(២) | មាត្រា ៣៨ | មាត្រា ៥ |

ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសាកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានអនុវត្តនៅអំឡុងពេលស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌ និងដំណើរការជំនុំជម្រះទាំងមូល រហូតដល់បណ្ដឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ។ [127] ប្រការនេះមានន័យថា បុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញតាមច្បាប់ និងតាមរយៈសេចក្ដីសម្រេចស្ថាពរ។ ជាគោលការណ៍បន្ទុកភស្តុតាងស្ថិតនៅលើស្ថាប័នតំណាងអយ្យការមិនមែនជាបន្ទុករបស់ជនជាប់ចោទ ។[128] ទោះបីជនជាប់ចោទមិននិយាយអ្វី និងមិនបង្ហាញភស្តុតាងអ្វីក៏ដោយ ពួកគេត្រូវតែបានឱ្យរួចទោសដែរ ប្រសិនបើអយ្យការមិនបានបង្ហាញភស្តុតាងដាក់បន្ទុកចាំបាច់គ្រប់គ្រាន់សម្រាប់ការផ្ដន្ទាទោស ម្យ៉ាងវិញទៀត ជនជាប់ចោទមិនមែនជាអ្នកដែលបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថាខ្លួនគ្មានទោសនោះទេ។[129]

*តួលេខទី ១៧៖ សិទ្ធិនៅស្ងៀម* [130]




សិទ្ធិនៅស្ងៀមជាឫសគល់នៅក្នុងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ចៅក្រមមិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទចំនួន ៤៩,២% នៃសំណុំរឿងដែលបានសង្កេត (ចំនួន ២២៧ ក្នុងចំណោម ៤៦១ សំណុំរឿង) ដែលជនជាប់ចោទមានវត្តមាន។ ទោះជាយ៉ាងនេះក្ដី មានភាពខុសគ្នារវាងតុលាការមួយទៅតុលាការមួយ។

---

[127] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១ ) ជំពូកទី ៦ ទំព័រ ២១៩ https://www.ohchr.org/Documents/Publications/training9chapter6en.pdf; អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្ដីពីការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១៤) ទំព័រ ១២៥ ផ្នែកទី ១៥.១។

[128] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០។

[129] សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-the-presumption-of-innocence-and-the-right-to-remain-silent ។

[130] ទិន្នន័យនេះរួមមានសំណុំរឿងចំនួន ៤៦១ ដែលបានសង្កេត (ក្នុងចំណោម ៥២១ សំណុំរឿង) ដែលជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

សាលាឧទ្ធរណ៍**ភ្នំពេញ**មិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះចំនួន ៣៦,២% នៃសំណុំរឿងដែលបានសង្កេត (ចំនួន ៨០ ក្នុងចំណោម ២២១ សំណុំរឿងដែលជនជាប់ចោទមានវត្តមាន)។ ចំនួន ៣១,១% នៃសំណុំរឿងទាំងអស់ (ចំនួន ៨០ ក្នុងចំណោម ២៥៧ សំណុំរឿង) ដែលតួលេខនេះកើនឡើងបើធៀបនឹងឆ្នាំ ២០២១ មានតែ ១៨,៨% ប៉ុណ្ណោះ។ តួលេខនេះមានលក្ខណៈល្អប្រសើរឱ្យកត់សម្គាល់បើធៀបនឹងរបាយការណ៍ឆ្នាំ២០១៧/២០១៨ ចៅក្រមមិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះចំនួន ៧១,៨% នៃសំណុំរឿងទាំងអស់ នេះបង្ហាញឱ្យឃើញអំពីវឌ្ឍនភាពចាប់តាំងពីឆ្នាំ២០១៩/២០២០ ដែលមានចំនួនតែ ២៥,៦% ប៉ុណ្ណោះ។ តុលាការនេះធ្លាប់បានលើកឡើងថា គោលការណ៍នៃការសន្មតទុកជាមុនថាគ្មានទោស មិនតម្រូវឱ្យចៅក្រមប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេនោះទេ។ តុលាការបានបន្ថែមថា ទោះជាយ៉ាងណាជនជាប់ចោទមានសេរីភាពអនុវត្តសិទ្ធិនៅស្ងៀមរបស់ពួកគេ ប្រសិនបើពួកគេមានបំណងដូច្នោះ។[131]

កត់សម្គាល់ថាសាលាឧទ្ធរណ៍**បាត់ដំបង** និងសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** មិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមនៅក្នុងសំណុំរឿង ៥៥,៦% (ចំនួន ៧៤ ក្នុងចំណោម ១៣៣ សំណុំរឿង) និង ៥២,៨% (ចំនួន ២៨ ក្នុងចំណោម ៥៣ សំណុំរឿង) នៃសំណុំរឿងដែលបានសង្កេត។ សាលាឧទ្ធរណ៍**ព្រះសីហនុ**មិនបានប្រាប់ និងពន្យល់អំពីសិទ្ធិនេះចំនួន ៨៣,៣% នៃសំណុំរឿងដែលបានសង្កេត (ចំនួន ៤៥ ក្នុងចំណោមចំនួន ៥៤ សំណុំរឿង)។ នៅខែមីនា ឆ្នាំ២០២៣ តំណាងតុលាការបានលើកឡើងថា ចៅក្រមមិនចាំបាច់ត្រូវប្រាប់ជនជាប់ចោទដែលមានមេធាវីការពារអំពីសិទ្ធិនេះនោះទេ ដោយសារតែតាមទ្រឹស្តី ការធ្វើបែបនេះស្ថិតនៅក្រោមទំនួលខុសត្រូវរបស់មេធាវី។[132] ទោះបីជាមិនមានការលើកឡើងណាមួយដែលថា ចៅក្រមទាញសេចក្តីសន្និដ្ឋានអំពីពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទនៅក្នុងការជំនុំជម្រះដែលបានសង្កេតក៏ដោយ ការប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទទាំងអស់ ជាការអនុវត្តរបស់ចៅក្រមដែលចាំបាច់ត្រូវតែអនុវត្ត ដើម្បីការពារនូវសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។

ខែកញ្ញា ឆ្នាំ២០២៣ សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានបញ្ជាក់ថា ត្បិតពេលខ្លះ ចៅក្រមមិនបានប្រាប់ជនជាប់ចោទពីសិទ្ធិនៅស្ងៀម ប៉ុន្តែជនជាប់ចោទភាគច្រើនលើសលប់ចេះប្រើសិទ្ធិមួយនេះយ៉ាងស្ទាត់ ហើយនៅពេលដែលគាត់មិនឆ្លើយនឹងសំណួររបស់តុលាការ តុលាការមិនបានប្រើហិង្សាបង្ខំឱ្យឆ្លើយទេ បើសួរម្តង ឬពីរដង មិនឆ្លើយទេ តុលាការបន្តសួរសំណួរផ្សេងទៀត។[133]

---

[131] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក ។

[132] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[133] លិខិតលេខ ១៩១៩ រប-ឧ/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ក៏ដាក់កាតព្វកិច្ចលើអាជ្ញាធរផងដែរ ដើម្បីធានាថាគ្មានការបង្ហាញពីពិរុទ្ធភាពណាមួយ ដូចជា ខ្នោះជើង ខ្នោះដៃ ទ្រុងដែក ឬឯកសណ្ឋានពន្ធនាគារ ត្រូវបានដាក់ឱ្យជនជាប់ចោទនៅអំឡុងពេលសវនាការឡើយ។[134] ការអនុវត្តល្អជាអន្តរជាតិក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌបង្ហាញថា ជនជាប់ចោទគួរស្លៀកពាក់សម្លៀកបំពាក់របស់ខ្លួន នៅពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ប្រការនេះអាចមានលក្ខណៈបុរេវិនិច្ឆ័យ នៅពេលជនជាប់ឃុំចូលរួមសវនាការនៃបណ្តឹងឧទ្ធរណ៍ដោយស្លៀកពាក់ឯកសណ្ឋានពន្ធនាគារដូចគ្នាទៅនឹងជនជាប់ឃុំ ដែលត្រូវបានកាត់ទោសរួចជាស្ថាពរហើយ ដោយសារតែការធ្វើបែបនេះជះឥទ្ធិពលទៅលើសេចក្តីសម្រេចរបស់ចៅក្រម និងការយល់ឃើញរបស់សាធារណជន។

វិធានអង្គការសហប្រជាជាតិឆ្នាំ ២០១៥ ស្តីពីបទដ្ឋានអប្បរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (“វិធាននៃលសាន់ម៉ាន់ដឺឡា”)[135] ដែលតំណាងឱ្យការអនុវត្តល្អ ត្រូវបានទទួលស្គាល់ជាអន្តរជាតិលើការប្រព្រឹត្តទៅលើជនជាប់ឃុំចែងថា ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះ គួរត្រូវបានអនុញ្ញាតឱ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេនៅពេលជំនុំជម្រះ ឬប្រសិនបើពួកគេស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវតែមានលក្ខណៈខុសពីទណ្ឌិត។ ដូចគ្នានេះដែរ ជនជាប់ចោទដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានអនុញ្ញាតឱ្យស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ រហូតដល់មានការផ្តន្ទាទោសជាស្ថាពរ។ នៅកម្ពុជា បញ្ហាជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការ ក្នុងឯកសណ្ឋានពន្ធនាគារគឺជាបន្ទុករបស់អគ្គនាយកដ្ឋានពន្ធនាគារ។ យោងតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ឯកសណ្ឋានពណ៌ខៀវគឺសម្រាប់ទណ្ឌិតដែលបានផ្តន្ទាទោសជាស្ថាពរ ចំណែកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីចុងឆ្នាំ២០១៣ គឺសម្រាប់ជនជាប់ឃុំដែលមិនទាន់ត្រូវបានផ្តន្ទាទោសស្ថាពរនៅឡើយ។[136] ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេ ឬយ៉ាងហោចណាស់ មិនមែនក្នុងឯកសណ្ឋានពណ៌ខៀវរបស់ទណ្ឌិតនោះទេ។

---

[134] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០; សូមមើលផងដែរ ECtHR, Samoila and Cionca ទល់នឹង ប្រទេសរ៉ូម៉ានី (ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨) ពាក្យស្នើសុំលេខ ៣៣០៦៥/០៣ វាក្យខណ្ឌ ៩៩-១០១, https://hudoc.echr.coe.int/eng#{"fulltext":["SAMOILA%20AND%20CIONCA"],"documentcollectionid2":["GRANDCHAMBER","CHAMBER"],"itemid":["001-85390"]} ។

[135] មហាសន្និបាតអង្គការសហប្រជាជាតិ វិធានអង្គការសហប្រជាជាតិ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ”, ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៧០/១៧៥ (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥), https://www.unodc.org/documents/justice-and-prison-reform/GA-RESOLUTION/E_ebook.pdf ។

[136] *សូមមើល `ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក`ឯកសណ្ឋានពន្ធនាគារ និងការសន្មតទុកជាមុនថាគ្មានទោស` (ខែមិថុនា ឆ្នាំ២០១៧)* https://sithi.org/medias/files/projects/tmp/publication/cchr-fair-trial-rights-newsletter-on-prisoner-uniform-and-the-presumption-of-innocence-english2017-06-05.pdf ។

*តួលេខទី ១៨៖ ការសន្មតទុកជាមុនថាគ្មានទោស*[137]

| កម្រងសំណួរ | សាលាឧទ្ធរណ៍ភ្នំពេញ | | | សាលាឧទ្ធរណ៍បាត់ដំបង | | | សាលាឧទ្ធរណ៍ត្បូងឃ្មុំ | | | សាលាឧទ្ធរណ៍ព្រះសីហនុ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ | មាន | គ្មាន | មិនពាក់ព័ន្ធ |
| តើជនជាប់ចោទត្រូវបានដាក់ខ្នោះដៃនៅអំឡុងពេលសវនាការទាំងមូលដែរឬទេ? | ០ | ២៦៦ | ៨៦ | ០ | ១៣៧ | ៦២ | ០ | ៤៩ | ៣៧ | ០ | ៥៣ | ៣៤ |
| តើចៅក្រមបានធ្វើសេចក្តីថ្លែងការណ៍ណាមួយអំពីពិរុទ្ធភាពរបស់ជនជាប់ចោទមុនពេលចេញសាលដីកាដែរឬទេ? | ០ | ៣៥២ | ០ | ០ | ១៩៩ | ០ | ០ | ៨៦ | ០ | ០ | ៨៧ | ០ |
| តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមទាញការសន្និដ្ឋានអំពីពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទដែរឬទេ? | ០ | ២៨៨ | ៦៤ | ០ | ១៨១ | ១៨ | ០ | ៧០ | ១៦ | ០ | ៦៥ | ២២ |

នៅអំឡុងពេលធ្វើរបាយការណ៍ ចំនួន ៣៤,៥% នៃជនជាប់ចោទទាំងអស់ដែលមានវត្តមាននៅពេលសវនាការ និងត្រូវបានជាប់ឃុំក្នុងពន្ធនាគារ (ចំនួន ១៧៣ ក្នុងចំណោម ៥០២ នាក់) បានស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវសម្រាប់ទណ្ឌិតនៅក្នុងសវនាការរបស់ពួកគេ។ ការអនុវត្តបែបនេះ ពិតជាប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ តួលេខ ២៤,៨% នៅសាលាឧទ្ធរណ៍**ភ្នំពេញ** (ចំនួន ៦៦ ក្នុងចំណោម ២៦៦ នាក់) បានកើនឡើងបើធៀបនឹងឆ្នាំ២០២១ មានត្រឹម ១៩,៥%។ ទោះបីជាតួលេខនេះមានការធ្លាក់ចុះបើធៀបទៅនឹងឆ្នាំ២០១៩/២០២០ គឺមានដល់ ២៨,២% ក៏ដោយ របកគំហើញទាំងនេះជាបញ្ហាគួរកត់សម្គាល់ដើម្បីឱ្យមានភាពប្រសើរឡើង ដូចដែលបានលើកឡើងទៅកាន់តុលាការជាច្រើនដងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយតុលាការ នៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៨/២០១៩ សាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា ឯកសណ្ឋានរបស់ជនជាប់ចោទ មិនត្រូវបានកំណត់

---

[137] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៧២៤ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។ មិនពាក់ព័ន្ធ = ជនជាប់ចោទអវត្តមាន ឬមិនត្រូវបានជាប់ឃុំក្នុងពន្ធនាគារ។

ដោយស្ថាប័នរបស់ខ្លួនទេ ហើយតុលាការមិនជ្រៀតជ្រែកដល់ការអនុវត្តកិច្ចការរបស់អគ្គនាយកដ្ឋានពន្ធនាគារឡើយ។[138]

ចំពោះតុលាការផ្សេងទៀត ភាគរយនៃជនជាប់ចោទដែលជាប់ឃុំពាក់ឯកសណ្ឋានពណ៌ខៀវនៅអំឡុងពេលសវនាការមាន ៦៥,៣% នៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** (ចំនួន ៣២ ក្នុងចំណោម ៤៩ នាក់) ៤៧,៤% នៅសាលាឧទ្ធរណ៍**បាត់ដំបង** (ចំនួន ៦៥ ក្នុងចំណោម ១៣៧ នាក់) និង ២០% នៅសាលាឧទ្ធរណ៍**ព្រះសីហនុ** (ចំនួន ១០ ក្នុងចំណោម ៥០ នាក់)។ នៅខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍**បាត់ដំបង**បានកត់សម្គាល់ថា ឯកឧត្តមបានស្នើឱ្យមន្ត្រីពន្ធនាគារនាំជនជាប់ចោទមកចូលរួមសវនាការត្រូវមានសម្លៀកបំពាក់របស់ពួកគេផ្ទាល់ ប៉ុន្តែពួកគេបានឆ្លើយថា ការធ្វើបែបនេះគឺត្រូវបានហាមឃាត់ដោយអគ្គនាយកដ្ឋានពន្ធនាគារដោយសារតែហេតុផលសន្តិសុខ។[139] នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍បានអះអាងថា ការស្លៀកពាក់ឯកសណ្ឋានពន្ធនាគាររបស់ជនជាប់ចោទមកចូលរួមសវនាការ គឺជាបន្ទុករបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលនេះមិនមែនជាការទទួលខុសត្រូវរបស់សាលាឧទ្ធរណ៍ឡើយ។[140]

នៅខែមករា ឆ្នាំ២០២៣ ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**បានផ្តល់មតិយោបល់ដូចគ្នា និងបានបន្ថែមថា មន្ត្រីពន្ធនាគារនៅមូលដ្ឋានគឺកំពុងតែពិចារណាលើបញ្ហានេះហើយ។[141] នៅខែមីនា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍**ព្រះសីហនុ** ក៏បានលើកឡើងផងដែរថា ពួកគាត់បានប្រាប់ដល់មន្ត្រីពន្ធនាគារឱ្យអនុញ្ញាតឱ្យជនជាប់ចោទស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលនៅអំឡុងពេលសវនាការ។[142]

---

[138] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្តមប្រធាន និងឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍ ឯកឧត្តមអគ្គព្រះរាជអាជ្ញា និងឯកឧត្តមអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ និងឯកឧត្តមអគ្គលេខាធិការ និងអគ្គលេខាធិការរងនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៨/២០១៩ ។

[139] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[140] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[141] នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[142] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

*តួលេខទី ១៩៖ ការសន្មតទុកជាមុនថាគ្មានទោស*[143]













លើសពីនេះ ជនជាប់ចោទចំនួន ៣២៩ នាក់ដែលជាប់ឃុំ មានវត្តមាននៅពេលសវនាការដែលបានសង្កេតដោយ ម.ស.ម.ក (៦៥,៥% នៃជនជាប់ចោទសរុប) បានបង្ហាញខ្លួននៅពេលសវនាការក្នុងឯកសណ្ឋានពន្ធនាគារខុសពីឯកសណ្ឋានរបស់ទណ្ឌិត។ ទោះបីជាប្រការនេះត្រូវបានលើកលែង ស្របតាមបទដ្ឋានអន្តរជាតិក៏ដោយ គួរតែផ្ដល់អាទិភាពដល់ការស្លៀកពាក់សម្លៀកបំពាក់ស៊ីវិល។ អ្វីដែលល្អនោះ មិនមានជនជាប់ចោទណាដែលត្រូវបានដាក់ខ្នោះដៃនៅពេលសវនាការឡើយ។

## ៥.៥. សិទ្ធិបន្ទាញឥស្លុតាង

| ច្បាប់អន្តរជាតិ | ច្បាប់ជាតិ | |
|---|---|---|
| ក.អ.ស.ព.ន | ក្រមនីតិវិធីព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤(៣)(ង) | មាត្រា ១៥៣, ១៥៤, ២៩៨, ៣២១, ៣២៤, ៣២៦, ៣២៨ & ៣៩៤ | មាត្រា ៦ |

[143] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុបពាក់ព័ន្ធសំណុំរឿងដែលសង្កេតក្នុងឆ្នាំ២០២២។ មិនពាក់ព័ន្ធ = ជនជាប់ចោទអវត្តមាន ឬមិនត្រូវបានជាប់ឃុំក្នុងពន្ធនាគារ។

រាល់ការសម្រេចសេចក្តីទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើភស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ។ ដូច្នេះភាគីនីមួយៗត្រូវមានលទ្ធភាពបង្ហាញភស្តុតាង និងហៅសាក្សីរបស់ខ្លួន ដើម្បីសាកសួរដេញដោលលើភស្តុតាង និងសាក្សី ដែលបានបង្ហាញដោយភាគីម្ខាងទៀត និងតតាំងនឹងភស្តុតាងដែលពួកគេមិនទទួលយក។[144] ចំណុចនេះជាការចាំបាច់ណាស់ ដើម្បីធានាបាននូវសិទ្ធិស្មើភាពគ្នារវាងភាគីពាក់ព័ន្ធ ជាគោលការណ៍មូលដ្ឋានតម្រូវឱ្យមានការប្រព្រឹត្តចំពោះភាគីទាំងអស់ក្នុងរបៀប ដែលធានាបាននូវភាពស្មើគ្នានៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ ហើយគ្មានភាគីណាមួយត្រូវបាត់បង់ឱកាសក្នុងការបង្ហាញរឿងក្តីរបស់ខ្លួនឡើយ។

ការផ្តល់ភស្តុតាងតាមរយៈសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ (មិននៅអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទឡើយ ប្រសិនបើពួកគេបានតទល់ និងសាកសួរសាក្សី នៅពេលដែលសាក្សីនោះបានផ្តល់ចម្លើយ ឬនៅដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលការជំនុំជម្រះ។[145] ជាចុងក្រោយចម្លើយសារភាពណាមួយដែលផ្តល់ដោយជនជាប់ចោទ ត្រូវតែធ្វើឡើងដោយគ្មានការបង្ខិតបង្ខំដោយផ្ទាល់ ឬដោយប្រយោលទាំងផ្លូវកាយ ឬផ្លូវចិត្តឡើយ។ ប្រសិនបើជនជាប់ចោទលើកឡើងអំពីការបំពានលើសិទ្ធិរបស់ខ្លួន នោះបន្ទុកភស្តុតាងគឺត្រូវស្ថិតនៅលើភាគីដែលបាននាំយកចម្លើយនោះ ដើម្បីបង្ហាញថាចម្លើយមិនត្រូវបានធ្វើឡើងដោយការបង្ខិតបង្ខំ និងមិនមែនជាបន្ទុករបស់ជនជាប់ចោទក្នុងការបង្ហាញនោះទេ។[146] ភស្តុតាងដែលទទួលបានមកដោយការបង្ខិតបង្ខំមិនត្រូវបានចាត់ទុកជាភស្តុតាងនោះទេនៅពេលជំនុំជម្រះ។

នៅក្នុងសំណុំរឿងតែចំនួន ០៣ ក្នុងចំណោមសំណុំរឿងចំនួន ៥២១ ដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍ (០,៦% នៃសំណុំរឿងសរុប) ប៉ុណ្ណោះដែលបង្ហាញថា ភាគីជនជាប់ចោទមិនត្រូវបានផ្តល់ឱកាសឱ្យកោះហៅសាក្សីនោះទេ៖ ភាគីជនជាប់ចោទពីរនាក់នៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងម្នាក់នៅសាលាឧទ្ធរណ៍**ព្រះសីហនុ**។ លើសពីនេះ គ្មានអ្វីបង្ហាញថា ភាគីណាមួយមិនត្រូវបានផ្តល់ឱកាសឱ្យបង្ហាញភស្តុតាង ឬ

---

[144] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ១៣, ៣៩។ សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិទាំងនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិបង្ហាញភស្តុតាង (សិទ្ធិហៅ និងសាកសួរសាក្សី" (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/evidentiary-rights-right-to-call-and-examine-witnesses ។

[145] សូមមើល ឧ. ECHR, Mirilashvili ទល់នឹង ប្រទេសរុស្ស៊ី (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨) ពាក្យស្នើសុំលេខ ៦២៩១/០៤ វាក្យខណ្ឌ ១៦៣, http://hudoc.echr.coe.int/eng?i=001-90099; ECtHR, Asch ទល់នឹង ប្រទេសអូទ្រីស ( ថ្ងៃទី២៦ ខែមេសា ឆ្នាំ ១៩៩១) លេខ A ២០៣ វាក្យខណ្ឌ ២៧, http://hudoc.echr.coe.int/eng?i=001-57676; ECtHR, Isgrò ទល់នឹង ប្រទេសអ៊ីតាលី (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩១) លេខ A ១៩៤-A វាក្យខណ្ឌ ៣៤, http://hudoc.echr.coe.int/eng?i=001-57653; ECtHR Kostovski ទល់នឹង ប្រទេសហូឡង់ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) លេខ ១៦៦ វាក្យខណ្ឌ ៤១, http://hudoc.echr.coe.int/eng?i=001-57615។

[146] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ ៣២ វាក្យខណ្ឌ ៤១។ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១០៣៣/២០០១, Singarasa ទល់នឹង ប្រទេសស្រីលង្កា (ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤) CCPR/C/៨១/0/ ១០៣៣/២០០១, វាក្យខណ្ឌ ៧.៤,https://juris.ohchr.org/Search/Details/1125 ។ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹង លេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, Khuseynova និង Butaeva ទល់នឹង ប្រទេសប៉ាគីស្ថាន (ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៨) CCPR/C/៩៤/D/ ១២៦៣-១២៦៤/២០០៤, វាក្យខណ្ឌ ៨.៣, https://juris.ohchr.org/Search/Details/1457។

ពិនិត្យមើលសំណុំរឿងមុនពេលសវនាការនោះទេ។ សិទ្ធិបង្ហាញភស្តុតាងនៅតែមិនទាន់បានគោរពបានពេញលេញដដែលដោយផ្អែកលើមូលហេតុចម្បងចំនួនបី៖

ទីមួយ នៅក្នុងសំណុំរឿងចំនួន ១៨ ក្នុងចំណោម ៤៣ សំណុំរឿង ដែលសាក្សីត្រូវបានកោះហៅ (៤១,៩% នៃសំណុំរឿងសរុប) សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការ មុនពេលដែលពួកគេត្រូវបានកោះហៅមកសាកសួរ។ ករណីនេះមាននៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងសាលាឧទ្ធរណ៍**ព្រះសីហនុ** (សំណុំរឿងចំនួន ០៣ ក្នុងចំណោមសំណុំរឿងចំនួន ០៦ នៃតុលាការនីមួយៗ) និងស្ទើរតែ ៤០% នៃករណីទាំងនេះបានកើតឡើងនៅសាលាឧទ្ធរណ៍បាត់ដំបង (សំណុំរឿងចំនួន ០៧ ក្នុងចំណោម ១៨ សំណុំរឿង) និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ (សំណុំរឿងចំនួន ០៥ ក្នុងចំណោម ១៣ សំណុំរឿង)។ ការអនុវត្តបែបនេះអាចនាំឱ្យសក្ខីកម្មរបស់សាក្សីទទួលរងឥទ្ធិពល នៅពេលស្តាប់សក្ខីកម្មរបស់សាក្សីផ្សេងទៀតមុនពេលខ្លួនផ្តល់សក្ខីកម្មបន្ទាប់។ ការអនុវត្តល្អ គឺត្រូវឱ្យសាក្សីចាកចេញពីបន្ទប់សវនាការរហូតទាល់តែពួកគេត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម។ ឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍បាត់ដំបង បានលើកឡើងថា នៅក្នុងករណីខ្លះ សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការដោយសារតែគូភាគីបានអញ្ជើញសាក្សីដោយមិនបានជូនដំណឹងដល់ចៅក្រម។[147] នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបង្ហាញថា នីតិវិធីនៅសាលាឧទ្ធរណ៍មានការខុសគ្នាខ្លះជាមួយនឹងសាលាដំបូងពាក់ព័ន្ធការបំបែកសាក្សីឱ្យចេញក្រៅពីបន្ទប់សវនាការ។ ចំពោះសាក្សីជាជនជាប់ចោទដូចគ្នា ហើយជនជាប់ចោទនោះបានសារភាពរួចហើយ ករណីនេះមិនចាំបាច់អនុញ្ញាតសាក្សីចេញក្រៅពីបន្ទប់សវនាការទេ តែដោយឡែកចំពោះករណីខ្លះ សាក្សីត្រូវតែបំបែកចេញទៅក្រៅបន្ទប់សវនាការ ដូចជា ករណីជួញដូរគ្រឿងញៀន ឬមានសាក្សីថ្មីជាដើម។[148] ខែធ្នូ ២០២២ ឯកឧត្តមប្រធានសាលាឧទ្ធរណ៍**ព្រះសីហនុ** បានលើកឡើងថា ពេលខ្លះក្រឡាបញ្ជីធ្វេសប្រហែសក្នុងការកោះហៅសាក្សី ឬពិនិត្យមើលថាតើគូភាគីមានវត្តមានហើយឬនៅ ហេតុដូច្នេះមិនដឹងថាតើអាចមានសាក្សីនៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មដែរឬយ៉ាងណានោះទេ។[149]

តុលាការក៏ត្រូវធានាផងដែរថា ភស្តុតាងជាសំអាងនោះមានតម្លៃគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះ (អាចទុកចិត្តបាន និងត្រឹមត្រូវ)។ ទិន្នន័យដែលប្រមូលបាននៅអំឡុងពេលសង្កេតសវនាការបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញ គឺជាបញ្ហាគួរឱ្យកត់សម្គាល់។ ចម្លើយសារភាពសរុបចំនួន ៤៦ ត្រូវបានបង្ហាញនៅ

---

[147] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[148] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ម .ស.ម.ក។

[149] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ពេលជំនុំជម្រះ ហើយក្នុងចំណោមចម្លើយទាំងនេះ មានចំនួន ២៩ ត្រូវបានចៅក្រមផ្អែកជាមូលដ្ឋានលើភស្តុតាង។ ភាពខុសគ្នារវាងតុលាការទាំងបួន៖ សាលាឧទ្ធរណ៍**ព្រះសីហនុ**បានយកចម្លើយសារភាពជាភស្តុតាងចំនួន ៨ សំណុំរឿង (១០០%) ដែលមានការសារភាពត្រូវបានបង្ហាញ ខណៈដែលសាលាឧទ្ធរណ៍**ភ្នំពេញ** យកចម្លើយសារភាពជាភស្តុតាងនៅក្នុងសំណុំរឿងចំនួន ១៨ (៧៨,៣%) នៃសំណុំរឿងចំនួន ២៣ ។ សាលាឧទ្ធរណ៍**បាត់ដំបង**បានយកចម្លើយសារភាពជាភស្តុតាងចំនួន ០៣ សំណុំរឿង (២១,៤%) នៃសំណុំរឿងចំនួន ១៤។ រីឯសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**មានតែមួយសំណុំរឿងប៉ុណ្ណោះ ដែលមានការផ្តល់ចម្លើយសារភាព ប៉ុន្តែចៅក្រមមិនយកចម្លើយសារភាពជាភស្តុតាងនោះទេ។ គុណភាព និងបរិមាណភស្តុតាងដែលត្រូវបានបង្ហាញ និងពិចារណានៅអំឡុងពេលសវនាការជំនុំជម្រះ គឺជាការចាំបាច់ដើម្បីធានាថា បុគ្គលទាំងឡាយត្រូវបាន បង្ហាញថាមានពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ បន្ថែមលើភស្តុតាងជាឯកសារ ចៅក្រម និងព្រះរាជអាជ្ញាគប្បីស្វែងរកដោយសកម្ម និងពិនិត្យលើប្រភេទភស្តុតាងពាក់ព័ន្ធផ្សេងទៀត ដូចជាសាក្សីផ្ទាល់ ភស្តុតាងផ្នែកវេជ្ជ សាស្ត្រ និងភស្តុតាងកោសល្យវិច្ច័យជាដើម។

ជាចុងក្រោយ កង្វះមេធាវីសម្រាប់ជនជាប់ចោទជាច្រើននាក់នៅក្នុងសំណុំរឿងបទមជ្ឈិម ដែលបានសង្កេត បានចោទជាសំណួរអំពីសមត្ថភាពរបស់ជនជាប់ចោទ ដែលមិនទទួលបានប្រយោជន៍ពីចំណេះដឹង និងជំនាញផ្នែកច្បាប់របស់មេធាវី ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពចំពោះសិទ្ធិក្នុងការកោះហៅសាក្សី និងសាកសួរសាក្សីរបស់ភាគីម្ខាងទៀត ដូច្នេះជាបញ្ហាចោទចំពោះការគោរពតាមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់។ មូលហេតុមួយទៀតដែលជាការកត់សម្គាល់ គឺលទ្ធភាពរបស់ជនជាប់ចោទដែលមិនមានមេធាវីការពារក្នុងការសិក្សាសំណុំរឿងរបស់ខ្លួន។ ទោះបីជាមិនមានសំណុំរឿងណាមួយដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍នេះបង្ហាញថា មេធាវីការពារក្តីលើកឡើងពីបញ្ហាណាមួយទាក់ទងនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីក៏ដោយ បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ[150] ដែលអនុញ្ញាតឱ្យមេធាវីការពារពិនិត្យមើលសំណុំរឿង និងថតចម្លងឯកសារសំណុំរឿង មិនបានផ្តល់សិទ្ធិដូចគ្នាដល់ជនជាប់ចោទ ដែលមិនមានមេធាវីការពារឡើយ។ ប្រការនេះអាចបង្កឧបសគ្គដល់ជនជាប់ចោទក្នុងការទទួលបានសិទ្ធិពិនិត្យមើលភស្តុតាងប្រឆាំងនឹងខ្លួន និងមិនអាចរៀបចំការការពារក្តីគ្រប់គ្រាន់ដោយខ្លួនឯងបាននោះទេ។

## ៥.៦. សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

| ច្បាប់កម្ពុជា |
| --- |
| ក្រមនីតិវិធីព្រហ្មទណ្ឌ |
| មាត្រា ៣៥៧ & ៤០៣ |

[150] មាត្រា ១៤៥, ២៥៤, ៣០៤, ៣១៩, ៣៩១ និង ៤២៨ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ។

សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ[151] មានន័យថា សេចក្តីសម្រេចព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាម្នាក់ត្រូវតែមានការពន្យល់ពីមូលហេតុ និងមូលដ្ឋានឈានដល់ការចេញនូវសេចក្តីសម្រេច និងមូលហេតុដែលបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព ឬគ្មានទោស។ ដើម្បីធ្វើដូច្នេះបាន ទាំងអង្គហេតុ (ឧ. កាលបរិច្ឆេទ ទីកន្លែង និងព្រឹត្តិការណ៍ជាក់ស្តែង) ភស្តុតាងដែលចៅក្រមយកជាសំអាងដើម្បីឈានដល់ការចេញសាលដីកា មានសំអាងហេតុរបស់ខ្លួន និងការពន្យល់អំពីសំអាងហេតុរបស់ខ្លួន និងច្បាប់ (ឧ. បទល្មើស និងរបៀបនៃការទទួលខុសត្រូវ៖ ចារី អ្នកសមគំនិត។ល។) ដែលជាសេចក្តីសម្រេច ត្រូវតែមានការពន្យល់បកស្រាយ។ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងរួមបញ្ចូលទាំងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនត្រឹមតែសម្រាប់ការពារជនជាប់ចោទពីសេចក្តីសម្រេចតាមអំពើចិត្តនោះទេ[152] ប៉ុន្តែដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍ផងដែរ។ ច្បាប់អន្តរជាតិចែងថា ដើម្បីអនុវត្តសិទ្ធិប្រកបដោយប្រសិទ្ធភាពឱ្យសាលាជម្រះក្តីជាន់ខ្ពស់ពិនិត្យឡើងវិញលើការផ្តន្ទាទោស និងការកាត់ទោស ពិរុទ្ធជនមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រឹមត្រូវ នៅក្នុងពេលវេលាសមរម្យមួយសម្រាប់បណ្តឹងឧទ្ធរណ៍ទាំងអស់។[153] នៅក្នុងបរិបទប្រទេសកម្ពុជា សិទ្ធិនេះត្រូវបានគោរព ទាំងភាគីជនជាប់ចោទ និងតំណាងអយ្យការដែលមានសិទ្ធិប្តឹងសាទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូលដើម្បីឱ្យត្រួតពិនិត្យឡើងវិញ។

---

[151] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងសិទ្ធិ ទទួលបានសេចក្តីសម្រេចមានសំអាងហេតុ (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-a-public-judgment-and-the-right-to-a-reasoned-judgment ។

[152] អង្គការលើកលែងទោសអន្តរជាតិ, "សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" (ឆ្នាំ២០១៤) ទំព័រ ១៧៣ ផ្នែក ២៤.២។

[153] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្តឹងលេខ ៣២០/ ១៩៨៨, V. Francis ទល់នឹង ប្រទេសចាម៉ៃកា (ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣), GAOR, A/ ៤៨/៤០(លេខ II) វាក្យខណ្ឌ ១២.២, http://hrlibrary.umn.edu/undocs/html/320-1988.html។

*តួលេខទី ២០៖ ការអានសំអាងហេតុពេលប្រកាសសាលដីកាដោយចៅក្រម*[154]




នៅអំឡុងពេលធ្វើរបាយការណ៍នេះ ក្នុងចំណោមសំណុំរឿងចំនួន ៩០% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត សាលដីកាដែលបានស្តាប់ (សំណុំរឿងចំនួន ១១០ ក្នុងចំណោម ១៣៦ សំណុំរឿង) គឺចៅក្រមមិនបានអានសំអាងហេតុនៅពេលប្រកាសសាលដីការបស់ខ្លួនទេ គឺគ្រាន់តែប្រកាសអំពីសេចក្តីសម្រេចតែប៉ុណ្ណោះ។ ភាគរយនេះមាន ៨១,២៥% នៅសាលាឧទ្ធរណ៍**ភ្នំពេញ** ដែលថយចុះពី ៩០% នៅឆ្នាំ២០២១។ ទោះបីជាមានភាពល្អប្រសើរឡើងបន្តិចពីមួយឆ្នាំទៅមួយឆ្នាំក្តី តួលេខនេះនៅតែបង្ហាញថាមានការធ្លាក់ចុះបើប្រៀបធៀបទៅនឹងឆ្នាំ២០១៩/២០២០ ដែលក្នុងនោះសាលដីកាស្ទើរតែពីរភាគបីត្រូវបានប្រកាសដោយមិនបានអានសំអាងហេតុ។ ប្រការនេះធ្វើឱ្យមានការចាប់អារម្មណ៍ ដោយសារតែបញ្ហានេះអាចនាំឱ្យមានការផ្តន្ទាទោសមិនស្របតាមច្បាប់។ នៅខែតុលា ឆ្នាំ២០២១ តុលាការបានលើកឡើងថា ចៅក្រមគ្រាន់តែអានសំអាងហេតុពេលប្រកាសសាលដីកា នៅពេលដែលមានវត្តមានភាគីប៉ុណ្ណោះ និងបានចង្អុលបង្ហាញថា ការធ្វើបែបនេះមិនផ្ទុយទៅនឹងបញ្ញត្តិច្បាប់ណាមួយឡើយ។[155] នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានលើកឡើងថា តុលាការនឹងធ្វើឱ្យប្រសើរឡើងពាក់ព័ន្ធនឹងការប្រកាសសាលដីកាត្រូវមានសង្ខេបពីសំអាងហេតុដើម្បីជនជាប់ចោទទទួលបានព័ត៌មានទាក់ទិននឹងសំណុំរឿងរបស់គេ។[156]

ដូចគ្នានេះដែរ ចៅក្រមសាលាឧទ្ធរណ៍**បាត់ដំបង** និងសាលាឧទ្ធរណ៍**ព្រះសីហនុ** មិនបានអានសំអាងហេតុ នៅក្នុងសំណុំរឿងចំនួន ៨២,២% និង ៧៨,៦% ចំពោះសំណុំរឿងដែលបានសង្កេត ហើយសាលដីកាត្រូវបានស្តាប់។ នៅខែមីនា ឆ្នាំ២០២៣ ឯកឧត្តមអនុប្រធានសាលាឧទ្ធរណ៍**បាត់ដំបង** បានលើកឡើងថា សំអាង

---

[154] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៥២១ ដែលបានសង្កេតនៅឆ្នាំ២០២២។ មិនដឹង មានន័យថាអ្នកសង្កេតការណ៍សវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

[155] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលឆ្លើយតបទៅនឹងរបកគំហើញនៃរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក។

[156] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

ហេតុសម្រាប់សាលដីកា គឺមិនអាននោះទេ ប្រសិនបើជនជាប់ចោទអវត្តមាន។ ទោះជាយ៉ាងនេះក្តី ឯកឧត្តមបានចង្អុលបង្ហាញថា សេចក្តីចម្លងពេញលេញនៃសាលដីកា គឺត្រូវបានផ្ញើទៅឱ្យគូភាគីទាំងអស់។[157]

អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ក៏បានកត់សម្គាល់ផងដែរថា សាលដីកានៃសំណុំរឿងចំនួន ៨៧,១% ដែល ម.ស.ម.ក បានស្តាប់ សាលាឧទ្ធរណ៍បានប្រកាសសាលដីកាលើពិរុទ្ធភាព ដោយតម្កល់សេចក្តីសម្រេចរបស់សាលាដំបូង។ ភាគរយនៃសាលដីកាលើពិរុទ្ធភាពមានចំនួន ៩៣% នៅសាលាឧទ្ធរណ៍ភ្នំពេញ (ជានិន្នាការមួយដែលបានបន្តចាប់តាំងពីអំឡុងពេលធ្វើរបាយការណ៍ ឆ្នាំ២០១៦/២០១៧) ចំនួន ៨៣,៣% នៅសាលាឧទ្ធរណ៍បាត់ដំបង និង ៨៥% នៅសាលាឧទ្ធរណ៍ព្រះសីហនុ។ តួលេខខ្ពស់ទាំងនេះ បូករួមទាំងកង្វះការអានសំអាងហេតុ បង្កើតបានជាការចម្ងល់ថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានគោរពដែរ ឬទេ។ ដូច្នេះ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុនៅតែមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយដោយតុលាការទាំងបីនេះ។ គួរកត់សម្គាល់ថា នៅអំឡុងពេលធ្វើរបាយការណ៍នេះ ម.ស.ម.ក បានស្តាប់សាលដីកាមួយតែប៉ុណ្ណោះនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ហើយសាលដីកាមួយចំនួន អ្នកសង្កេតការណ៍សវនាការមិនបានចូលរួមស្តាប់ទេ។ ទោះបីជាចៅក្រមមិនបានអានសង្ខេបសំអាងហេតុសម្រាប់សាលដីកាលើពិរុទ្ធភាពក្តី កង្វះទិន្នន័យអំពីសាលដីកានៃសំណុំរឿងដទៃទៀត មិនអាចឱ្យ ម.ស.ម.ក ទាញសេចក្តីសន្និដ្ឋាន និងវាយតម្លៃបានច្បាស់លាស់ថាតើតុលាការគោរពសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុបានពេញលេញដែរ ឬទេ។ ខែកញ្ញា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានអះអាងថា តុលាការមានបំណងចង់ប្រកាសសាលដីកាដល់ភាគីនៃសំណុំរឿងទាំងអស់ តែនៅពេលថ្ងៃប្រកាសសាលដីកានោះមានសំណុំរឿងខ្លះមិនមានវត្តមានរបស់ភាគីចូលរួម ដូចនេះតុលាការមិនចាំបាច់ប្រកាសនោះទេ ពីព្រោះគ្មានអ្នកស្តាប់។[158]

## ៥.៧. ការប្រតិបត្តិរបស់ចៅក្រម

| ច្បាប់អន្តរជាតិ | ច្បាប់កម្ពុជា | | |
|---|---|---|---|
| ក.អ.ស.ព.ន | រដ្ឋធម្មនុញ្ញ | ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា | ក្រមសីលធម៌ចៅក្រម |

[157] នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងរបស់សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[158] នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍ របស់ ម.ស.ម.ក។

| មាត្រា ១៤(១) | មាត្រា ១២៨ & ១៣២ | មាត្រា ៨, ៥០ & ៧៧ | មាត្រា ២ & ៨ |
|---|---|---|---|

ដោយជានាតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.ន សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង គឺជាសសរស្តម្ភនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[159] ប្រសិនបើគ្មានការគោរពសិទ្ធិនេះទេ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀតទាំងអស់លែងមានប្រយោជន៍ហើយ។ ជាការពិត សាលាជម្រះក្តីដែលមិនមានសមត្ថកិច្ច មិនឯករាជ្យ និងលម្អៀង មិនអាចបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធានាបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌បានត្រឹមត្រូវនោះទេ។ ដូច្នេះ ចៅក្រមត្រូវតែប្រកាន់វិជ្ជាជីវៈគ្រប់ពេលវេលា និងមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ នៅកម្ពុជា ក្រមសីលធម៌របស់ចៅក្រមត្រូវបានធ្វើនិយតកម្មដោយច្បាប់ស្តីពីលក្ខនិកៈចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ចៅក្រម ដែលតម្រូវឱ្យចៅក្រមមិនរងសម្ពាធពីគ្រប់ទម្រង់នៃឥទ្ធិពលណាមួយពីសំណាក់គូភាគី ឬបុគ្គល ក្រុម ឬស្ថាប័នណាមួយ និងធ្វើសេចក្តីសម្រេចលើសំណុំរឿងប្រកបដោយមនសិការ ការគោរព ការអត់ធ្មត់ សុជីវធម៌ និងសីលធម៌បំផុត ដើម្បីធានានូវយុត្តិធម៌។

នៅអំឡុងពេលធ្វើរបាយការណ៍នេះ មិនមានព្រះរាជអាជ្ញា ឬចៅក្រមណាម្នាក់បានប្រើប្រាស់ឥរិយាបថបំភិតបំភ័យ ឬរើសអើងចំពោះភាគីណាមួយឡើយ រួមទាំងជនជាប់ចោទផងដែរ។ ចៅក្រមបានត្រឹមតែទទួលទូរស័ព្ទរបស់ខ្លួននៅអំឡុងពេលសវនាការក្នុងចំណោមសំណុំរឿងចំនួនប្រាំដែលបានសង្កេត គឺត្រឹមតែ ១% ប៉ុណ្ណោះ។ មានសំណុំរឿងចំនួនបីដែលបានកើតឡើងនៅសាលាឧទ្ធរណ៍**បាត់ដំបង** ស្របពេលដែលសំណុំរឿងចំនួនពីរទៀតបានកើតឡើងនៅសាលាឧទ្ធរណ៍**ភ្នំពេញ** និងសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**។ នៅក្នុងសំណុំរឿងចំនួនបួនក្នុងចំណោមសំណុំរឿងទាំងប្រាំនេះ ចៅក្រមបានលើកនិយាយយ៉ាងខ្លីមុនពេលដាក់ទូរស័ព្ទចុះវិញ។ ទោះជាយ៉ាងនេះក្តី ចៅក្រមមួយរូបនៅ សាលាឧទ្ធរណ៍**បាត់ដំបង** បាននិយាយទូរស័ព្ទនៅអំឡុងពេលសវនាការដែលបានសង្កេត។ ទូរស័ព្ទរបស់ចៅក្រមដែលបានលើកនិយាយនោះ គឺបានដាក់សំឡេងញ័រ លើកលែងតែសំណុំរឿងមួយនៅសាលាឧទ្ធរណ៍**បាត់ដំបង**។ នៅខែសីហា ឆ្នាំ២០២៣ ឯកឧត្តមប្រធានសាលាឧទ្ធរណ៍បាត់ដំបងបានឆ្លើយតបថា ករណីមានការប្រើប្រាស់ទូរស័ព្ទក្នុងអំឡុងពេលសវនាការនេះ តុលាការកំពុងពង្រឹងឱ្យមានភាពប្រសើរឡើង។[160]

---

[159] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង (ខែកញ្ញា ឆ្នាំ២០២២) https://sithi.org/km/fair-trial-rights/the-right-to-be-tried-by-a-competent-independent-and-impartial-tribunal។

[160] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

*តួលេខទី ២១៖ រយៈពេលនៃសវនាការដែលបានសង្កេត*[161]

*ទិន្នន័យជារួម៖*

| រយៈពេលសវនាការ | ១៥ នាទី ឬតិចជាងនេះ | ១៦ - ៣០ នាទី | ៣១ នាទី – ១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ១២៦ | ៤៨ | ៥១ | ២៧ | ២៥២ |
| បទមជ្ឈិម | ៩៨ | ៧៧ | ៦៣ | ២១ | ២៥៩ |
| បទលហុ | ៤ | ៤ | ១ | ១ | ១០ |
| **សរុប** | **២២៨** | **១២៩** | **១១៥** | **៤៩** | **៥២១** |
| **សរុបជា %** | **៤៣,៧៦%** | **២៤,៧៦%** | **២២,០៧%** | **៩,៤០%** | **១០០%** |

*សាលាឧទ្ធរណ៍ភ្នំពេញ*

| រយៈពេលសវនាការ | ១៥ នាទី ឬតិចជាងនេះ | ១៦ - ៣០ នាទី | ៣១ នាទី – ១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ១០៤ | ៣៤ | ២២ | ៥ | ១៦៥ |
| បទមជ្ឈិម | ៤៤ | ២៣ | ១៣ | ៨ | ៨៨ |
| បទលហុ | ៣ | ១ | ០ | ០ | ៤ |
| **សរុប** | **១៥១** | **៥៨** | **៣៥** | **១៣** | **២៥៧** |
| **សរុបជាភាគរយ** | **៥៨,៧%** | **២២,៦%** | **១៣,៦%** | **៥%** | **១០០%** |

*សាលាឧទ្ធរណ៍បាត់ដំបង*

| រយៈពេលសវនាការ | ១៥ នាទី ឬតិចជាងនេះ | ១៦ - ៣០ នាទី | ៣១ នាទី – ១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ១៩ | ១០ | ១៧ | ៥ | ៥១ |
| បទមជ្ឈិម | ៤១ | ៣១ | ១៥ | ៣ | ៩០ |

[161] ទិន្នន័យនេះផ្អែកលើរយៈពេលនៃសវនាការដែលបានកត់ត្រាសម្រាប់សំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

| | | | | | |
|---|---|---|---|---|---|
| បទលហុ | ១ | ១ | ០ | ០ | ២ |
| សរុប | ៦១ | ៤២ | ៣២ | ៨ | ១៤៣ |
| សរុបជាភាគរយ | ៤២,៦% | ២៩,៤% | ២២,៤% | ៥,៦% | ១០០% |

*សាលាឧទ្ធរណ៍ត្បូងឃ្មុំ*

| រយៈពេលសវនាការ | ១៥ នាទី ឬតិចជាងនេះ | ១៦ - ៣០ នាទី | ៣១ នាទី – ១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ១ | ២ | ៩ | ៦ | ១៨ |
| បទមជ្ឈិម | ៥ | ១២ | ១៦ | ៩ | ៤២ |
| បទលហុ | ០ | ១ | ១ | ០ | ២ |
| សរុប | ៦ | ១៥ | ២៦ | ១៥ | ៦២ |
| សរុបជាភាគរយ | ៩,៧% | ២៤% | ៤២% | ២៤,២% | ១០០% |

*សាលាឧទ្ធរណ៍ព្រះសីហនុ*

| រយៈពេលសវនាការ | ១៥ នាទី ឬតិចជាងនេះ | ១៦ - ៣០ នាទី | ៣១ នាទី – ១ ម៉ោង | លើសពី ១ ម៉ោង | សរុប |
|---|---|---|---|---|---|
| បទឧក្រិដ្ឋ | ២ | ២ | ៥ | ១០ | ១៩ |
| បទមជ្ឈិម | ៦ | ១៥ | ១៤ | ៣ | ៣៨ |
| បទលហុ | ០ | ១ | ០ | ១ | ២ |
| សរុប | ៨ | ១៨ | ១៩ | ១៤ | ៥៩ |
| សរុបជាភាគរយ | ១៣,៦% | ៣០,៥% | ៣២,២% | ២៣,៧% | ១០០% |

សវនាការលើបណ្តឹងឧទ្ធរណ៍ភាគច្រើនដែលបានសង្កេតគឺមានរយៈពេលខ្លី ដែលគួរឱ្យមានការយកចិត្តទុកដាក់ចំពោះភាពហ្មត់ចត់របស់ចៅក្រមក្នុងការពិនិត្យសំណុំរឿងនៅអំឡុងពេលជំនុំជម្រះ  ជាពិសេសពាក់ព័ន្ធ

នឹងបទល្មើសធ្ងន់ធ្ងរបំផុត។ នៅក្នុងចំណោមសវនាការចំនួន ៥២១ សំណុំរឿងដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍នេះ សវនាការចំនួន ៤៣,៧៦% មានរយៈពេល ១៥ នាទីឬតិចជាងនេះ (២២៨ សំណុំរឿង) សវនាការចំនួន ២៤,៧៦% មានរយៈពេលចន្លោះពី ១៦ ទៅ ៣០ នាទី (១២៩ សំណុំរឿង) សវនាការចំនួន ២២,០៧% មានរយៈពេលចន្លោះពី ៣១ នាទីទៅមួយម៉ោង (១១៥ សំណុំរឿង) និងមានសវនាការតែ ៩,៤០% ប៉ុណ្ណោះដែលមានរយៈពេលលើសពីមួយម៉ោង (៤៩ សំណុំរឿង)។ គួរឱ្យផ្តោតអារម្មណ៍លើនោះ សវនាការចំនួន ៥៥,៣% នៃសវនាការដែលមានរយៈពេល ១៥ នាទី ឬតិចជាងនេះ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ - សវនាការបទឧក្រិដ្ឋមានរយៈពេលខ្លីបំផុតដែលបានសង្កេតគឺមានរយៈពេលត្រឹមតែបួននាទី - និងសវនាការចំនួន ៤៣% ពាក់ព័ន្ធនឹងបទមជ្ឈិម - សវនាការបទមជ្ឈិមមានរយៈពេលខ្លីបំផុតដែលបានសង្កេត គឺមានរយៈពេលត្រឹមតែបីនាទី។ ដូចនៅផ្នែកផ្សេងៗដែរ មានភាពខុសគ្នារវាងតុលាការនីមួយៗផងដែរ។

សវនាការមានរយៈពេលខ្លី នៅសាលាឧទ្ធរណ៍**ភ្នំពេញ** ដោយសារសវនាការចំនួន ៥៨,៧% មានរយៈពេល ១៥ នាទី ឬតិចជាងនេះ (សំណុំរឿងចំនួន ១៥១ ក្នុងចំណោម ២៥៧ សំណុំរឿង) ហើយលើសពីនេះ សវនាការចំនួន ២២,៦% មានរយៈពេលចន្លោះពី ១៦ ទៅ ៣០ នាទី (សំណុំរឿងចំនួន ៥៨ ក្នុងចំណោម ២៥៧ សំណុំរឿង)។ គួរឱ្យផ្តោតអារម្មណ៍លើនោះ សវនាការចំនួន ៦៨,៩% មានរយៈពេលតិចជាង ១៥ នាទី ពាក់ព័ន្ធនឹងបទឧក្រិដ្ឋ។ ដូចគ្នានេះដែរ សវនាការចំនួន ៤២,៦% នៃសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍**បាត់ដំបង** មានរយៈពេល ១៥ នាទី ឬតិចជាងនេះ (សំណុំរឿងចំនួន ៦១ ក្នុងចំណោម ១៤៣ សំណុំរឿង) ហើយលើសពីនេះ សវនាការចំនួន ២៩,៤% មានរយៈពេលចន្លោះពី ១៦ ទៅ ៣០ នាទី (សំណុំរឿងចំនួន ៤២ ក្នុងចំណោម ១៤៣ សំណុំរឿង)។ ស្ទើរតែមួយភាគបីនៃសវនាការ ដែលមាន រយៈពេលតិចជាង ១៥ នាទីពាក់ព័ន្ធនឹងបទឧក្រិដ្ឋ (សំណុំរឿងចំនួន ១៩ ក្នុងចំណោម ៦១ សំណុំរឿង)។ នៅខែសីហា ឆ្នាំ ២០២៣ តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានមានប្រសាសន៍ថា ចំពោះសវនាការដែលមានរយៈពេលខ្លី ដោយសារជនជាប់ចោទបានសារភាពអំពីទង្វើរបស់គេរួចអស់ហើយ ដូច្នោះចៅក្រមមិនមានអ្វីត្រូវសួរដេញដោលច្រើនថែមទៀតនោះ ឬម្យ៉ាងទៀត ដោយសារមិនមានវត្តមានរបស់ជនជាប់ចោទ។[162]

សវនាការចំនួន ៦៦% នៃសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** មានរយៈពេលលើសពី ៣០ នាទី (សំណុំរឿងចំនួន ៤១ ក្នុងចំណោម ៦២ សំណុំរឿង) និង ៩,៧% នៃសវនាការទាំងនោះ (សំណុំរឿងចំនួន ៦ ក្នុងចំណោម ៦២ សំណុំរឿង) មានរយៈពេល ១៥ នាទី ឬតិចជាងនេះ។ លើសពីនេះ មានសវនាការតែមួយប៉ុណ្ណោះដែលមានរយៈពេល ១៥ នាទី ឬតិចជាងនេះពាក់ព័ន្ធនឹងបទឧក្រិដ្ឋ។ ដូចគ្នានេះដែរ សវនាការចំនួន ៥៥,៩% នៃសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** មាន រយៈពេលលើសពី ៣០

[162] នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

នាទី (សំណុំរឿងចំនួន ៣៣ ក្នុងចំណោម ៥៩ សំណុំរឿង) និង ១៣,៦% នៃសវនាការទាំងនោះ (សំណុំរឿងចំនួន ៨ ក្នុងចំណោម ៥៩ សំណុំរឿង) មានរយៈពេល ១៥ នាទី ឬតិចជាងនេះ រួមទាំងបទឧក្រិដ្ឋចំនួនពីរសំណុំរឿងផងដែរ។

សរុបមក អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា រយៈពេលជាមធ្យមនៃសវនាការដែលបានសង្កេតចំនួន ៥២១ សំណុំរឿង មានត្រឹមតែ ២៨ នាទី ៤៤ វិនាទី ក្នុងមួយសំណុំរឿង។ នៅក្នុងសវនាការដែលមានរយៈខ្លីបំផុតជាច្រើន ត្រូវបានសង្កេតឃើញថា ជនជាប់ចោទអវត្តមាន ឬ/និងមិនមានមេធាវីការពារ។ លើសពីនេះ គ្មានការកោះហៅសាក្សីមកផ្តល់សក្ខីកម្ម នៅក្នុងសវនាការភាគច្រើនដែលបានសង្កេតនោះទេ។ ទោះបីជាមិនមានបទដ្ឋានកំណត់ទាក់ទងនឹងរយៈពេលនៃការជំនុំជម្រះក៏ដោយ សវនាការដែលមានរយៈពេលតិចជាង ៣០ នាទី ជាពិសេសនៅពេលទាក់ទងនឹងបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ស្ទើរតែមិនអាចផ្តល់បរិយាកាសអំណោយផលសម្រាប់ភាគីក្នុងការមានលទ្ធភាពការពារសំណុំរឿងរបស់ខ្លួនឱ្យបានពេញលេញនោះទេ។

ការអនុវត្តប្រកបដោយមនសិការ និងភាពអត់ធ្មត់ ដើម្បីផ្តល់ភាពយុត្តិធម៌ត្រឹមត្រូវដល់ភាគី គឺជាគោលការណ៍មួយដែលចៅក្រមត្រូវប្រកាន់ខ្ជាប់តាមក្រមសីលធម៌។ ដូច្នេះ តុលាការត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ពេលវេលាឱ្យបានគ្រប់គ្រាន់សម្រាប់សវនាការ ដើម្បីធានានូវការវិនិច្ឆ័យត្រឹមត្រូវ និងហ្មត់ចត់ ហើយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់របស់ជនជាប់ចោទ រួមមានសិទ្ធិមានវត្តមាន និងសិទ្ធិមានមេធាវី ត្រូវបានគោរពពេញលេញ ហើយភស្តុតាងត្រូវបានប្រមូលគ្រប់គ្រាន់ និងបង្ហាញនៅក្នុងសវនាការ ដើម្បីធានានូវការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវ។

## ៥.៨. សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

| ច្បាប់អន្តរជាតិ | | ច្បាប់កម្ពុជា | | | |
|---|---|---|---|---|---|
| ក.អ.ស.ព.ន | អ.ស.ក | រដ្ឋធម្មនុញ្ញ | ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌ | ច្បាប់ស្តីពីយុត្តិធម៌អនីតិជន |
| មាត្រា ១៤ (១) | មាត្រា ៣៧ & ៤០ | មាត្រា ៣១ & ៤៨ | មាត្រា ១០០ & ២១២ | មាត្រា ៣៩ & ៤០ | មាត្រា ៥, ៦, ៣៩, ៤៧, ៤៨, ៤៩, ៥៤, ៥៧ & ៨២ |

ច្បាប់អន្តរជាតិធានាចំពោះកុមារ - ជនដែលមានអាយុក្រោម ១៨ ឆ្នាំ[163] ដែលបានរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ នូវរាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលអនុវត្តចំពោះមនុស្សពេញវ័យ ប៉ុន្តែ

[163] អ.ស.ក, មាត្រា ១។

ទទួលស្គាល់ថា ពួកគេក៏ត្រូវការកិច្ចការពារពិសេសផងដែរ ដោយគិតគូរពីអាយុ ភាពដឹងក្តី និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី។[164]

ក.ស.អ.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") ដែលចូលជាធរមាននៅកម្ពុជានៅឆ្នាំ១៩៩២ ចែងពីបទប្បញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តលើកុមារនៅក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ [165] ដែលគាំទ្រដោយវិធាន និងគោលការណ៍ណែនាំអន្តរជាតិជាច្រើន។[166] កតិកាសញ្ញា និងអនុសញ្ញាទាំងនេះបកស្រាយពីភាពចាំបាច់ជាពិសេសសម្រាប់រដ្ឋភាគីក្នុងការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នដែលអនុវត្តជាពិសេសចំពោះកុមារដែលបានរងការចោទប្រកាន់ ឬទទួលស្គាល់ថាបានបំពានលើច្បាប់ព្រហ្មទណ្ឌ។ ជាពិសេស រដ្ឋត្រូវកំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកុមារត្រូវសន្មតថាមិនមានសមត្ថភាពក្នុងការបំពានច្បាប់ព្រហ្មទណ្ឌ និងមិនអាចទទួលខុសត្រូវក្នុងដំណើរការនីតិវិធីច្បាប់ព្រហ្មទណ្ឌបានឡើយ។[167] កុមារដែលមានអាយុអប្បបរមា ឬលើសពីអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែក្រោមអាយុ ១៨ ឆ្នាំ អាចត្រូវបានចោទប្រកាន់ជាផ្លូវការ និងទទួលបាននីតិវិធីយុត្តិធម៌កុមារស្របតាម អ.ស.ក ។[168] ទោះបីជាយ៉ាងនេះក្តី រដ្ឋភាគីត្រូវបានតម្រូវឱ្យលើកកម្ពស់វិធានការដោះស្រាយជាមួយកុមារ ដោយមិនឈានទៅរកដំណើរការនីតិវិធីតុលាការនៅពេលដែលសមស្រប និងចាំបាច់"។[169] លើសពីនេះ ការសម្រេចទោសមួយចំនួនដូចជា ដីកាសម្រេចលើការថែទាំ ដីកាណែនាំ និងដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការផ្តល់ប្រឹក្សា ការព្យួរទោស ការថែទាំជំនួស កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជម្រើសផ្សេងទៀតចំពោះការថែទាំតាមស្ថាប័នត្រូវតែមានដើម្បីធានាថា កុមារត្រូវបានដោះស្រាយដោយសមស្របទៅនឹងសុខុមាលភាពរបស់ពួកគេ ហើយថែមទាំងស្របទៅតាមកាលៈទេសៈរបស់ពួកគេ និងបទល្មើស។[170] ច្បាប់កម្ពុជាបានបញ្ញត្តិបន្ថែមពីការប្រព្រឹត្តលើកុមារទំនាស់នឹងច្បាប់ខុសៗគ្នានៅក្នុងផ្នែកសំខាន់ៗជាច្រើន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តនៅឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារទំនាស់នឹងច្បាប់។

---

[164] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់" (ខែកញ្ញា ឆ្នាំ ២០២២) ។ https://sithi.org/km/fair-trial-rights/the-rights-of-children-conflict-with-the-law ។

[165] អ.ស.ក , មាត្រា ៤០(២) គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ មាត្រា ១៤ វាក្យខណ្ឌ ៣៨-៧១, ក.អ.ស.ព.ន មាត្រា ១៤, គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤២។

[166] ឧទាហរណ៍ វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) ឬវិធានច្បាប់របស់អង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសិទ្ធិសេរីភាពក្នុងចំណោមវិធានច្បាប់ផ្សេងៗ។

[167] អ.ស.ក, មាត្រា ៤០(៣)។

[168] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

[169] អ.ស.ក, មាត្រា ៤០(៣០) គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។

[170] អ.ស.ក, មាត្រា ៤០ (៤)។

*ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ*

ជាអន្តរជាតិ អាយុអប្បបរមាទូទៅបំផុតគឺ ១៤ ឆ្នាំ។[171] ច្បាប់ជាតិបានកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅអាយុដូចគ្នា[172] មានន័យថា គ្មានកុមារណាម្នាក់ក្រោមអាយុដែលបានកំណត់នេះនៅពេលបទល្មើសកើតឡើង ត្រូវបានតុលាការជំនុំជម្រះនោះទេ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់កុមារដែលត្រូវបានសង្ស័យថាប្រព្រឹត្តបទល្មើសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន រួមទាំងស្វែងរកសំបុត្រកំណើត ឬឯកសារបញ្ជាក់កំណើត ឬប្រើប្រាស់មធ្យោបាយដែលអាចទុកចិត្តបានផ្សេងទៀតដែលតុលាការអាចទទួលយកបាន ដើម្បីកំណត់អាយុរបស់ពួកគេក្នុងករណីដែលគ្មានឯកសារបញ្ជាក់កំណើត។ ការសង្ស័យណាមួយទាក់ទងនឹងអាយុរបស់កុមារត្រូវតែដោះស្រាយឱ្យបានត្រឹមត្រូវ។[173] ដូចគ្នានេះដែរ តុលាការត្រូវតែផ្ទៀងផ្ទាត់អាយុរបស់កុមារទំនាស់នឹងច្បាប់ពាក់ព័ន្ធនឹងសំណុំរឿង ដែលខ្លួនទទួលបន្ទុកក្នុងការជំនុំជម្រះ។ ប្រសិនបើអាចកំណត់បានថា កុមាររងការចោទប្រកាន់មានអាយុក្រោម ១៤ ឆ្នាំ នៅពេលបទល្មើសកើតឡើង ឬប្រសិនបើមានការសង្ស័យអំពីអាយុរបស់ពួកគេនៅពេលបទល្មើសកើតឡើងនោះចៅក្រមត្រូវឱ្យពួកគេរួចពីបទចោទប្រកាន់ភ្លាមៗ។

នៅអំឡុងពេលធ្វើរបាយការណ៍នេះ ក្នុងចំណោមជនជាប់ចោទចំនួន ៧២៤ នាក់ដែលពាក់ព័ន្ធនឹងសំណុំរឿងដែល ម.ស.ម.ក បានសង្កេត ជនជាប់ចោទចំនួន ២៦ នាក់ជាកុមារនៅពេលបទល្មើសកើតឡើង។ កុមារចំនួនបួននាក់មានអាយុចន្លោះពី ១៤-១៥ ឆ្នាំ (១៥,៤%) និង ២២ នាក់ (៨៤,៦%) មានអាយុ ១៦-១៧ ឆ្នាំ នៅពេលបទល្មើសកើតឡើង។

ជនជាប់ចោទចំនួនដប់ប្រាំនាក់ ដែលត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**បាត់ដំបង** រួមទាំងជនជាប់ចោទចំនួនបីនាក់ដែលមានអាយុ ១៤-១៥ ឆ្នាំនៅពេលបទល្មើសបានកើតឡើង។ បន្ថែមពីនេះ ជនជាប់ចោទចំនួនប្រាំមួយនាក់បានបង្ហាញខ្លួនចំពោះមុខសាលាឧទ្ធរណ៍**ភ្នំពេញ** រួមទាំងជនជាប់ចោទម្នាក់ដែលមានអាយុ ១៤-១៥ ឆ្នាំនៅពេលបទល្មើសបានកើតឡើង។ ជនជាប់ចោទប្រាំនាក់ ដែលមានអាយុ ១៦-១៧ ឆ្នាំនៅពេលបទល្មើសបានកើតឡើង ត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**ព្រះសីហនុ**។

---

[171] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

[172] ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៨ និង ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

[173] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

## *តួលេខទី ២២៖ អាយុនៅពេលបទល្មើសកើតឡើង*[174]




## *សិទ្ធិមានសេរីភាព*

នៅអំឡុងពេលធ្វើរបាយការណ៍នេះ កុមារចំនួន ២៣ នាក់ក្នុងចំណោមកុមារទំនាស់នឹងច្បាប់ចំនួន ២៦ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេត (៨៨,៥%) គឺត្រូវបានបន្តឃុំខ្លួនបណ្តោះអាសន្ន រួមទាំងកុមារចំនួនពីរនាក់ដែលមានអាយុ ១៤-១៥ ឆ្នាំនៅពេលបទល្មើសកើតឡើង។ តុលាការទាំងបីសុទ្ធតែប្រើវិធានការនៃការបន្តឃុំខ្លួនទាំងអស់។ លើសពីនេះ កុមារចំនួន ២១ នាក់ក្នុងចំណោមកុមារដែលបានបន្តឃុំខ្លួន ២៣ នាក់ ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារក្នុងពេលសវនាការរបស់ពួកគេ រួមទាំងកុមារចំនួនប្រាំមួយនាក់ដែលបង្ហាញខ្លួនក្នុងឯកសណ្ឋានពណ៌ខៀវសម្រាប់ទណ្ឌិត ដូច្នេះប្រការនេះធ្វើឱ្យប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោស។

កុមារចំនួន ៨៣,៣% នៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**ភ្នំពេញ** (៥ នាក់ ក្នុងចំណោម ៦ នាក់) ត្រូវបានបន្តឃុំខ្លួនជាបណ្តោះអាសន្ន ដែលកើនឡើងពីចំនួន ៧៥% នៅឆ្នាំ២០២១។ ទោះបីជាតួលេខទាំងនេះមានភាពល្អប្រសើរ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩/២០២០ គឺកុមារទាំងអស់ត្រូវបានបន្តឃុំខ្លួនជាបណ្តោះអាសន្ន សិទ្ធិមានសេរីភាពរបស់កុមារទំនាស់នឹងច្បាប់មិនត្រូវបានគោរពជាបន្តបន្ទាប់ដោយតុលាការចាប់តាំងពីឆ្នាំ២០១៤ មក។ ជាការពិតណាស់ របកគំហើញពីការសង្កេតសវនាការដែលអនុវត្តដោយ ម.ស.ម.ក ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២២ បង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធនៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារ។ កុមារដែលត្រូវបានបន្តឃុំខ្លួនទាំងអស់បានបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារនៅអំឡុងពេលធ្វើរបាយការណ៍នេះ រួមទាំងកុមារចំនួនបីនាក់ដែលស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ។

[174] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប (២៦ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

ដូចគ្នានេះដែរ កុមារចំនួន ៩៣,៣% នៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**បាត់ដំបង** ត្រូវបានបន្តឃុំខ្លួនជាបណ្តោះអាសន្ន (១៤ នាក់ ក្នុងចំណោម ១៥ នាក់)។ កុមារទាំងអស់លើកលែងតែកុមារម្នាក់ក្នុងចំណោមកុមារដែលត្រូវបានបន្តឃុំខ្លួនទាំងអស់ បានបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារ ក្នុងនោះកុមារចំនួនពីរនាក់ស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ។ ជាចុងក្រោយ កុមារចំនួន ៨០% នៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** ត្រូវបានបន្តឃុំខ្លួនជាបណ្តោះអាសន្ន (៤ នាក់ ក្នុងចំណោម ៥ នាក់)។ ជាថ្មីម្តងទៀត កុមារទាំងអស់លើកលែងតែកុមារម្នាក់ ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារនៅពេលសវនាការរបស់ខ្លួន រួមមានកុមារម្នាក់ស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ។

*តួលេខទី ២៣៖ ចំនួនភាគរយនៃកុមារទំនាស់នឹងច្បាប់ដែលត្រូវបានបន្តឃុំខ្លួននៅឆ្នាំ២០២២*[175]




ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាអាទិភាពនៅពេលធ្វើការសម្រេច ឬដាក់ទោសលើកុមារ ដែលបានរកឃើញថាបានបំពានច្បាប់ព្រហ្មទណ្ឌ។[176] ការដកហូតសិទ្ធិសេរីភាពរបស់កុមារចាប់ពីពេលឃាត់ខ្លួន នៅពេលដំណើរការនីតិវិធីទាំងមូល និងការផ្តន្ទាទោស គឺត្រូវចាត់ទុកជាវិធានការចុងក្រោយ ហើយគួរត្រូវបានប្រើតែនៅក្នុងករណីពិសេសប៉ុណ្ណោះសម្រាប់រយៈពេលសមស្របខ្លីបំផុត។[177] ច្បាប់គួរចែងពីវិធានការមិនឃុំខ្លួនផ្សេងៗ និងកំណត់យ៉ាងច្បាស់អំពីអាទិភាពក្នុងការប្រើប្រាស់វិធានការទាំងនេះ[178] និងច្បាប់កម្ពុជាចែងពីវិធានការមិនឃុំខ្លួន។[179]

មានតែកុមារម្នាក់ប៉ុណ្ណោះក្នុងចំណោម ១២ នាក់ ដែលសាលដីកាត្រូវបានស្តាប់ បានបង្ហាញថាចៅក្រមបានពិចារណាសម្រេចផ្តន្ទាទោសមិនដាក់ពន្ធនាគារ។ នៅឆ្នាំ២០១៩ សាលាឧទ្ធរណ៍**ភ្នំពេញ**បានលើក

175 ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប (២៦ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

176 អ.ស.ក មាត្រា ៣(១), សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧៦។

177 អ.ស.ក មាត្រា ៣៧(ខ), សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៩, ៧៣, ៨២-៩៥ ។

178 គណៈកម្មាធិការ អ.ស.ក សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧៣។

179 ក្រមព្រហ្មទណ្ឌ មាត្រា ៤០ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧ ។

ឡើងកាលពីមុនថា ការអនុវត្តវិធានបង្វែរសម្រាប់កុមារដែលជាជនល្មើសតម្រូវឱ្យមានដាក់ទោសជំនួសជាផ្លូវការ គឺមិនអាចធ្វើទៅបានទេ ដោយសារកង្វះយន្តការគាំទ្រវិធានការបែបនេះ។[180]

*ការបែងចែកជនជាប់ឃុំជាកុមារក្នុងពន្ធនាគារ*

បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌កុមារ ក៏បានផ្តល់អនុសាសន៍អំពីការដាក់កុមារឱ្យដាច់ដោយឡែកពីអ្នកជាប់ឃុំពេញវ័យនៅក្នុងមន្ទីរឃុំឃាំង លើកលែងឧត្តមប្រយោជន៍របស់កុមារមិនត្រូវបានពិចារណា ដើម្បីជៀសវាងការដាក់ឱ្យពួកគេទទួលរងឥទ្ធិពលអវិជ្ជមានពីជនជាប់ឃុំពេញវ័យ។ កុមារដែលត្រូវឃុំខ្លួន មិនត្រូវឃុំនៅមណ្ឌល ឬនៅក្នុងពន្ធនាគារសម្រាប់មនុស្សពេញវ័យនោះទេ ពោលគឺត្រូវឃុំនៅអគារសម្រាប់កុមារ។[181] នៅអំឡុងពេលធ្វើរបាយការណ៍នេះ មិនមានអ្វីមួយដែលបង្ហាញថា កុមារទំនាស់នឹងច្បាប់ដែលត្រូវបានឃុំខ្លួននោះត្រូវបានដាក់ជាមួយជនជាប់ឃុំពេញវ័យនោះទេ។

*ការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់*

តាមច្បាប់សិទ្ធិមនុស្ស កុមារមានសិទ្ធិទទួលបានការគោរពឯកជនភាពរបស់ពួកគេនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។[182] ប្រការនេះរាប់បញ្ចូលទាំងទំនាក់ទំនងដំបូងនៃការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចជាស្ថាពរ ឬប្រសិនបើត្រូវបានផ្តន្ទាទោស មានការរួចផុតពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការឃុំឃាំង ឬការដកហូតសេរីភាព។ ហេតុផលជាមូលដ្ឋានគឺដើម្បីជៀសវាងការប៉ះពាល់ ដែលបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬសញ្ញាមិនសមរម្យ។[183] ដូច្នេះ វិធានច្បាប់ជាសវនាការយុត្តិធម៌កុមារត្រូវធ្វើឡើងជាអសាធារណៈ និងមានការលើកលែងដែលមានកម្រិតតាមច្បាប់។[184] ឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ឬកុមាររងគ្រោះអាចត្រូវបានការពារបន្ថែមដោយការដាក់នៅខាងក្រោយរនាំង ឬប្រើប្រាស់មធ្យោបាយផ្សេងទៀតក្នុងការផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា មានដូចជាសវនាការតាមប្រព័ន្ធវីដេអូ ឬសវនាការជាអសាធារណៈគួរត្រូវបានពិចារណា។ ប្រសិនបើសាលដីកា ឬការផ្តន្ទាទោសត្រូវបានប្រកាសជាសាធារណៈ នោះអត្តសញ្ញាណរបស់កុមារមិនគួរត្រូវបានបង្ហាញឡើយ។[185] ជាចុងក្រោយ ឯកសារណាមួយទាក់ទងនឹងកុមារគួរត្រូវបានរក្សាការសម្ងាត់យ៉ាងតឹងរ៉ឹង និងមិនបើកចំហដល់ភាគីទីបី លើកលែងតែចំពោះអ្នកដែលពាក់ព័ន្ធដោយ

---

[180] នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្តមប្រធាន ឯកឧត្តមអនុប្រធានទាំងអស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញា តំណាងចៅក្រមមួយរូប និងឯកឧត្តមអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញនៅក្នុងរបាយការណ៍ឆ្នាំ២០១៧/២០១៨។

[181] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៩២ និង ៩៣។

[182] អ.ស.ក, មាត្រា ៤០(២)(ii) សូមមើលផងដែរ អ.ស.ក មត្រា ១៦ និង មាត្រា ៤០(១), គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៦។

[183] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

[184] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[185] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

ផ្ទាល់ក្នុងការស៊ើបអង្កេត និងការវិនិច្ឆ័យលើសំណុំរឿង។[186] ប្រការនេះត្រូវបានធានា ទោះបីជានៅពេលដែលកុមារឈានដល់អាយុ ១៨ ឆ្នាំក៏ដោយ។[187]

### *តួលេខទី ២៤៖ ការការពារឯកជនភាពរបស់កុមារ*[188]




នៅអំឡុងពេលធ្វើរបាយការណ៍នេះ វិធានការនានា (សវនាការជាអសាធារណៈ) ត្រូវបានអនុវត្ត ដើម្បីការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ចំនួន ៥៤,៥% (ចំនួន ១២ នាក់ក្នុងចំណោម ២២ នាក់) ក្នុងសំណុំរឿងដែលបានសង្កេត ដែលជនជាប់ចោទមានវត្តមាននៅពេលសវនាការ។ ទោះជាយ៉ាងនេះក្តី មានភាពខុសគ្នារវាងតុលាការទាំងបួនផងដែរ។

គួរឱ្យផ្តោតលើនោះ មិនមានវិធានការណាមួយត្រូវបានអនុវត្តដើម្បីការពារឯកជនភាពកុមារចំនួនប្រាំនាក់ ក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍**ភ្នំពេញ**នោះទេ។ ករណីនេះក៏បានកើតឡើងនៅឆ្នាំ២០២១ ផងដែរ។ តុលាការនេះក៏បានធ្វើសវនាការជាអសាធារណៈទាក់ទងនឹងសំណុំរឿងកុមារទំនាស់នឹងច្បាប់ នៅអំឡុងពេលធ្វើរបាយការណ៍នេះ ប៉ុន្តែ ម.ស.ម.ក មិនអាចសង្កេតសវនាការទាំងនោះបាន។

តួលេខនេះគឺជាបញ្ហា ជាពិសេស ដោយសារបញ្ហាសិទ្ធិឯកជនភាពរបស់កុមារនៅពេលសវនាការព្រហ្មទណ្ឌត្រូវបានពិភាក្សាដោយយកចិត្តទុកដាក់ជាមួយតុលាការនៅខែសីហា ឆ្នាំ២០១៩ នៅពេលដែលតុលាការបានបដិសេធចំពោះរបកគំហើញអវិជ្ជមាននៅក្នុងរបាយការណ៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។ ជាការឆ្លើយតបនឹងបញ្ហានេះ តុលាការបានលើកឡើងអំពីការតម្លើងប្រព័ន្ធបច្ចេកវិទ្យាសវនាការតាមប្រព័ន្ធវីដេអូដែលជាជំនួយរបស់អង្គការយូនីសេហ្វ ដើម្បីការពារភាពឯកជនរបស់កុមារឱ្យបានកាន់តែល្អប្រសើរ។ តុលាការក៏បានស្នើឱ្យ ម.ស.ម.ក កត់ត្រា និងរាយការណ៍មកកាន់ប្រធានតុលាការ ចំពោះចៅក្រមណាដែលមិនទាន់គោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងសំណុំរឿងកុមារ ក៏ដូចជាករណីមិនមានការគោរពឯកជនភាពពេញលេញនៅពេលសវនាការផងដែរ។[189]

---

[186] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[187] គណៈកម្មាធិការសិទ្ធិកុមារ, សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

[188] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុប (២៦ នាក់) ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥២១ ដែលបានសង្កេត។

[189] នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ម.ស.ម.ក បានជួបប្រជុំជាមួយឯកឧត្តមប្រធាន ឯកឧត្តមអនុប្រធានទាំងអស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញា តំណាងចៅក្រមមួយរូប និងឯកឧត្តមអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីលទ្ធផលរកឃើញនៅក្នុងរបាយការណ៍ឆ្នាំ២០១៧/២០១៨។

នៅអំឡុងពេលប្រជុំពិគ្រោះយោបល់អំពីរបកគំហើញសម្រាប់របាយការណ៍ប្រចាំឆ្នាំ២០២១ តុលាការបានលើកឡើងថា នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទជាកុមារ កុមាររងគ្រោះ ឬកុមារជាសាក្សី ការជំនុំជម្រះត្រូវបានធ្វើឡើងដោយប្រើប្រាស់វនាំងការពារឯកជនភាព និងតាមប្រព័ន្ធវីដេអូ។ តុលាការបានលើកឡើងថា ទាំងការជំនុំជម្រះ និងការចេញសេចក្ដីសម្រេចសម្រាប់សំណុំរឿងពាក់ព័ន្ធនឹងកុមារ គឺធ្វើឡើងក្នុងសវនាការជាអសាធារណៈ ទោះបីជាសំណុំរឿងទាំងនោះពាក់ព័ន្ធនឹងជនជាប់ចោទពេញវ័យក៏ដោយ។ ប៉ុន្តែ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងបែបនេះក្ដី សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ នៅតែមិនទាន់បានគោរពដោយតុលាការនៅឡើយ។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានអះអាងថា តុលាការនឹងអនុវត្តឱ្យប្រសើរឡើងលើសំណុំរឿងកុមារទំនាស់នឹងច្បាប់ ជាពិសេស សវនាការត្រូវធ្វើជាអសាធារណៈ។[190]

ដូចគ្នានេះដែរ សាលាឧទ្ធរណ៍**ព្រះសីហនុ**មិនបានចាត់វិធានការណាមួយដើម្បីការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ចំនួនបីនាក់ ក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេត។ នៅខែធ្នូ ឆ្នាំ២០២២ តំណាងមកពីតុលាការនេះបានលើកឡើងថា នៅក្នុងសំណុំរឿងរំលោភសេពសន្ថវៈ ឬប្រទូស្តកេរខ្មាស ជាទូទៅចៅក្រមបន្តដំណើរការនីតិវិធីដោយសវនាការជាអសាធារណៈ និងប្រើប្រាស់វនាំងដើម្បីការពារឯកជនភាពរបស់កុមាររងគ្រោះ។ ទោះជាយ៉ាងនេះក្ដី ការធ្វើបែបនេះគឺអាស្រ័យលើការសម្រេចរបស់ចៅក្រម ដោយសារតែប្រការនេះមិនមែនជាលក្ខខណ្ឌតម្រូវដោយច្បាប់នោះទេ។ [191] នៅខែមីនា ឆ្នាំ២០២៣ មន្ត្រីតុលាការបានកត់សម្គាល់ថា តុលាការខ្វះខាតឧបករណ៍ និងបរិក្ខារ ដូចជាវនាំងដើម្បីការពារឯកជនភាពរបស់អនីតិជននៅអំឡុងពេលសវនាការ។[192]

សាលាឧទ្ធរណ៍**បាត់ដំបង** បានធ្វើសវនាការជាអសាធារណៈសម្រាប់កុមារទំនាស់នឹងច្បាប់ចំនួន ៨៥,៧% (ចំនួន ១២ នាក់ក្នុងចំណោម ១៤ នាក់) ក្នុងសំណុំរឿងដែល ម.ស.ម.ក បានសង្កេត។ នៅខែមីនា ឆ្នាំ២០២៣ តំណាងនៃតុលាការនេះបានលើកឡើងថា ជាទូទៅចៅក្រមអនុវត្តដំណើរការនីតិវិធីសវនាការជាអសាធារណៈនៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទជាកុមារ ប៉ុន្តែបានកត់សម្គាល់ថា តុលាការមិនមាន

---

[190] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

[191] នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[192] នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងមកពីសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

នាំងការពារឯកជនភាពគ្រប់គ្រាន់នោះទេ។[193] នៅខែសីហា ឆ្នាំ២០២៣ តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានកត់សម្គាល់ថា ចំពោះកិច្ចការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ តុលាការកំពុងពង្រឹងលើកិច្ចការនេះ។[194]

សាលាឧទ្ធរណ៍**ត្បូងឃ្មុំ**បានដំណើរការសវនាការជាអសាធារណៈសម្រាប់គ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នៅអំឡុងពេលធ្វើរបាយការណ៍នេះ ដោយអនុលោមតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ដូច្នេះ អាចនិយាយបានថា តុលាការបានចាត់វិធានការចាំបាច់ដើម្បីការពារឯកជនភាពរបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី ដោយសារតែ ម.ស.ម.ក មិនអាចសង្កេតសវនាការអសាធារណៈទាំងនេះបាន ចំណុចនេះមិនអាចត្រូវបានវាយតម្លៃថាតើសិទ្ធិផ្សេងទៀតដែលបានលើកឡើងនៅក្នុងផ្នែកនេះ ត្រូវបានតុលាការគោរពពេញលេញដែរ ឬយ៉ាងណា។

193 នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងមកពីសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

194 នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញនៃរបាយការណ៍របស់ ម.ស.ម.ក។

## ៦. ២០១៤-២០២២៖ ការវិវឌ្ឍនៃការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍ភ្នំពេញ

ផ្នែកនេះបង្ហាញអំពីនិន្នាការសំខាន់ៗ ទាក់ទងនឹងការគោរពបទដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិដោយសាលាឧទ្ធរណ៍**ភ្នំពេញ** នៅអំឡុងពេលធ្វើរបាយការណ៍ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២២។[195] ម.ស.ម.ក នៅមិនទាន់អាចធ្វើការវិភាគដូចគ្នាសម្រាប់សាលាឧទ្ធរណ៍ទាំងបីផ្សេងទៀតបានទេ ដោយសារតែសកម្មភាពសង្កេតសវនាការពាក់ព័ន្ធទើបតែចាប់ផ្តើមនៅឆ្នាំ២០២២ នេះប៉ុណ្ណោះ។

**សិទ្ធិក្នុងការនិយាយជាមួយមេធាវីនៅមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី៖** សិទ្ធិនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីដែល ម.ស.ម.ក បានសង្កេត ត្រូវបានគោរពយ៉ាងខ្ជាប់ខ្ជួនចាប់តាំងពីឆ្នាំ២០១៤។ ដូចបានបង្ហាញនៅតារាងខាងក្រោមក្នុងចំណោមសំណុំរឿងចំនួន ៩៨% ដែលបានសង្កេតមិនមានអ្វីដែលបង្ហាញថា មេធាវីរបស់ជនជាប់ចោទត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះទេ។[196]

ដូចគ្នានេះដែរ ជនជាប់ចោទចំនួនតែបួននាក់ប៉ុណ្ណោះក្នុងចំណោមជនជាប់ចោទទាំងអស់ពាក់ព័ន្ធនឹងសំណុំរឿង ដែលបានសង្កេតចាប់តាំងពីឆ្នាំ២០១៤ ត្រូវបានមេធាវីការពារក្តីលើកឡើងពីបញ្ហាពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ដែលធ្វើឱ្យសិទ្ធិនេះត្រូវបានតុលាការគោរពយ៉ាងទូលំទូលាយ។[197]

[195] សូមកត់សម្គាល់ថា គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក ត្រូវបានផ្អាកជាបណ្តោះអាសន្ននៅចន្លោះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦។ ជាលទ្ធផល មិនមានទិន្នន័យណាមួយអាចស្វែងរកបានសម្រាប់អំឡុងពេលនេះទេ។

[196] ទិន្នន័យនេះផ្អែកលើសំណុំរឿងដែលបានសង្កេត ដែលជនជាប់ចោទមានមេធាវីការពារ៖ ជនជាប់ចោទចំនួន ១៤៩ នាក់(ក្នុងចំណោម ១៦១ នាក់) នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៤៤៣ នាក់ (ក្នុងចំណោម ៥៦២ នាក់) នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៤១ នាក់ (ក្នុងចំណោម ៣១៥ នាក់) នៅឆ្នាំ២០១៧/២០១៨, ជនជាប់ចោទចំនួន ២៦២ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០១៨/២០១៩, ជនជាប់ចោទចំនួន ៥៣ នាក់ (ក្នុងចំណោម ១១៨ នាក់) នៅឆ្នាំ២០២១ និង ជនជាប់ចោទចំនួន ២៦៦ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០២២។

[197] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលមានវត្តមាន និង/ឬមានមេធាវីការពារ៖ ជនជាប់ចោទចំនួន ១៤៩ នាក់ (ក្នុង ចំណោម ១៦១ នាក់) នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៤៤៣ នាក់ (ក្នុងចំណោម ៥៦២ នាក់) នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៤១ នាក់ (ក្នុងចំណោម ៣១៥ នាក់) នៅឆ្នាំ២០១៧/២០១៨, ជនជាប់ចោទចំនួន ២៦២ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០១៨/២០១៩, ជនជាប់ចោទចំនួន ៨៩ នាក់ (ក្នុងចំណោម ១១៨ នាក់) នៅឆ្នាំ២០២១ និងជនជាប់ចោទចំនួន ២៨៨ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០២២។

### *តួលេខទី ២៥៖ ការវិវឌ្ឍនៃសិទ្ធិនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ (ឆ្នាំ២០១៤-២០២២)*[198]




**សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ៖** ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២២ សេចក្តីសម្រេចត្រូវបានប្រកាសជាសាធារណៈនៅគ្រប់សំណុំរឿងទាំងអស់ ដែលបានសង្កេត។[199]

**សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស៖** បន្ទាប់ពីត្រូវបានចាត់ចូលថាជាសិទ្ធិដែលត្រូវបានគោរពពេញលេញនៅឆ្នាំ២០១៤/២០១៥ [200] សិទ្ធិនេះបានប្តូរទៅជាសិទ្ធិ ដែលមិនទាន់ត្រូវបានគោរពពេញលេញនៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៦/២០១៧ ហើយចាប់តាំងពីពេលនោះមក សិទ្ធិនេះនៅតែស្ថិតក្នុងចំណាត់ថ្នាក់នេះដដែល។ ទោះជាមិនមានសំណុំរឿងដែលបានសង្កេតចាប់តាំងឆ្នាំ២០១៤ ដែលចៅក្រមបានធ្វើសេចក្តីថ្លែងការណ៍ណាមួយអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ មុនពេលចេញសេចក្តីសម្រេច និងមិនមាន

---

[198] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលមានមេធាវីការពារ៖ ជនជាប់ចោទចំនួន ១៤៩ នាក់ (ក្នុងចំណោម ១៦១ នាក់) នៅឆ្នាំ២០១៤/២០១៥, ជនជាប់ចោទចំនួន ៤៤៣ នាក់ (ក្នុងចំណោម ៥៦២ នាក់) នៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៤១ នាក់ (ក្នុងចំណោម ៣១៥ នាក់) នៅឆ្នាំ២០១៧/២០១៨, ជនជាប់ចោទចំនួន ២៦២ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០១៨/២០១៩, ជនជាប់ចោទចំនួន ១៨៣ នាក់ (ក្នុងចំណោម ២៥៥ នាក់) នៅឆ្នាំ២០១៩/២០២០, ជនជាប់ចោទចំនួន ៨៩ នាក់ (ក្នុងចំណោម ១១៨ នាក់) នៅឆ្នាំ២០២១ និងជនជាប់ចោទចំនួន ២៦៦ នាក់ (ក្នុងចំណោម ៣៥២ នាក់) នៅឆ្នាំ២០២២។

[199] ទិន្នន័យនេះផ្អែកលើសំណុំរឿងទាំងអស់ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥, ២៥២ សំណុំរឿង (ក្នុងចំណោម ៣៤១ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧, ៩៥ សំណុំរឿង (ក្នុងចំណោម ២១៣ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ ២០១៧/២០១៨, ៩៩ សំណុំរឿង (ក្នុងចំណោម ២៣៩ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩, ២១ សំណុំរឿង (ក្នុងចំណោម ២០៣ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០, ២១ សំណុំរឿង (ក្នុងចំណោម ៨៥ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ២០២១ និង ៤៨ សំណុំរឿង (ក្នុងចំណោម ២៥៧ សំណុំរឿង) ដែលបានសង្កេតនៅឆ្នាំ២០២២។

[200] នៅឆ្នាំ២០១៤/២០១៥ ទិន្នន័យដែលទាក់ទងនឹងការប្រាប់ និងការពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទពីសំណាក់ចៅក្រមមិនត្រូវបានរាប់បញ្ចូលទៅក្នុងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសនោះទេ ប៉ុន្តែនៅក្នុងប្រភេទចំណាត់ថ្នាក់ផ្សេងគ្នាដែលទាក់ទងនឹងការពន្យល់ប្រាប់សិទ្ធិ។

ជនជាប់ចោទណាម្នាក់ត្រូវបានដាក់ខ្នោះនៅពេលសវនាការក៏ដោយ [201] នៅមានកត្តាជាច្រើនដែលបញ្ជាក់ថាសិទ្ធិនេះត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញ។

ជាការពិតណាស់ ចាប់តាំងពីឆ្នាំ ២០១៤ មក ចៅក្រមមិនបានប្រាប់ ឬពន្យល់ដល់ជនជាប់ចោទទាំងអស់អំពីសិទ្ធិនៅស្ងៀមនោះទេ។ ទោះបីជាយ៉ាងនេះក្តី មានការកត់សម្គាល់ពីនិន្នាការវិជ្ជមាននៅអំឡុងពេលធ្វើរបាយការណ៍នីមួយៗ ដោយមានការធ្លាក់ចុះនៅចន្លោះពេលធ្វើរបាយការណ៍នេះ និងនៅអំឡុងពេលធ្វើរបាយការណ៍ចុងក្រោយ ដូចបានបង្ហាញនៅតួលេខខាងក្រោម។ ទោះបីជាចៅក្រមបានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទនៅត្រឹមតែចំនួន ៦,៣% នៃសំណុំរឿង ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ ក្តី ចៅក្រមក៏បានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមក្នុងចំណោមសំណុំរឿងចំនួន ២៥,៧% នៃសំណុំរឿង ដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍នេះផងដែរ។ នៅពេលប្រៀបធៀបទៅនឹងសំណុំរឿងចំនួន ៤៤,៧% ដែលបានសង្កេតនៅឆ្នាំ២០២១ បានសង្កេតឃើញថាមានការថយចុះគួរឱ្យកត់សម្គាល់នៅឆ្នាំ ២០២២។ ទោះបីជាមានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ក៏ដោយ ការប្រាប់ និងពន្យល់របស់តុលាការអំពីសិទ្ធិជាមូលដ្ឋាននេះដល់ជនជាប់ចោទនៅតែមិនគ្រប់គ្រាន់ ដែលធ្វើឱ្យប៉ះពាល់ដល់ការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ។

[201] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុបពាក់ព័ន្ធនឹងសំណុំរឿង ដែលបានសង្កេតនៅអំឡុងពេលធ្វើរបាយការណ៍នីមួយៗ៖ ជនជាប់ចោទចំនួន ១៦១ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ ជនជាប់ចោទចំនួន ៥៥៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ ជនជាប់ចោទចំនួន ៣១៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ ជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ ជនជាប់ចោទចំនួន ២៥៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ ២០១៩/២០២០ ជនជាប់ចោទចំនួន ១១៨ នាក់ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ ២០២១ និងជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

### *តួលេខទី ២៦៖ ការប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀម (ឆ្នាំ២០១៤-២០២២)*[202]




បន្ថែមពីនេះ ជនជាប់ចោទបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិត តាំងពីឆ្នាំ ២០១៤[203] ដែលបញ្ជាក់បន្ថែមថា សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញ។ ដូចបានបង្ហាញនៅតួលេខខាងក្រោម ទិន្នន័យនេះបង្ហាញថា ទោះបីជាមានជនជាប់ចោទចំនួន ៥,៤% បានបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារសម្រាប់ទណ្ឌិតនៅឆ្នាំ ២០១៤/២០១៥ ក្តី ប៉ុន្តែចំនួន ១៨,៨% បានបង្ហាញខ្លួនបែបនេះនៅឆ្នាំ២០២២។ ប្រការនេះគឺមានភាពប្រសើរឡើងបន្តិចបន្តួចបើធៀបនឹងឆ្នាំ២០២១ ខណៈដែលចំនួន ១៩,៥% នៃជនជាប់ចោទបានបង្ហាញខ្លួនក្នុងឯកសណ្ឋានទណ្ឌិត។

---

[202] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ ២០១៨/២០១៩ សំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ សំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ ២០២១ និងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

[203] ឯកសណ្ឋានពណ៌ទឹកក្រូចចាស់សម្រាប់ជនជាប់ឃុំរង់ចាំសវនាការ ត្រូវបានណែនាំកាលពីចុងឆ្នាំ២០១៣ ដោយបង្ហាញពីភាពខុសគ្នារវាងពួកគេជាមួយទណ្ឌិតដែលមានឯកសណ្ឋានពណ៌ខៀវ។

*តួលេខទី ២៧៖ ភាគរយនៃជនជាប់ចោទដែលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានទណ្ឌិត (ឆ្នាំ២០១៤-២០២២)*[204]




**សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់៖** ទោះបីជាត្រូវបានចាត់ទុកថាមានការ គោរព នៅអំឡុងពេលធ្វើបាយការណ៍ឆ្នាំ២០១៤/២០១៥ និង ឆ្នាំ២០១៦/២០១៧ ក៏ដោយ សិទ្ធិនេះត្រូវបាន ចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញតាំងពីពេលនោះមក។ ដូចបានបង្ហាញនៅតួលេខខាងក្រោម មាន ការថយចុះជារួមនៅគ្រប់ផ្នែកទាំងអស់ដែលបានវាស់ស្ទង់ ជាពិសេសលើភាគរយនៃសំណុំរឿងដែលចៅក្រម បានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជាប់ចោទទាំងអស់ ច្បាប់ពាក់ព័ន្ធ ឬទីកន្លែងនៃបទ ល្មើសកើតឡើង។ អ្វីដែលគួរផ្តោតនោះគឺនៅអំឡុងពេលធ្វើបាយការណ៍នេះ ឃើញមានការធ្លាក់ចុះគួរឱ្យកត់ សម្គាល់ចំពោះភាគរយនៃសំណុំរឿងដែលចៅក្រមបានអានប្រាប់អំពីកាលបរិច្ឆេទនៃបទល្មើស ច្បាប់ពាក់ព័ន្ធ និងបទចោទប្រកាន់ទាំងអស់ នៅពេលប្រៀបធៀបទៅនឹងឆ្នាំ២០២១។

---

[204] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេត ដែលមានវត្តមាននៅពេលសវនាការ និងជាប់ ពន្ធនាគារ៖ ជនជាប់ចោទក្នុងចំណោម ១៦១ នាក់នៅឆ្នាំ២០១៤/២០១៥ ជនជាប់ចោទចំនួន ៣៥៦ នាក់ក្នុងចំណោម ៥៥៨ នាក់នៅ ឆ្នាំ២០១៦/២០១៧ ជនជាប់ចោទចំនួន ២៤៩ នាក់ក្នុងចំណោម ៣១៥ នាក់នៅឆ្នាំ២០១៧/ ២០១៨ ជនជាប់ចោទចំនួន ២៥៤ នាក់ ក្នុងចំណោម ៣៥២ នាក់នៅឆ្នាំ២០១៨/២០១៩ ជនជាប់ចោទចំនួន ២២១ នាក់ក្នុងចំណោម ២៥៥ នាក់នៅឆ្នាំ ២០១៩/២០២០ ជន ជាប់ចោទចំនួន ៨៩ នាក់ក្នុងចំណោម ១១៨ នាក់នៅឆ្នាំ២០២១ និងជនជាប់ចោទ ២៦៦ នាក់ក្នុងចំណោម ៣៥២ នាក់នៅឆ្នាំ ២០២២។

*តួលេខទី ២៨៖ ការវិវឌ្ឍនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ (ឆ្នាំ២០១៤-២០២២)*[205]




**សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ៖** ចំនួនភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារនៅពេលសវនាការរបស់ពួកគេបានថយចុះជាលំដាប់ចាប់តាំងពីឆ្នាំ២០១៤/២០១៥ រហូតដល់ឆ្នាំ ២០១៩/២០២០ ដោយមានភាពល្អប្រសើរបន្តិចសម្រាប់អំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០២១ និងឆ្នាំ ២០២២។ ចំនួននេះបានបង្ហាញនៅតួលេខខាងក្រោម និងគូសបញ្ជាក់ឱ្យឃើញថា សិទ្ធិមានមេធាវីមិនទាន់ត្រូវបានគោរពពេញលេញនោះទេ។ ដូចគ្នានេះដែរ សិទ្ធិមានវត្តមាននៅពេលសវនាការមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយមានជនជាប់ចោទចន្លោះពីចំនួន ១០% និង ២៧% ដែលអវត្តមាននៅពេលសវនាការនៅក្នុងសំណុំរឿងដែលបានសង្កេតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២២។

[205] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ សំណុំរឿងចំនួន២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ សំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ សំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ និងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

*តួលេខទី ២៩៖ ការវិវឌ្ឍនៃសិទ្ធិមានមេធាវី (ឆ្នាំ២០១៤-២០២២)*[206]




*តួលេខទី ៣០៖ ការវិវឌ្ឍនៃសិទ្ធិមានវត្តមាននៅពេលសវនាការ (ឆ្នាំ២០១៤-២០២២)*[207]

| តើជនជាប់ចោទមានវត្តមាននៅពេលសវនាការដែរ ឬទេ? | មាន | គ្មាន |
|---|---|---|
| ឆ្នាំ២០១៤/២០១៥ | ៧៩,០% | ២១,០% |
| ឆ្នាំ២០១៦/២០១៧ | ៧២,៤% | ២៧,៦% |
| ឆ្នាំ២០១៧/២០១៨ | ៨២,៥% | ១៧,៥% |

---

[206] ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ១៣៥ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ១៦១ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ ជនជាប់ចោទចំនួន ៤៣៩ ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ៥៥៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ ជនជាប់ចោទចំនួន ២៤១ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ ជនជាប់ចោទចំនួន ២៦២ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ ជនជាប់ចោទចំនួន ១៨៣ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ២៥៥នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ និងជនជាប់ចោទចំនួន ៨៩ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ១១៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ ជនជាប់ចោទចំនួន ២៦៦ នាក់ដែលមានមេធាវីការពារក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

[207] ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ១២៩ នាក់ ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១៦១ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ ជនជាប់ចោទចំនួន ៤០៤ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៥៥៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ ជនជាប់ចោទចំនួន ២៦០ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ ជនជាប់ចោទចំនួន ២៨៤ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ ជនជាប់ចោទចំនួន ២៣០ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ និងជនជាប់ចោទចំនួន ៩៨ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១១៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ និងជនជាប់ចោទចំនួន ២៨៨ នាក់ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

| | | |
|---|---|---|
| ឆ្នាំ២០១៨/២០១៩ | ៨០,៧% | ១៩,៣% |
| ឆ្នាំ២០១៩/២០២០ | ៩០,២% | ៩,៨% |
| ឆ្នាំ២០២១ | ៨៣,១% | ១៦,៩% |
| ឆ្នាំ២០២២ | ៨១,៨% | ១៨,២% |

**សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង៖** ជនជាប់ចោទមួយចំនួនបានអះអាងថាធ្លាប់ទទួលរងអំពើហិង្សា ឬការធ្វើទារុណកម្មពីសំណាក់អាជ្ញាធរដើម្បីបង្ខំពួកគេឱ្យឆ្លើយសារភាពនៅអំឡុងពេលធ្វើរបាយការណ៍ទាំងអស់។ ដូចបានឃើញនៅខាងក្រោម ភាគរយនៃជនជាប់ចោទដែលត្រូវបានបង្ខំមានចន្លោះពី ២,៥% ទៅ ២,៧% ដោយមានការថយចុះបន្តិចនៅឆ្នាំ២០២២ បើធៀបទៅនឹងឆ្នាំ២០២១។ ការលើកឡើងអំពីការគំរាមកំហែង ឬអំពើហិង្សាដែលកើតមានចាប់តាំងពីឆ្នាំ២០១៤ ផ្តល់នូវ ហេតុផលដល់ការចាត់ចំណាត់ថ្នាក់សិទ្ធិនេះថាមិនទាន់ត្រូវបានគោរពពេញលេញ។

*តួលេខទី ៣១៖ ការវិវឌ្ឍនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព (ឆ្នាំ២០១៤-២០២២)*[208]




**សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ៖** គួរកត់សម្គាល់ថា នៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ ២០២២ មានតែសវនាការចំនួនមួយប៉ុណ្ណោះដែលបានសង្កេត ដែលសាធារណជន ឬប្រព័ន្ធផ្សព្វផ្សាយត្រូវបានរារាំងមិនឱ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការ។ ទោះបីជាយ៉ាងនេះក្តី សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

[208] ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ៧ នាក់ដែលបានលើកឡើងថាមានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មដើម្បីបង្ខិតបង្ខំពួកគេឱ្យសារភាពអំពីបទល្មើសដែលត្រូវបានចោទប្រកាន់ក្នុងចំណោមជនជាប់ចោទចំនួន ១៦១ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ ជនជាប់ចោទចំនួន ៤០ នាក់បានលើកឡើងដូចគ្នាក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ ជនជាប់ចោទចំនួន ១៥ នាក់ដែលបានលើកឡើងដូចគ្នាក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ ជនជាប់ចោទចំនួន ១៧ នាក់ដែលបានលើកឡើងដូចគ្នាក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ ជនជាប់ចោទចំនួន ៣ នាក់ដែលបានលើកឡើងដូចគ្នាក្នុងចំណោមជនជាប់ចោទចំនួន ១១៨ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ ជនជាប់ចោទចំនួន ១៣ នាក់ដែលបានលើកឡើងដូចគ្នាក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

ត្រូវបានចាត់ទុកថាមិនទាន់ត្រូវបានគោរពពេញលេញចាប់ពីឆ្នាំ២០១៤ មក។ អំឡុងពេលធ្វើរបាយការណ៍ថ្មីៗចំនួនបី បានបង្ហាញឱ្យឃើញអំពីភាពល្អប្រសើរចំពោះចំនួនសំណុំរឿងដែលតុលាការបានបិទកាលវិភាគសវនាការនៅខាងក្រៅបន្ទប់សវនាការ ដោយបន្ទាប់ពីអំឡុងពេលធ្វើរបាយការណ៍ចំនួនបីជាប់ៗគ្នា (ឆ្នាំ២០១៦/២០១៧, ឆ្នាំ២០១៧/២០១៨ និង ឆ្នាំ២០១៨/២០១៩) ដែលនៅអំឡុងពេលនេះមិនមានការបិទផ្សាយអ្វីទាំងអស់។[209] ទោះជានៅអំឡុងពេលធ្វើរបាយការណ៍ ទិន្នន័យនៃការបិទកាលវិភាគសវនាការ បានបង្ហាញពីការថយចុះគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងឆ្នាំ២០២១ ក៏ដោយ គួរសម្គាល់ថា តុលាការបានផ្សាយកាលវិភាគសវនាការនៅលើប្រព័ន្ធអនឡាញ នៅក្នុងសំណុំរឿងចំនួន ៦៧,៧% នៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេត។

*តួលេខទី ៣២៖ ការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ (ឆ្នាំ២០១៤-២០២២)*[210]




**សិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ៖** ការគោរពសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុនៅតែមានបញ្ហានៅអំឡុងពេលធ្វើរបាយការណ៍ទាំងអស់កន្លងមក។ ទោះបីជាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅឆ្នាំ២០១៨/២០១៩ នៅពេលដែលសេចក្ដីសម្រេចមិនបានអានសំអាងហេតុត្រូវបានប្រកាសត្រឹមតែចំនួន ៤៧,៥% នៃសំណុំរឿងប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងចំនួន ៨៧,៤% នៅឆ្នាំ២០១៧/២០១៨ និងចំនួន ៨៤,៦% នៅឆ្នាំ២០១៤/២០១៥ ក៏ដោយ ភាពប្រសើរឡើងនេះមានរយៈពេលខ្លី ដោយសារតែអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ សេចក្ដីសម្រេចចំនួន ៦៦,៥% ត្រូវបានប្រកាសដោយមិនបានអានសំអាងហេតុ និងកើនឡើងដល់ ៩០% នៅឆ្នាំ២០២១។ តួលេខនេះនៅតែមានកម្រិតខ្ពស់នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ដោយមានសំណុំរឿងចំនួន ៨១,២៥% មានសេចក្ដីសម្រេចដែលមិនបានអានសំអាងហេតុ។

---

[209] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ សំណុំរឿងចំនួន២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ សំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ សំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ និងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

[210] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ សំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ សំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ សំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ សំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០ សំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១ និងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។

**សិទ្ធិបង្ហាញភស្តុតាង៖** ចាប់ពីឆ្នាំ២០១៤ មក ម.ស.ម.ក បានផ្ដោតជានិច្ចលើគុណភាពនៃភស្តុតាងដែលបានបង្ហាញនៅពេលសវនាការ ដែលជារឿយៗមានតម្លៃពុំទាន់ពេញលេញគ្រប់គ្រាន់។ ទោះបីជាយ៉ាងនេះក្ដី ចាប់ពីឆ្នាំ២០១៤ មក មានតែសំណុំរឿងមួយចំនួនតូចប៉ុណ្ណោះដែលបានបង្ហាញថា ភាគីមិនត្រូវបានផ្ដល់ឱកាសឱ្យហៅសាក្សី។ ទោះបីនេះជារបកគំហើញទាំងមូលមានភាពវិជ្ជមានក៏ដោយ ម.ស.ម.ក បានកត់សម្គាល់ឃើញថា នៅក្នុងសំណុំរឿងភាគច្រើនដែលសាក្សីត្រូវបានកោះហៅ ពួកគេមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលពួកគេត្រូវបានសាកសួរ។ ការអនុវត្តបែបនេះអាចនាំឱ្យសក្ខីកម្មរបស់សាក្សីរងការប៉ះពាល់នៅពេលដែលស្ដាប់ចម្លើយរបស់អ្នកដទៃ។

**សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់៖** ចាប់ពីឆ្នាំ២០១៤ មក សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ ដែលគួរត្រូវបានផ្ដល់កិច្ចការពារជាពិសេសតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជា បានយកចិត្តទុកដាក់មិនទាន់គ្រប់ជ្រុងជ្រោយឡើយ៖ កុមារភាគច្រើនត្រូវបានបន្តឃុំខ្លួន ហើយនៅក្នុងសំណុំរឿងភាគច្រើន មិនមានការចាត់វិធានការដើម្បីការពារភាពឯកជនរបស់កុមារទំនាស់នឹងច្បាប់នៅអំឡុងពេលសវនាការនោះទេ។ លើសពីនេះ ការផ្ដន្ទាទោសដាក់ពន្ធនាគារត្រូវបានអនុវត្តនៅក្នុងសំណុំរឿងភាគច្រើនពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ដែលបានសង្កេត តាមសេចក្ដីសម្រេចដែលបានស្ដាប់មក។[211]

*តួលេខទី ៣៣៖ ការវិវឌ្ឍនៃការប្រើប្រាស់ការឃុំខ្លួនចំពោះកុមារទំនាស់នឹងច្បាប់ (ឆ្នាំ២០១៤-២០២២)*[212]




[211] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់ដែលសាលដីកាត្រូវបានតាមដាន ឬស្ដាប់៖ កុមារទំនាស់នឹងច្បាប់ចំនួន ១១ នាក់នៅឆ្នាំ ២០១៤/២០១៥ កុមារទំនាស់នឹងច្បាប់ចំនួន ២៨ នាក់នៅឆ្នាំ២០១៦/២០១៧ កុមារទំនាស់នឹងច្បាប់ចំនួន ៣ នាក់នៅឆ្នាំ២០១៧/២០១៨ កុមារទំនាស់នឹងច្បាប់ចំនួន ៦ នាក់នៅឆ្នាំ២០១៨/២០១៩ និងកុមារទំនាស់នឹងច្បាប់ចំនួន ៦ នាក់នៅឆ្នាំ២០២២។

[212] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់ចំនួន ១១ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥ កុមារទំនាស់នឹងច្បាប់ចំនួន ៣៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧ កុមារទំនាស់នឹងច្បាប់ចំនួន ៩ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨ កុមារទំនាស់នឹងច្បាប់ចំនួន ២២ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩ កុមារទំនាស់នឹងច្បាប់ចំនួន ១៥ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ ២០១៩/២០២០ កុមារទំនាស់នឹងច្បាប់ចំនួន ៤ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០២១ កុមារទំនាស់នឹងច្បាប់ចំនួន ៦ នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតនៅឆ្នាំ២០២២។

# ៧. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សិទ្ធិសំខាន់ៗមួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានធានាដោយតុលាការទាំងបួន រួមទាំងសិទ្ធិនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសចក្តីសម្រេចជាសាធារណៈ។ គួរឱ្យសាទរទាំងនៅសាលាឧទ្ធរណ៍**ព្រះសីហនុ** និងសាលាឧទ្ធរណ៍**ត្បូងឃ្មុំ** បានគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការយល់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ទន្ទឹមនេះដែរ សាលាឧទ្ធរណ៍**ត្បូងឃ្មុំ** និងសាលាឧទ្ធរណ៍**បាត់ដំបង** បានគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ។ ទោះជាយ៉ាងនេះក្តី ម.ស.ម.ក កត់សម្គាល់ឃើញថា តុលាការទាំងបួននៅមិនទាន់គោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ភាគច្រើន ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ។ ជាពិសេស ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន រួមទាំងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ផងដែរ ក៏ដូចជាការដែលជនជាប់ចោទចំនួនមួយភាគបីមិនមានមេធាវីការពារ នៅអំឡុងពេលធ្វើរបាយការណ៍នេះ។

ទោះបីជាសិទ្ធិមួយចំនួនត្រូវបានការពារយ៉ាងជាប់លាប់ដោយសាលាឧទ្ធរណ៍**ភ្នំពេញ** ចាប់ពីឆ្នាំ២០១៤មកក៏ដោយ សិទ្ធិមួយចំនួនទៀតមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដូចជាសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ សិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។ ប្រការនេះគួរឱ្យយកចិត្តទុកដាក់ផងដែរ ជាពិសេស ដោយសារតែបញ្ហាទាំងនេះត្រូវបានលើកឡើងដល់តុលាការជាច្រើនលើកច្រើនសារមកហើយ។ នៅពេលប្រៀបធៀបរបកគំហើញនៃរបាយការណ៍នេះជាមួយនឹងរបកគំហើញកាលពីឆ្នាំមុនៗ ភាគច្រើននៃរបកគំហើញមានលក្ខណៈស្រដៀងគ្នា រវាងសិទ្ធិដែលត្រូវបានគោរព និងសិទ្ធិមិនទាន់ត្រូវបានគោរពពេញលេញ។ ភស្តុតាងនេះបង្ហាញថា ទោះបីជាមានការធ្វើឱ្យប្រសើរឡើងនៃផ្នែកខ្លះក៏ដោយ ចាំបាច់ត្រូវមានវិធានការជាបន្ទាន់ ដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

សរុបមក បញ្ហាភាគច្រើនដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ អាចដោះស្រាយបានតាមរយៈវិធានការសាមញ្ញៗ ចំណាយតិច និងអនុវត្តបានរហ័ស។ ចំណុចផ្សេងទៀតអាចធ្វើការកែលម្អបានតាមរយៈការបណ្តុះបណ្តាលចៅក្រម និងមេធាវីអំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ តាមរយៈការអនុវត្តវិធានការនេះ ដើម្បីដោះស្រាយបញ្ហាទាំងនោះ តុលាការអាចកំណត់នូវយុត្តិសាស្ត្រធ្វើជាគំរូដល់សាលាដំបូង ដែលការធ្វើបែបនេះមានឥទ្ធិពលជាវិជ្ជមានដល់គុណភាពទាំងមូលនៃការគ្រប់គ្រងយុត្តិធម៌នៅកម្ពុជា និងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ។

## ៧.១. អនុសាសន៍រួម

៧.១.១ ក្រសួងយុត្តិធម៌គួររៀបចំកិច្ចប្រជុំជាទៀងទាត់ ស្តីពីការអនុវត្តជាក់ស្តែងនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមួយចៅក្រមសាលាឧទ្ធរណ៍ ដោយគោរពតាមគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ផ្អែកលើមូលដ្ឋាននៃបទដ្ឋានជាតិ និងអន្តរជាតិ។

៧.១.២ ក្រសួងយុត្តិធម៌គួរបង្កើតទម្រង់បទដ្ឋានសម្រាប់សេចក្តីសម្រេច និងបញ្ជូនទៅគ្រប់តុលាការទាំងអស់ដើម្បីអនុវត្ត។ ទម្រង់នេះគួរមានព័ត៌មានដូចខាងក្រោម ដើម្បីធានាថារបាយការណ៍សង្ខេបដែលចៅក្រមប្រធានក្រុមប្រឹក្សាអាន គឺមានភាពពេញលេញ៖ ១ បទល្មើសដែលបានចោទប្រកាន់លើជនជាប់ចោទ និងច្បាប់ពាក់ព័ន្ធ ២. កាលបរិច្ឆេទពេលវេលា ទីកន្លែងដែលបទល្មើសកើតឡើង និងភាគីពាក់ព័ន្ធ ៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិទទួលបាន។ ជាពិសេស ទម្រង់បទដ្ឋាននៃសេចក្តីសម្រេចគួររំឭកចៅក្រមអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់មានសេចក្តីសម្រេចជាស្ថាពរ និងអាជ្ញាអស់ជំនុំ និងប្រាប់ថាបន្ទុកនៃភស្តុតាងជារបស់ព្រះរាជអាជ្ញា។

៧.១.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីបទចោទប្រកាន់ និងសិទ្ធិរបស់ពួកគេដែរ ឬទេ។ ការខកខានក្នុងការអានព័ត៌មានខាងលើនៅពេលចាប់ផ្តើមការជំនុំជម្រះគួរបង្កើតបានជាហេតុផលនៃការប្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោស។

## ៧.២. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

៧.២.១ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួសជាជាងការឃុំខ្លួន រួមទាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[213] ដោយអនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (UN SDG) ចំណុច ១៦.៣.២ ដើម្បីធានាបាននូវការលើកលែងការឃុំខ្លួន និងសិទ្ធិមានសេរីភាពតាមច្បាប់។

៧.២.២ តុលាការត្រូវធានាថា ជនជាប់ចោទ ជាពិសេសជនជាប់ឃុំត្រូវបាននាំយកមកជំនុំជម្រះភ្លាមៗ តាមដែលអាចធ្វើទៅបាន និងដែលការពន្យារពេលដោយគ្មានហេតុផល ធ្វើឱ្យប៉ះពាល់ដល់ការផ្តល់យុត្តិធម៌ឆាប់រហ័ស។

---

[213] SRSHRC សេចក្តីថ្លែងការណ៍ស្តីពីការបញ្ចប់បេសកកម្ម (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨) ទំព័រ ៤។

## ៧.៣. អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព

៧.៣.១ តុលាការត្រូវតែស៊ើបអង្កេតភ្លាមៗ និងដោយហ្មត់ចត់លើការលើកឡើងរបស់ជនជាប់ចោទអំពីការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាពអំពីពិរុទ្ធភាពមុននឹងចេញសេចក្តីសម្រេច។

៧.៣.២ តុលាការត្រូវធានាថា ប្រសិនបើមានការលើកឡើងអំពីការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្មណាមួយ បន្ទាប់ពីធ្វើការស៊ើបអង្កេតរាល់ភស្តុតាង ឬចម្លើយសារភាពដែលទទួលបានតាមវិធីនេះគឺមិនអាចទទួលយកបានឡើយ ហើយត្រូវធ្វើការជំនុំជម្រះឡើងវិញលើករណីដែលពាក់ព័ន្ធ ហើយធានាឱ្យមានការជួសជុលសំណងសមរម្យដល់ជនរងគ្រោះ។

## ៧.៤. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

៧.៤.១ តុលាការ និងក្រសួងយុត្តិធម៌គួរធានាថា គ្រប់កាលវិភាគសវនាការប្រចាំថ្ងៃត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធអនឡាញ និងបិទផ្សាយនៅលើក្តារខៀនព័ត៌មាននៅខាងក្រៅបន្ទប់សវនាការយ៉ាងហោចណាស់ ២៤ ម៉ោងមុនពេលសវនាការ និងបន្តធានាថា សាធារណជនអាចចូលទៅកាន់បន្ទប់សវនាការនៅគ្រប់សំណុំរឿងទាំងអស់ លើកលែងតែករណីពិសេស ដែលរាប់បញ្ចូលទាំងសំណុំរឿងកុមារផងដែរ។ នៅពេលដែលព័ត៌មានទាំងនេះត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធអនឡាញ និងបិទនៅលើក្តារខៀនព័ត៌មាន ឈ្មោះរបស់កុមារមិនគួរបង្ហាញនោះទេ ផ្ទុយមកវិញអាចដាក់ឈ្មោះជាអក្សរកាត់ដើម្បីការពារភាពឯកជនរបស់កុមារ។

## ៧.៥. អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៧.៥.១ ចៅក្រមគួរប្រាប់ជនជាប់ចោទអំពីការចោទប្រកាន់លើពួកគេ និងផ្តល់ព័ត៌មានពាក់ព័ន្ធនានាដូចជាកាលបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងច្បាប់ជាធរមាន។ ប្រការនេះមានសារៈសំខាន់ជាពិសេសក្នុងករណីដែលបទចោទប្រកាន់អាចត្រូវបានប្តូរ ឬកែចាប់តាំងពីពេលចាប់ខ្លួន/ចោទប្រកាន់ដំបូង។ ចៅក្រមគួរយកចិត្តទុកដាក់ជាពិសេស ដោយធានាថាបានចែករំលែកព័ត៌មានអំពីច្បាប់ពាក់ព័ន្ធ និងទីកន្លែងនៃបទល្មើស។

៧.៥.២ ចៅក្រមគួរផ្តល់ការពន្យល់ឱ្យបានគ្រប់ជ្រុងជ្រោយអំពីសិទ្ធិទទួលបានជំនុំជម្រះរបស់ជនជាប់ចោទ។

៧.៥.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីបទចោទប្រកាន់មកលើពួកគេ និងសិទ្ធិរបស់ពួកគេដែរ ឬទេ។

## ៧.៦. អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិមានមេធាវី

៧.៦.១ តុលាការ និងអគ្គនាយកដ្ឋានពន្ធនាគារ គួរពិគ្រោះយោបល់ និងសម្របសម្រួលគ្នា ដើម្បីដោះស្រាយបញ្ហាភស្តុភារ និងទំនាក់ទំនងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានទាក់ទងនឹងទីតាំងរបស់ជនជាប់ចោទ។

៧.៦.២ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ព័ត៌មានអំពីការផ្ទេរជនជាប់ឃុំ គឺត្រូវបានបញ្ជូនជាទៀងទាត់ទៅកាន់មហាអយ្យការ ដើម្បីធានាថាតុលាការនឹងផ្តល់ព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលានៃសវនាការលើបណ្តឹងឧទ្ធរណ៍ទៅដល់មណ្ឌលអប់រំកែប្រែ ដែលឃុំខ្លួនជនជាប់ចោទឱ្យបានត្រឹមត្រូវ។

៧.៦.៣ ចៅក្រមគួរពន្យារពេលសវនាការណាមួយ ប្រសិនបើជនជាប់ចោទមិនមានវត្តមាន ទោះបីជាពួកគេមានមេធាវីការពារក៏ដោយ លុះត្រាតែពួកគេបានលះបង់សិទ្ធិមានវត្តមានជាផ្លូវការ និងច្បាស់លាស់។

៧.៦.៤ តុលាការគួរធានាថា មិនមានទំនាស់ផលប្រយោជន៍ដែលមិនសមស្របនោះទេ ក្នុងករណីដែលមេធាវីការពារឱ្យជនជាប់ចោទច្រើននាក់នៅពេលសវនាការ។

៧.៦.៥ ចៅក្រមគួរប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេ ប្រសិនបើពួកគេមិនមានមេធាវីការពារ។

៧.៦.៦ ក្រសួងយុត្តិធម៌គួរជូនដំណឹងដល់សាធារណជន អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដែលរដ្ឋជាអ្នករ៉ាប់រង រួមទាំងតាមរយៈការផ្សព្វផ្សាយនៅតាមការិយាល័យនគរបាល ពន្ធនាគារ និងអគារតុលាការផងដែរ។

## ៧.៧. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៧.៧.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទឱ្យបានច្បាស់ អំពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ រហូតទាល់តែមានសេចក្តីសម្រេចជាស្ថាពរ និងអំពីបន្ទុកនៃភស្តុតាងដែលជាភារកិច្ចរបស់ព្រះរាជអាជ្ញា ហើយជនជាប់ចោទមានសិទ្ធិនៅស្ងៀមដោយមិនប្រើប្រាស់ភាពនៅស្ងៀមនេះប្រឆាំងនឹងជនជាប់ចោទឡើយ។

៧.៧.២ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃគួរផ្សព្វផ្សាយអំពីគោលការណ៍ណែនាំច្បាស់លាស់ដែលបញ្ជាក់ថាជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬជនដែលទើបត្រូវបានជំនុំជម្រះដំបូង ប៉ុន្តែពុំទាន់មានសេចក្តីសម្រេចស្ថាពរ ត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្លៀកពាក់សម្លៀកបំពាក់ស៊ីវិលធម្មតា។

៧.៧.៣ ចៅក្រមគួរអនុញ្ញាតឱ្យជនជាប់ចោទ ដែលត្រូវបាននាំមកតុលាការក្នុងឯកសណ្ឋានទណ្ឌិត ស្លៀកពាក់ឯកសណ្ឋានស៊ីវិលរបស់ខ្លួនជំនួសវិញមុនពេលសវនាការ។

## ៧.៨. អនុសាសន៍ទាក់ទងនឹងការប្រតិបត្តិរបស់ចៅក្រម

៧.៨.១ ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរធ្វើការរួមគ្នាដើម្បីពិនិត្យឡើងវិញលើក្រមសីលធម៌ចៅក្រម និងធ្វើការកែសម្រួលតាមការចាំបាច់។ ការកែសម្រួលគួររាប់បញ្ចូលទាំងការហាមឃាត់ដាច់ខាតលើការប្រើប្រាស់ទូរស័ព្ទចល័ត និងអនុញ្ញាតឱ្យមានការសម្រាករយៈពេលខ្លី ដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងមេធាវីចាកចេញពីបន្ទប់សវនាការ ឬទទួលទូរស័ព្ទរបស់ខ្លួន។ ចៅក្រមក៏គួរធានាដែរថា ចៅក្រមបានបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការស្តាប់សវនាការរបស់ខ្លួន ដើម្បីធានាថា សំណុំរឿងរបស់ខ្លួនត្រូវបានជំនុំជម្រះបានត្រឹមត្រូវ និងដោយហ្មត់ចត់។

## ៧.៩. អនុសាសន៍ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាង

៧.៩.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទ អំពីសិទ្ធិបង្ហាញភស្តុតាងរបស់ពួកគេក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងការបង្ហាញភស្តុតាងប្រឆាំងនឹងពួកគេដែរ។

៧.៩.២ ចៅក្រមគួរបង្គាប់ឱ្យសាក្សីឱ្យចាកចេញពីបន្ទប់សវនាការ រហូតទាល់តែពួកគេត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម ទើបអាចត្រឡប់មកវិញបាន ដែលនេះជាមធ្យោបាយមួយដើម្បីធានាថា សាក្សីមិនរងឥទ្ធិពលពីភស្តុតាង និងសក្ខីកម្មផ្សេងទៀត ដែលបានបង្ហាញនៅពេលសវនាការ។

៧.៩.៣ ចៅក្រមត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្នថា តើភស្តុតាងដែលបានបង្ហាញមានលក្ខណៈហួសពីវិមតិសង្ស័យដែលថាជនជាប់ចោទមានពិរុទ្ធភាពដែរ ឬទេ។ ប្រសិនបើមានការបកស្រាយភស្តុតាងដែលស៊ីសង្វាក់គ្នានឹងភាពគ្មានទោសរបស់ជនជាប់ចោទ ដូច្នេះជនជាប់ចោទត្រូវតែបានឱ្យរួចទោស។

៧.៩.៤ ក្រសួងយុត្តិធម៌គួររៀបចំបង្កើតគោលការណ៍ណែនាំច្បាស់លាស់ទាក់ទងនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង ដោយផ្អែកលើការអនុវត្តរបស់ អ.វ.ត.ក [214] និងធានាថា ចៅក្រមទាំងអស់ទទួលបានការបណ្តុះបណ្តាលសមស្រប។

## ៧.១០. អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

៧.១០.១ ធានាថា សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយសរសេរអក្សរកាត់ក្នុងករណីចាំបាច់ ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬសម្រាប់ហេតុផលណាមួយផ្សេងទៀត។

[214] ការអនុវត្តរបស់ អ.វ.ត.ក អាចជាការណែនាំដ៏មានប្រយោជន៍ ជាពិសេសវិធានផ្ទៃក្នុងរបស់ខ្លួន ដូចជាវាក្យខណ្ឌ២០៤ ដល់ ២០៩ នៃសំណុំរឿងលេខ ០០២/០១ សាលដីកាសាលាឧទ្ធរណ៍ សូមមើល "សាលដីកាសាលាឧទ្ធរណ៍"; អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦) សំណុំរឿង/សំណុំរឿងកលេខ ០០២/១៩-០៩- ២០០៧-ECCC/SC, https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/F36_KH.pdf។

៧.១០.២ ដោយទាញយកការអនុវត្តរបស់ អ.វ.ត.ក[215] បង្កើតក្របខ័ណ្ឌមួយ ដែលចៅក្រមមានកាតព្វកិច្ចក្នុងការប្រាប់ និងពន្យល់អំពីសំអាងហេតុផ្លូវច្បាប់ និងភស្តុតាងនៅពីក្រោយសេចក្តីសម្រេចរបស់ខ្លួន ហើយធានាថា សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុត្រូវបានផ្តល់ជូនដល់ជនជាប់ចោទ។

## ៧.១១. អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់

៧.១១.១ ចៅក្រមគួរពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេសមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការជំនុំជម្រះ និងការប្រកាសសេចក្តីសម្រេចត្រូវធ្វើឡើងជាអសាធារណៈ។

៧.១១.២ ចៅក្រមគួរអនុវត្តតាមការអនុវត្តល្អរបស់ អ.វ.ត.ក និងអនុញ្ញាតឱ្យកុមារទំនាស់នឹងច្បាប់បង្ហាញខ្លួននៅចំពោះមុខតុលាការដោយស្លៀកពាក់សម្លៀកបំពាក់របស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់។

៧.១១.៣ ចៅក្រមគួរកម្រិតការឃុំខ្លួនកុមារទំនាស់នឹងច្បាប់ចំពោះតែករណីពិសេស នៅពេលដែលមិនមានជម្រើសផ្សេងទៀតប៉ុណ្ណោះ ហើយធានាថា ក្នុងករណីបែបនេះ រាល់វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្ត ដើម្បីគោរពសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ រួមទាំងការដាក់កុមារទាំងនោះឱ្យនៅដាច់ដោយឡែកពីជនជាប់ឃុំពេញវ័យផងដែរ។

៧.១១.៤ ក្រសួងយុត្តិធម៌គួរធានាថា ចៅក្រម និងព្រះរាជអាជ្ញាទទួលបានការបណ្តុះបណ្តាលជាក់លាក់ទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌កុមារ។

៧.១១.៥ ចៅក្រមគួរពិនិត្យ និងប្រើប្រាស់វិធានការមិនឃុំខ្លួនដល់កុមារទំនាស់នឹងច្បាប់ និងអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោសពាក់ព័ន្ធនឹងកុមារ ដែលត្រូវបានទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ ដែលការផ្តោតសំខាន់លើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោសតែម្យ៉ាង និងផ្តោតលើឧត្តមប្រយោជន៍របស់កុមារ។

៧.១១.៦ តុលាការគួរណែនាំអំពីវិធានទូទៅ ដែលសវនាការយុត្តិធម៌កុមារគួរត្រូវបានធ្វើឡើងជាអសាធារណៈ ដោយមានករណីលើកលែងដែលមានកម្រិតតាមច្បាប់កំណត់ ដើម្បីគោរពឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់។

៧.១១.៧ ក្នុងសំណុំរឿងនានាពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ ដែលធ្វើជាសាធារណៈ ត្រូវចាត់វិធានការដើម្បីការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ដូចជាការប្រើប្រាស់នាំងការពារឯកជនភាពជាដើម។

---

[215] សូមមើល ជាពិសេស "សាលដីកាសាលាឧទ្ធរណ៍", អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦, សំណុំរឿង/សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCe/SC, https://www.eccc.gov.kh/sites/default/files/documents/courtdoc/2016-11-23%2011:55/Case%20002_01%20Appeal%20Judgement.pdf។

សាលាឧទ្ធរណ៍**ភ្នំពេញ** គួរប្រើប្រាស់សវនាការតាមប្រព័ន្ធវីដេអូដែលតុលាការមាន នាពេលបច្ចុប្បន្ន ហើយធានាថា បុគ្គលិកនានាទទួលបានការបណ្ដុះបណ្ដាលសមស្រប។

៧.១១.៨ ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គួរអនុវត្តវិធានបង្វែរដែល តាមរយៈវិធាននេះ កុមារទំនាស់នឹងច្បាប់ទទួលបានជំនួយគាំទ្រ និងស្ដារនីតិសម្បទាចូលក្នុង សហគមន៍វិញ ដែលជាការបង្វែរមួយជំនួសឱ្យការកាត់ទោសជាផ្លូវការ។ វិធាននេះ ត្រូវអនុវត្តចំពោះ គ្រប់កុមារទំនាស់នឹងច្បាប់ទាំងអស់ ដែលប្រព្រឹត្តបទល្មើសដំបូង លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរ បំផុត ។

៧.១១.៩ ក្រសួងយុត្តិធម៌ ត្រូវពិនិត្យឡើងវិញលើច្បាប់ដែលមានស្រាប់ រួមទាំងច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅ របស់តុលាការ ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋានអន្តរជាតិស្ដីពីប្រព័ន្ធយុត្តិធម៌កុមារ រួម មានជាអាទិ៍ វិធានក្រុងប៉េកាំង គោលការណ៍ណែនាំរបស់អង្គការយូនីសេហ្វសម្រាប់កំណែទម្រង់ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន[216] សៀវភៅណែនាំការអនុវត្តរបស់អង្គការយូនីសេហ្វសម្រាប់អនុសញ្ញា ស្ដីពីសិទ្ធិកុមារ និងកំណែទម្រង់ច្បាប់របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្ដីពីការអនុវត្តអនុ សញ្ញាស្ដីពីសិទ្ធិកុមារ។[217] និងកំណែទម្រង់ច្បាប់របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្ដីពីការ អនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ។[218]

---

[216] អង្គការយូនីសេហ្វ "គោលការណ៍ណែនាំស្ដីពីកំណែទម្រង់ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន" https://www.un.org/ruleoflaw/files/Juvenile_justice_16052011_final.pdf ។

[217] អង្គការយូនីសេហ្វ ការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ ទំព័រ ១០៧, https://www.unicef.org/lac/media/22071/file/Implementation%20Handbook%20for%20the%20CRC.pdf ។

[218] អង្គការយូនីសេហ្វ "កំណែទម្រង់ច្បាប់ និងការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ" ទំព័រ ៨៧, http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf។

# ៨. ឯកសារគន្លិនិទ្ទេស

## ៨.១. ច្បាប់កម្ពុជា

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧)
https://sithi.org/tmp/publication/view/2007-09-03-criminal-procedure-code-of-the-kingdom-of-cambodia-2007

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម) https://sithi.org/laws/2008-02-19-constitution-of-the-kingdom-of-cambodia

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៩)
https://www.sithi.org/laws/2014-01-31-criminal-code-2014

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦)
https://sithi.org/laws/2016-06-29-law-on-juvenile-justice

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ (ឆ្នាំ២០១៤)
https://www.arbitrationcouncil.org/download/law-on-the-organization-of-courts/?wpdmdl=2883&refresh=6327e7fe849fc1663559678

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឆ្នាំ២០១៤)
https://www.arbitrationcouncil.org/download/law-on-the-organization-and-functioning-of-supreme-council-of-magistracy/?wpdmdl=2875&refresh=6327e88ba0c4c1663559819។

ច្បាប់ស្តីពីពន្ធនាគារនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១១)
http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Prison%20law%202011%20-%20ENG%20(unofficial%20translation).pdf

ច្បាប់ស្តីពីឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញា (ឆ្នាំ២០១៤)
https://www.arbitrationcouncil.org/download/law-on-the-status-of-judges-and-prosecutors/?wpdmdl=2879&refresh=6327e83233c621663559730

ប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពិរុទ្ធជន (ឆ្នាំ១៩៩៨)
https://sithi.org/tmp/publication/view/2010-10-01-proclamation-no-217-on-the-administration-of-prisons-1998

បទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធតុលាការ និងច្បាប់ និងនីតិវិធីព្រហ្មទណ្ឌដែលមានជាធរមាននៅកម្ពុជាក្នុងអំឡុងអន្តរកាល (ឆ្នាំ១៩៩២)
https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_11.pdf

## ៨.២. លិខិតូបករណ៍គោលនយោបាយកម្ពុជា

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ 'ផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ' (ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥)

ក្រសួងផែនការ "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣"
http://cdc-crdb.gov.kh/en/strategy/documents/nsdp-2019-2023_en.pdf
រាជរដ្ឋាភិបាលកម្ពុជា "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨"
www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/---sro-bangkok/documents/genericdocument/wcms_364549.pdf
ប្រកាសលេខ ០៩០ កយ.ប្រក/២១ ស្តីពីបែបបទនៃការឃ្លាំមើល ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមឡើងវិញនៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១) https://policypulse.org/wp-content/uploads/2021/07/Prakas_090_0721_MOJ_KH.pdf (មានជាភាសាខ្មែរតែប៉ុណ្ណោះ)។

## ៨.៣. ច្បាប់អន្តរជាតិ

### សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

មហាសន្និបាតអង្គការសហប្រជាជាតិ "អនុសញ្ញាស្តីពីសិទ្ធិកុមារ" (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) https://www.ohchr.org/Documents/ProfessionalInterest/crc.pdf
មហាសន្និបាតអង្គការសហប្រជាជាតិ "អនុសញ្ញាស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម " (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤) http://cambodia.ohchr.org/sites/default/files/Treaty/CAT-EN.pdf
មហាសន្និបាតអង្គការសហប្រជាជាតិ "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦) https://www.ohchr.org/en/professionalinterest/pages/ccpr.aspx
មហាសន្និបាតអង្គការសហប្រជាជាតិ "សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) http://www.un.org/en/universal-declaration-human-rights/index.html
សហភាពអាហ្វ្រិក 'ធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន' (ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១) https://au.int/sites/default/files/treaties/36390-treaty-0011_-_african_charter_on_human_and_peoples_rights_e.pdf
ក្រុមប្រឹក្សាអឺរ៉ុប "អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស" (ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥០) https://www.echr.coe.int/Documents/Convention_ENG.pdf
សហភាពអឺរ៉ុប 'ធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប' (ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០០) https://www.europarl.europa.eu/charter/pdf/text_en.pdf
អង្គការរដ្ឋអាមេរិក "អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស" (ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩) https://www.cidh.oas.org/basicos/english/basic3.american%20convention.htm

### លិខិតូបករណ៍អន្តរជាតិផ្សេងទៀត

អង្គការសហប្រជាជាតិ 'គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ' (អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំពីរស្តីពីការទប់ស្កាត់បទល្មើស និងប្រព្រឹត្តលើអ្នកទោសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងមីឡានពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៨៥) (អនុម័តដោយសេចក្តីសម្រេចរបស់

មហាសន្និបាតលេខ ៤០/៣២ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ១៩៨៥) https://www.ohchr.org/EN/ProfessionalInterest/Pages/IndependenceJudiciary.aspx

អង្គការសហប្រជាជាតិ 'គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី' (អនុម័តដោយសភាអង្គការសហប្រជាជាតិលើកទីប្រាំបីស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តលើអ្នកប្រព្រឹត្ត ក្រុងហាវ៉ាណា ប្រទេសគុយបា) (ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០) http://hrlibrary.umn.edu/instree/i3bprl.htm

មហាសន្និបាតអង្គការសហប្រជាជាតិ 'វិធានបទដ្ឋានអប្បបរមានៃការប្រព្រឹត្តលើជនជាប់ឃុំ' (ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៥៥) https://www.ohchr.org/EN/ProfessionalInterest/Pages/TreatmentOfPrisoners.aspx

មហាសន្និបាតអង្គការសហប្រជាជាតិ 'គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីការបង្ការទប់ស្កាត់ការប្រព្រឹត្តល្មើសរបស់អនីតិជន (គោលការណ៍ណែនាំទីក្រុងរីយ៉ាដ)' (អនុម័តដោយសេចក្តីសម្រេចរបស់មហាសន្និបាត លេខ ៤៥/១១២) (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០)
https://www.ohchr.org/en/ProfessionalInterest/Pages/PreventionOfJuvenileDelinquency.aspx

មហាសន្និបាតអង្គការសហប្រជាជាតិ "វិធានរបស់អង្គការសហប្រជាជាតិ ស្តីពីការការពារអនីតិជនដែលត្រូវបានគេដកហូតសិទ្ធិសេរីភាព" (ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០)
https://www.ohchr.org/EN/ProfessionalInterest/Pages/JuvenilesDeprivedOfLiberty.aspx

មហាសន្និបាតអង្គការសហប្រជាជាតិ 'វិធានបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ ស្តីពីការគ្រប់គ្រងយុត្តិធម៌អនីតិជន (ច្បាប់ទីក្រុងប៉េកាំង)' (ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥)
https://www.ohchr.org/EN/ProfessionalInterest/Pages/BeijingRules.aspx

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ 'សេចក្តីពន្យល់ទូទៅលេខ ១៣ – មាត្រា ១៤ (ការគ្រប់គ្រងយុត្តិធម៌) ភាពស្មើគ្នាចំពោះមុខតុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការឯករាជ្យដែលបង្កើតឡើងដោយច្បាប់ (ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៨៤)
https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=INT%2fCCPR%2fGEC%2f4721&Lang=en

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ 'សេចក្តីពន្យល់ទូទៅលេខ ២៩ – មាត្រា ៤៖ រដ្ឋក្នុងភាពអាសន្ន' (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១) CCPR/C/21/Rev.1/Add.11,
http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsjYoiCfMKoIRv2FVaVzRkMjTnjRO%2Bfud3cPVrcM9YR0iix49nlFOsUPO4oTG7R/o7TSsorhtwUUG%2By2PtsIYr5BldM8DN9shT8B8NpbsC%2B7bODxKR6zdESeXKjiLnNU%2BgQ%3D%3D

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ 'សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌' (ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧) CCPR/C/GC/32,
http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d/PPRiCAqhKb7yhsrdB0H1I5979OVGGB%2BWPAXhRj0XNTTvKgFHbxAcZSvX1OsJj/iyRmVA4IiMvUt2NlGKqqg2nh1qOE2hX5xoGtKE2v2YSQVV1Rv5NitNbSYwp

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារ 'សេចក្ដីពន្យល់ទូទៅលេខ ២៤ ស្ដីពីសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌កុមារ' (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩) CRC/C/GC/24, https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CRC%2fC%2fGC%2f24&Lang=en

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ 'សេចក្ដីពន្យល់ទូទៅលេខ ៣៥ - មាត្រា ៩៖ សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន (ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៤) CCPR/C/GC/35, https://www.ohchr.org/en/calls-for-input/general-comment-no-35-article-9-liberty-and-security-person

## ៨.៤. ករណីច្បាប់

***ជាតិ***

សេចក្ដីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) https://www.ccc.gov.kh/detail_info_en.php?_txtID=453

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាំង ហ្គេកអ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១) (សាលដីកាអង្គជំនុំជម្រះ) (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០) https://www.refworld.org/cases,ECCC,4c56ccfb2.html

***អន្តរជាតិ***

តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង *Asch ទល់នឹង ប្រទេសអូទ្រីស (*២៦ មេសា ១៩៩១*)* លេខ ២០៣ https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Asch%20v.%20Austria%201991%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-57676%22]%7D

តុលាការសិទ្ធិមនុស្សអឺរ៉ុប *Barberá, Messeguè* និង *Jabardo* ទល់នឹង ប្រទេសអេស្ប៉ាញ (៦ ធ្នូ ១៩៨៨) លេខ *A* ១៤៦, https://hudoc.echr.coe.int/eng#%7B%22itemid%22:[%22001-57429%22]%7D

តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង *Beckles* ទល់នឹង ចក្រភពអង់គ្លេស (៨ តុលា ២០០២) ពាក្យស្នើសុំលេខ ៤៤៦៥២/៩៨, https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Beckles%20v.%20the%20United%20Kingdom%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-60672%22]%7D

តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង *Condron* ទល់នឹង ចក្រភពអង់គ្លេស (២ ឧសភា ២០០០) ពាក្យស្នើសុំលេខ ៣៥៧១៨/៩៧, https://hudoc.echr.coe.int/eng#%7B%22itemid%22:[%22001-58798%22]%7D

តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង *Isgrò* ទល់នឹង ប្រទេសអ៊ីតាលី (១៩ កុម្ភៈ ១៩៩១) លេខ A ១៩៤-A, https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22(%5C%22Isgro%20v%20Italy%5C%22)%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-57653%22]%7D

តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង *Kostovski* ទល់នឹង ប្រទេសហូឡង់ (២០ ខែវិច្ឆិកា ១៩៨៩) លេខ A ១៦៦, https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Kostovski%20v.%20the%20Netherlands%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-57615%22]%7D
តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង Mirilashvili ទល់នឹង ប្រទេសរុស្ស៊ី (១១ ខែធ្នូ ឆ្នាំ ២០០៨) ពាក្យស្នើសុំលេខ ៦២៩១/០៤, https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Mirilashvili%20v.%20Russia%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-90099%22]%7D
តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង Samoila និង Cionca ទល់នឹង ប្រទេសរ៉ូម៉ានី (៤ មីនា ២០០៨) ពាក្យស្នើសុំលេខ ៣៣០៦៥/០៣, https://hudoc.echr.coe.int/eng#{"fulltext":["SAMOILA%20AND%20CIONCA"],"documentcollectionid2":["GRANDCHAMBER","CHAMBER"],"itemid":["001-85390"]}
តុលាការសិទ្ធិមនុស្សអឺរ៉ុបរវាង Sejdovic ទល់នឹង ប្រទេសអ៊ីតាលី (១ មីនា ២០០៦) ពាក្យស្នើសុំលេខ ៥៦៥៨១/០០, https://hudoc.echr.coe.int/eng#%7B%22fulltext%22:[%22Sejdovic%20v.%20Italy%22],%22languageisocode%22:[%22ENG%22],%22documentcollectionid2%22:[%22GRANDCHAMBER%22,%22CHAMBER%22],%22itemid%22:[%22001-72629%22]%7D
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ១០៣៣/២០០១, Singarasa ទល់នឹង ប្រទេសស្រីលង្ការ (២១ កក្កដា ២០០៤) CCPR/C/81/D/1033/2001, http://juris.ohchr.org/Search/Details/1125
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ៦០៩/១៩៩៥ Nathaniel Williams ទល់នឹង ប្រទេសចាម៉ៃកា (៤ វិច្ឆិកា ១៩៩៧) CCPR/C/61/D/609/1995
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ២៥៣/១៩៨៧, Kelly ទល់នឹង ប្រទេសចាម៉ៃកា (៨ មេសា ១៩៩១) CCPR/C/41/D/253/1987, http://juris.ohchr.org/Search/Details/418
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ៩១២/២០០០, Deolall ទល់នឹង ប្រទេសហ្គីយ៉ាណា (១ វិច្ឆិកា ២០០៤) CCPR/C/82/D/912/2000, http://juris.ohchr.org/Search/Details/1149
គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ០១៦/១៩៧៧ Mbenge ទល់នឹង ប្រទេសហ្សាអៀ (២៥ មីនា ១៩៨៣) CCPR/C/18/D/16/1977, http://juris.ohchr.org/Search/Details/573
គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បណ្ដឹងលេខ ២១៥/១៩៨៦ G.A. Van Meurs ទល់នឹង ប្រទេសហូឡង់ (២៣ កក្កដា ១៩៩០) CCPR/C/39/D/215/1986, http://hrlibrary.umn.edu/undocs/session39/215-1986.html

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ២៦៣/១៩៨៧, M. Gonzalez del Río ទល់នឹង ប្រទេសប៉េរូ (២៨ តុលា ១៩៩២) CCPR/C/46/D/263/1987, http://hrlibrary.umn.edu/undocs/html/dec263.htm

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ៣២០/១៩៨៨ V. Francis ទល់នឹង ប្រទេសចាម៉ៃកា (២៤ មីនា ១៩៩៣) *GAOR*, A/48/40 (vol. II), http://hrlibrary.umn.edu/undocs/html/320-1988.html

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បណ្ដឹងលេខ ៣៨៧/១៩៨៩ Karttunen ទល់នឹង ប្រទេសហ្វាំងឡង់ (២៣ តុលា ១៩៩២) CCPR/C/46/D/387/1989, http://juris.ohchr.org/Search/Details/402

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បណ្ដឹងលេខ ៧០១/១៩៩៦ Gómez ទល់នឹង ប្រទេសអេស្ប៉ាញ (២០ កក្កដា ២០០០) CCPR/C/69/D/201/1996, https://juris.ohchr.org/Search/Details/880

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, V. P. Domukovsky et al. ទល់នឹង ប្រទេសហ្សកហ្ស៊ី (៦ មេសា ១៩៩៨) CCPR/C/63/D/632/1995, http://juris.ohchr.org/Search/Details/833

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, Khuseynova និង Butaeva ទល់នឹង ប្រទេសតាហ្ស៊ីគីស្ថាន (២០ តុលា ២០០៨) CCPR/ C/94/D/1263–1264/2004, http://juris.ohchr.org/Search/Details/1457

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បណ្ដឹងលេខ ១៧៩៧/២០០៨ Mennen ទល់នឹង ប្រទេសហូឡង់ (២៧ កក្កដា ២០១០) CCPR/C/99/D/1797/2008, http://hrlibrary.umn.edu/undocs/1797-2008.html

## ៨.៥. ទ្រឹស្ដី

Nowak Manfred, 'កតិកាសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ – បទអត្ថាធិប្បាយ CCPR" (បោះពុម្ពលើកទី២ N.P. Engel ២០០៥)

## ៨.៦. សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌

អង្គការលើកលែងទោសអន្តរជាតិ 'សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ' បោះពុម្ពលើកទីពីរ ក្រុងឡុងដ៍៖ ការបោះពុម្ពផ្សាយរបស់អង្គការលើកលែងទោសអន្តរជាតិ AI Index POL 30/002/2014 (2014) https://www.amnesty.org/en/documents/pol30/002/2014/en/

Oliveira Bárbara និង Besharaty-Movaed Linda, 'សៀវភៅស្ដីពីការសង្កេតសវនាការរបស់របស់គណៈកម្មការអ្នកច្បាប់អន្តរជាតិ' ទីក្រុងហ្សឺណែវ គណៈកម្មការអ្នកច្បាប់អន្តរជាតិ (២០០២) http://hrlibrary.umn.edu/research/trial_observation_manual.pdf

អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការប្រចាំអឺរ៉ុប ("OSCE") / ការិយាល័យស្ថាប័នប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ("ODIHR") 'ការសង្កេតការណ៍ការសវនាការ៖ សៀវភៅយោងសម្រាប់អ្នកប្រតិបត្តិ' ប្រទេសប៉ូឡូញ៖ OSCE/ODIHR (2012) https://www.osce.org/files/f/documents/5/f/94216.pdf

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស 'សិទ្ធិមនុស្សនៅក្នុងការគ្រប់គ្រងយុត្តិធម៌៖ សៀវភៅស្តីពីសិទ្ធិមនុស្សសម្រាប់ចៅក្រម រដ្ឋអាជ្ញា និងមេធាវី' ញូវយ៉ក និងហ្សឺណែវ៖ OHCHR, ២០០៣ ។ "ជំពូកទី ៦ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ៖ ផ្នែកទី ១ – ចាប់ពីការស៊ើបអង្កេតរហូតដល់ការជំនុំជម្រះ" https://www.ohchr.org/Documents/Publications/training9chapter6en.pdf និង "ជំពូកទី ៧ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌៖ ផ្នែកទី ២ – ចាប់ពីការជំនុំជម្រះដល់ការសម្រេចស្ថាពរ" https://www.ohchr.org/Documents/Publications/training9chapter7en.pdf

Pejic Jelena និង Lesnie Vanessa 'តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌? មគ្គុទ្ទេសក៍ជាមូលដ្ឋាន ស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់ ញូវយ៉ក៖ គណៈកម្មាធិការមេធាវីសិទ្ធិមនុស្ស (២០០០) https://internationalcourts.net/system/files/LawyersCommitteeForHumanRights_WhatIsAFairTrial_2000._pdf

## ៨.៧. ឯកសារសង្កេតការណ៍សវនាការ និងប្រព័ន្ធផ្ទុកទិន្នន័យរបស់ ម.ស.ម.ក

ម.ស.ម.ក 'តារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍'
https://sithi.org/km/tmp/publication/view/2021-01-01-appeal-hearing-monitoring-checklist

ម.ស.ម.ក 'ក្រមសីលធម៌អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក'
https://sithi.org/km/tmp/publication/view/2010-01-01-cchr-trial-monitoring-code-of-conduct

ម.ស.ម.ក 'គោលការណ៍ណែនាំស្តីពីតារាងសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក' https://sithi.org/km/tmp/publication/view/2014-01-29-guidance-notes-for-cchr-appeal-court-monitoring-checklist

ប្រព័ន្ធផ្ទុកទិន្នន័យអំពីការសង្កេតសវនាការរបស់ ម.ស.ម.ក អាចស្វែងរកបាននៅ
https://sithi.org/km/tmp/appeal

## ៨.៨. ការបោះពុម្ពផ្សាយរបស់ ម.ស.ម.ក

ម.ស.ម.ក, 'សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា៖ ការពិនិត្យ UPR លើកទី៣'
https://sithi.org/medias/files/projects/tmp/publication/final-upr-cambodia-joint-submission-on-access-to-justice-kh-20231206-171032.pdf

ម.ស.ម.ក, គោលដៅយុត្តិធម៌ និងអាដហុក, 'ដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិសម្រាប់ការពិនិត្យជាសាកលតាមពេលកំណត់លើកទី ៣ នៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិទទួលបានយុត្តិធម៌

នៅកម្ពុជា', (១២ កក្កដា ២០១៨),
www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS32.aspx (JS7)
ម.ស.ម.ក ' ព្រឹត្តិបត្រព័ត៌មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ 'ឯកសណ្ឋានពន្ធនាគារ និងការសន្មតទុកជាមុនថាគ្មានទោស' (មិថុនា ២០១៧)
https://sithi.org/medias/files/projects/tmp/publication/cchr-fair-trial-rights-newsletter-on-prisoner-uniform-and-the-presumption-of-innocence-english2017-06-05.pdf
ម.ស.ម.ក 'ការអនុវត្តការពិនិត្យជាសាកលតាមពេលកំណត់៖ ពីរឆ្នាំខាងមុខ' (មករា ២០២១),
https://sithi.org/medias/files/projects/upr/infographic/Implementation%20of%20the%20Universal%20periodic%20review%20Eng.pdf
ម.ស.ម.ក 'ការវិភាគច្បាប់ សេចក្តីព្រាងច្បាប់ចំនួនបី ទាក់ទងនឹងប្រព័ន្ធតុលាការ' (២០១៤),
https://sithi.org/medias/files/projects/tmp/publication/cchr-analysis-of-the-draft-laws-on-judicial-reforms-eng-final2014-05-16.pdf
ម.ស.ម.ក 'កម្រងមេរៀនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌' (កញ្ញា ២០២២),
https://sithi.org/km/fair-trial-rights
ម.ស.ម.ក 'ការដាក់ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មុនពេលការពិនិត្យលើកទីបីនៃព្រះរាជាណាចក្រកម្ពុជា' (មករា ២០២២),
https://tbinternet.ohchr.org/Treaties/CCPR/Shared%20Documents/KHM/INT_CCPR_CSS_KHM_47750_E.pdf

### ៨.៩. ផ្សេងៗ

គណៈកម្មាធិការសិទ្ធិមនុស្ស 'ការបញ្ចប់ការសង្កេតលើរបាយការណ៍តាមពេលកំណត់លើកទីបីរបស់ប្រទេសកម្ពុជា' (១៨ ឧសភា ២០២២), CCPR/C/KHM/CO/3,
https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2FC%2FKHM%2FCO%2F3&Lang=en
រាជរដ្ឋាភិបាលកម្ពុជា ការដាក់ជូនរបាយការណ៍ថ្នាក់ជាតិអនុលោមតាមកថាខណ្ឌទី ៥ នៃឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ១៦/២១' របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស, (១៥ វិច្ឆិកា ២០១៨), A/HRC/WG.6/32/KHM/1, កថាខណ្ឌ ៧៤, https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement
រាជរដ្ឋាភិបាលកម្ពុជា 'ការឆ្លើយតបរបស់កម្ពុជាចំពោះបញ្ជីបញ្ហាទាក់ទងនឹងរបាយការណ៍តាមពេលកំណត់លើកទីបីរបស់ខ្លួន' (១៦ មេសា ២០២១), CCPR/C/KHM/RQ/3, para.50,
https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CCPR%2fC%2fKHM%2fRQ%2f3&Lang=en

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្ដីព្រាងច្បាប់ស្ដីពីឋានៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ' (ឧសភា ២០១៤), http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20status%20of%20J%20and%20P,%20ENG%20May%202014%20final.pdf

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្ដីព្រាងច្បាប់ស្ដីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ' (ឧសភា ២០១៤), http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20SCM%20Draft%20law,%20ENG%20May%202014%20final.pdf

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា 'មតិយោបល់លើបទប្បញ្ញត្តិមួយចំនួននៃសេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការទាក់ទងនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ' (ឧសភា ២០១៤), http://cambodia.ohchr.org/~cambodiaohchr/sites/default/files/OHCHR%20comments%20on%20draft%20Law%20on%20org%20of%20courts,%20ENG%20May%202014%20final.pdf

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស 'តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស' (៣១ កក្កដា ២០១៩) A/HRC/42/31 កថាខណ្ឌទី ៣០ https://cambodia.ohchr.org/sites/default/files/Ohchr-report/Role%20and%20achievements%20of%20the%20Office.pdf

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស 'តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស' (១៦ កញ្ញា ២០២១), A/HRC/48/49, https://cambodia.ohchr.org/sites/default/files/Ohchr-report/A_HRC_48_49.pdf

អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា 'ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា' (០៣ សីហា ២០២១) https://documents-dds-ny.un.org/doc/UNDOC/GEN/G21/210/37/PDF/G2121037.pdf?OpenElement

មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) 'សំណួរ-ចម្លើយអំពីច្បាប់ស្ដីពីយុត្តិធម៌អនីតិជនដែលទើបអនុម័តថ្មីនៅកម្ពុជា' (១៩ កញ្ញា ២០១៦) http://unicefcambodia.blogspot.com/2016/09/q-on-newly-adopted-juvenile-justice-law.html

មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) 'គោលការណ៍ណែនាំសម្រាប់កំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន'
https://www.un.org/ruleoflaw/files/Juvenile_justice_16052011_final.pdf
មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) 'ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ'
https://www.unicef.org/lac/media/22071/file/Implementation%20Handbook%20for%20the%20CRC.pdf
មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) 'កំណែទម្រង់ច្បាប់ និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ' http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf ។